សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៧

តាក់តែងឡើងដោយ
និស្សិតឈ្មោះ ក. **ស៊ុន មរកត**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **សឿន សោភ័ណ**

ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ
ជំនាន់ទី១០ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ស៊ុន មរកត** ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១០ ឆ្នាំសិក្សា ២០១៦-២០១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សូមគោរពថ្លែងអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅជូនៈ

អ្នកម្តាយ **ឃឹម ឡាយ** ដែលបានខិតខំធ្វើការដោយមិនខ្លាចភាពនឿយហត់ ដើម្បីឱ្យកូនបានសិក្សារៀនសូត្ររហូតដល់ពេលនេះ ព្រមទាំងអរគុណដ៏ទឹកចិត្តដ៏ថ្លៃថ្លាក្នុងការឆ្លៀតពេលពីកាលវិភាគធ្វើការដ៏មមាញឹកមកមើលថែរក្សាកូនលុះដល់វ័យកូនធំល្មមអាចមើលថែខ្លួនឯងបាន។

មិត្តភក្តិទាំងឡាយដែលបានជួយលើកទឹកចិត្ត និងការផ្តល់ជាមតិយោបល់។

ថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោកគ្រូ អ្នកគ្រូការិយាល័យ ដែលតែងជួយសម្រួលការងារផ្សេងៗដល់និស្សិតគ្រប់ជំនាន់ ព្រមទាំងសាស្ត្រាចារ្យទាំងឡាយ ដែលបានបង្ហាត់បង្រៀន ក៏ដូចជាចែករំលែកបទពិសោធន៍ល្អៗ និងការតម្រង់ទិសជំនាញវិជ្ជាជីវៈដល់និស្សិតគ្រប់ជំនាញ។

ជាពិសេស នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **បណ្ឌិត សឿន សោភ័ណ** ដែលលោកបានជួយដឹកនាំ ជ្រោមជ្រែង ត្រួតពិនិត្យ កំឡុងពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះឱ្យប្រព្រឹត្តទៅបានដោយរលូន។ ហើយបើសិនជាគ្មានវត្តមានរបស់សាស្ត្រាចារ្យទេ ប្រហែលជានាងខ្ញុំក៏មិនអាចសម្រេចបាននូវភារកិច្ចមួយនេះបានទេ គឺក៏ព្រោះតែលោកបានចំណាយពេលវេលាក៏មានតម្លៃក្នុងការពិនិត្យ និងកែលម្អនូវសារណាមួយនេះឱ្យមានលក្ខណៈល្អប្រសើរ។

ជាចុងក្រោយ នាងខ្ញុំសូមលើកម្រាមដៃដប់ប្រមាណប្បូងសួងដល់វត្ថុស័ក្តសិទ្ធិទាំងអស់នៅលើលោកនេះ សូមតាមថែរក្សាការពារដល់អ្នកមានគុណ មិត្តភក្តិទាំងឡាយ ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ឱ្យជួបតែសេចក្តីសុខ អាយុយឺនយូរ សុខភាពបរបូរណ៍ និងសម្រេចគ្រប់ភារកិច្ច៕

# អារម្ភកថា

នាងខ្ញុំជានិស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី១០។ នៅឆ្នាំទី៤នេះ ដែលជាឆ្នាំបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នាងខ្ញុំបានជ្រើសរើស ប្រធានបទ "ការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច" ដើម្បីធ្វើការស្រាវជ្រាវនិងចងក្រងជាសៀវភៅសារណានេះឡើងដោយសង្ឃឹមថា ជាជំនួយដល់មិត្តនិស្សិតទាំងឡាយក្នុងការយល់ដឹងបន្ថែម ទៀតអំពីបញ្ហាពិការភាពនៅក្នុងសង្គមកម្ពុជា ឱ្យកាន់តែច្បាស់ជាងមុន និងជួយធ្វើឱ្យមានសមភាពរវាងជនពិការ និងជនមិនពិការ។

ទោះបីជាការស្វែងរកឯកសារពាក់ព័ន្ធមានភាពលំបាកបន្តិចមែន ដោយត្រូវច្បិចយកចំណុចមួយ ចំនួនតូចចេញពីឯកសារមួយចំនួនធំ ព្រមទាំងការបកប្រែឯកសារភាសាបរទេសផងនោះ ក៏នាងខ្ញុំនៅតែមានសេចក្តីសោមនស្សក្នុងការចងក្រងសៀវភៅនេះឡើង។ សេចក្តីស្និតស្នាលញក្នុងការស្រាវជ្រាវប្រមូលផ្តុំទៅលើប្រធានខាងលើ ក៏ព្រោះតែនាងខ្ញុំយល់ថាជនពិការភាគច្រើនត្រូវបានគេផាត់ចេញពីសង្គម បណ្តាលឱ្យជីវិតរបស់ពួកគាត់ហាក់មិនសូវមានពន្លឺនៃសេចក្តីសង្ឃឹម ខណៈពេលដែលជនពិការក៏ដូចជាជនមិនពិការដែរ ពោលគឺជាកោសិកានៃសង្គមយើងដូចគ្នា។ មួយវិញទៀតយើងតែងបានឃើញជនពិការធ្វើអាជីវកម្មនៅតាមដងវិថីដើម្បីតែជីវភាព ដែលទីនោះជាកន្លែងគ្រោះថ្នាក់ ទទួលរងការបណ្តេញ ការជេរប្រមាថពីសំណាក់ជនមួយចំនួន ដែលរួមមានអាជ្ញាធរមានសមត្ថកិច្ចមួយចំនួនតូចផងដែរ។ ស្ថានភាពនេះយើងអាចនឹងយល់ថា ដោយសារតែពួកគាត់ពិការគឺមានតែជម្រើសបែបនេះឬស្រដៀងនេះទើបអាចរកចំណូលសម្រាប់ខ្លួននិងគ្រួសារបាន ផ្ទុយស្រលះពីការគិតបែបនេះ ជនពិការក៏អាចធ្វើការក្នុងតួនាទីទាំងឡាយដែលជនមិនពិការធ្វើបានដូចគ្នា ប្រសិនពួកគាត់មានឱកាសពេញលេញក្នុងការ ទទួលបានការអប់រំ សេវាសុខភាព និងការលើកទឹកចិត្តក្នុងការចូលរួម។

នាងខ្ញុំសង្ឃឹមថា ប្រធានបទស្តីពី "ការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច" ពិតជាអាចនាំឱ្យមិត្តអ្នកអានបានយល់ច្បាស់ថា ពិការភាពមិនមានន័យស្មើនឹងជនពិការនោះទេ តែគឺជាឧបសគ្គ ដែលយើងទាំងអស់គ្នាត្រូវរួមគ្នាដកចេញ។

ជាទីបញ្ចប់ នាងខ្ញុំសុំអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងដែលបានកើតឡើងដោយអចេតនានិងភាពខ្វះចន្លោះទាំងឡាយក្នុងការចងក្រងសៀវភៅនេះ ព្រមទាំងជួយកែសម្រួលដោយអនុគ្រោះផង៕

# តារាងសម្គាល់អក្សរកាត់

| | |
|---|---|
| ABC | Association for the Blind in Cambodia |
| APMBC | Anti-Personnel Mine Ban Convention |
| ARC | Australian Red Cross |
| CABDICO | Capacity Building of People with Disability in the Community Organization |
| CBR | Community Based Rehabilitation |
| CCAMH | Chey Chumneas Referral Hospital´s Centre for Child and Adolescent Mental Health |
| CDMD | Cambodian Development Mission for Disability |
| CDPO | Cambodia Disabled People´s Organization |
| CEDAW | Convention on the Elimination of All Forms of Discrimination Against Women |
| CIDI | Cambodia Initiative for Disability Inclusion |
| CMAA | Cambodian Mine Action and Victim Assistance Authority |
| CMVIS | Cambodia Mine/ERW Victim Information System |
| CNVLD | Cambodian National Volleyball League Disabled |
| CRC | Convention on the Rights of the Child |
| CRPD | Convention on the Rights of Persons with Disabilities |
| CSES | Cambodia Socio-Economic Survey |
| CT | Cambodia Trust |
| DAC | Disability Action Council |
| DDSP | Disability Development Services Programme |
| DDP | Deaf Development Programme |
| DoLA | Department of Local Administration |
| DPO | Disabled People´s Organization |
| DWPD | Department of Welfare for Persons with Disabilities |
| ECCD | Early Childhood Care and Development |
| EMIS | Education Management Information System |

| | |
|---|---|
| HEF | Health Equity Fund |
| HIF | Handicap International Federation |
| ICESCR | International Covenant on Economic, Social and Cultural Rights |
| ICRC | International Committee of the Red Cross |
| ILO | International Labour Organization |
| JRS | Jesuit Refugee Service |
| KNKS | Kumar Ney Kdey Sangkheum "Children of Hope" |
| KPF | Komar Pikar Foundation |
| KT | Krousar Thmey |
| MDGs | The Millennium Development Goals |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation |
| NCDD | National Committee for Sub-National Democratic Development |
| NCDP | National Centre for Disabled People |
| NDSP | National Disability Strategic Plan 2014-2018 |
| NPA | National Plan of Action for Persons with Disabilities including Landmine/ERW Survivors 2009-2011 |
| NP-SNDD | National Programme for Sub-National Democratic Development |
| NSPS | National Social Protection Strategy for the Poor and Vulnerable |
| OEC | Operations Enfants du Cambodge |
| PPCIL | Phnom Penh Center for Independent Living |
| PRC | Physical Rehabilitation Centre |
| PWDF | Persons with Disabilities Foundation |
| SDGs | Sustainable Development Goals |
| SHG | Self-help group |
| TIGA | Towards Sustainable Income Generating Activities |
| RSO | Rabbit School Organization |
| USAID | The United States Agency for International Development |
| UNDP | United Nations Development Programme |

| | |
|---|---|
| UNESCAP | United Nations Economic and Social Commission for Asia and the Pacific |
| UNICEF | United Nations Children´s Fund |
| UNOHCHR | United Nations Office of the High Commissioner for Human Rights |
| URC | University Research of Cambodia |
| VI-C | Veterans International Cambodia |
| WASH | Water, sanitation and hygiene |
| WHO | World Health Organization |

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១៖ ពិការភាព និង អភិបាលកិច្ច**

**១.១ ទិដ្ឋភាពទូទៅនៃពិការភាពនៅទូទាំងពិភពលោក និងនៅកម្ពុជា** ........................................ ៥

១.១.១ ពិការភាពនៅទូទាំងពិភពលោក ........................................ ៥

១.១.២ ពិការភាពនៅកម្ពុជា ........................................ ៧

**១.២ អំពីអភិបាលកិច្ច** ........................................ ១០

១.២.១ គោលបំណង និងតួអង្គសំខាន់ៗក្នុងអភិបាលកិច្ច ........................................ ១០

១.២.២ អភិបាលកិច្ចល្អ ........................................ ១១

**១.៣ សារសំខាន់នៃការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច** ........................................ ១៤

១.៣.១ និយមន័យពាក្យគន្លឹះ ........................................ ១៤

១.៣.២ អត្ថប្រយោជន៍នៃការដាក់បញ្ចូលពិការភាព ........................................ ១៥

**ជំពូកទី២៖ ក្របខណ្ឌគាំពារវិស័យពិការភាព**

**២.១ មូលដ្ឋានគតិយុត្តទាក់ទងនឹងសិទ្ធិជនពិការ** ........................................ ១៩

២.១.១ ច្បាប់អន្តរជាតិ ........................................ ១៩

២.១.២ ច្បាប់ជាតិ ........................................ ២១

**២.២ តួអង្គពាក់ព័ន្ធ និងសេវាកម្មទាក់ទងវិស័យពិការភាព** ........................................ ២៨

២.២.១ តួអង្គពាក់ព័ន្ធ ........................................ ២៨

២.២.២ សេវាកម្មទាក់ទងនឹងជនពិការ ........................................ ៣៣

**២.៣ ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការរៀបចំផែនការ** ........................................ ៣៦

២.៣.១ ថ្នាក់ឃុំ សង្កាត់ ........................................ ៣៦

២.៣.២ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ........................................ ៣៨

**ជំពូកទី៣៖ របកគំហើញលើការស្រាវជ្រាវ**

**៣.១. កត្តារារាំងដល់ជនពិការក្នុងការអភិវឌ្ឍខ្លួន** ........................................ ៤១

៣.១.១. ភាពមានកម្រិតក្នុងការប្រមូលទិន្នន័យជនពិការ ........................................... ៤១
៣.២.២. ឧបសគ្គចម្បងៗដែលជនពិការជួបប្រទះ........................................................ ៤២
**៣.២. ដំណោះស្រាយ** .......................................................................................... ៤៣
៣.២.១. ឥរិយាបថ .............................................................................................. ៤៣
៣.២.២. ការប្រាស្រ័យទាក់ទង ............................................................................... ៤៤
៣.២.៣. ការបង្កភាពងាយស្រួល............................................................................. ៤៥
៣.២.៤. ការចូលរួម............................................................................................. ៤៥

**សេចក្ដីសន្និដ្ឋាន** ........................................................................................... ៤៨
**អនុសាសន៍** .................................................................................................. ៥០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

អត្រាជនពិការខ្ពស់ គឺជាផលវិបាកមួយក្នុងចំណោមផលវិបាកដទៃទៀតដែលសង្គ្រាមបានបន្សល់ទុកឱ្យកម្ពុជា បន្ទាប់ពីប្រទេសមួយនេះបានឆ្លងកាត់មហន្តរាយនៃសង្គ្រាមជាច្រើនទសវត្សរ៍ ជាពិសេសគឺការទម្លាក់គ្រាប់ពីសហរដ្ឋអាមេរិក និងក្នុងរបបប្រល័យពូជសាសន៍ដែលធ្វើឱ្យប្រជាជនស្លាប់ជាច្រើនសន្ធឹក រីឯអ្នកដែលរួចរស់មានជីវិតវិញគឺភាគច្រើនមានបញ្ហាកង្វះអាហារូបត្ថម្ភ មានជម្ងឺប្រចាំកាយ ព្រោះធ្លាប់ទទួលរងទណ្ឌកម្ម និងខ្លះទៀតបានបាត់បង់កាយសម្បទាព្រោះតែកាកសំណល់សង្គ្រាម។ ទោះបីសង្គ្រាមបានកន្លងផុតទៅយូរឆ្នាំក៏ពិតមែន តែបញ្ហាគ្រាប់មីនបង្កប់ក្នុងដីនៅតែជាការព្រួយបារម្ភណ៍មួយ។ គួរបញ្ជាក់ផងដែរថានៅដើមឆ្នាំ២០១៧ ខែមករានេះ គេប្រទះឃើញគ្រាប់បែកគីមីចំនួន២គ្រាប់នៅក្នុងខេត្តស្វាយរៀង ហើយនៅខែកុម្ភៈ គេក៏បានប្រទះឃើញគ្រាប់បែកប្រភេទ Mk82 ទម្ងន់២២០គីឡូក្រាមទៀតនៅខេត្តព្រៃវែង។[1] នេះអាចជាសញ្ញាអវិជ្ជមានមួយដែលគួសបង្ហាញថាអាចមានជនរងគ្រោះ ធ្លាក់ខ្លួនពិការឬស្លាប់ ដោយសារកាកសំណល់សង្គ្រាមនាពេលអនាគតទៀត បើមិនមានការសហការចាត់ចែងលើបញ្ហានេះ។ ក្រៅអំពីសង្គ្រាមដែលបង្កឱ្យមានជនពិការជាច្រើន គេក៏ប្រទះឃើញមានមូលហេតុចំបងៗផ្សេងទៀតដែលមានជាអាទិ៍ គ្រោះថ្នាក់ការងារ ជម្ងឺតម្កាត់ ចាស់ជរា កង្វះអាហារូបត្ថម្ភ និងជាពិសេសគ្រោះថ្នាក់ចរាចរណ៍ដែលកំពុងកើនឡើងជាប្រចាំ។

នៅក្នុងប្រទេសកម្ពុជា ជនពិការភាគច្រើនរស់នៅក្នុងភាពក្រីក្រ និងជាក្រុមងាយរងគ្រោះជាងគេនៅក្នុងសង្គម។ [2] ជនពិការតែងតែទទួលរងការរើសអើង និងមានឱកាសតិចតួចក្នុងការចូលរួមក្នុងគ្រប់សកម្មភាពសង្គមរួមមានផ្នែកសុខភាព អប់រំ ឱកាសការងារ ការចូលរួមក្នុងសកម្មភាពនយោបាយ និងឱកាសស្មើភាពគ្នាក្នុងសង្គម។ ដើម្បីដោះស្រាយតម្រូវការនិងជួយជនពិការ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនិងអនុវត្តច្បាប់ គោលនយោបាយ ក៏ដូចជាយុទ្ធសាស្ត្រនានាដើម្បីផ្តល់ផលប្រយោជន៍ជូនជនពិការរួមទាំងសិទ្ធិទទួលបានការងារដ៏សមរម្យផងដែរ។ ជាច្បាប់គោលសម្រាប់ជនពិការ គឺកម្ពុជាបានអនុម័ត និងប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) មានការទទួលខុសត្រូវក្នុងការធានានូវសុខុមាលភាពជនពិការ និងក្រុមងាយរងគ្រោះផ្សេងៗទៀត។ យ៉ាងណាមិញ បញ្ហាពិការភាពគឺជាបញ្ហាពហុវិស័យដែលទាមទារឱ្យ

[1] ការចុះផ្សាយរបស់វិទ្យុបារាំងអន្តរជាតិ ថ្ងៃទី២៥ ខែមករា និង ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧

[2] របាយការណ៍ប្រចាំឆ្នាំ២០១១ របស់ក្រុមប្រឹក្សាសកម្មភាពជនពិការ

មានការចូលរួម និងសហការពីគ្រប់ភាគីពាក់ព័ន្ធ ដែលរួមមាន ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី អង្គការក្រៅរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដែលត្រូវរួមគ្នាអនុវត្តច្បាប់និងគោលនយោបាយ និងបង្កើតគម្រោងកម្មវិធីដើម្បីការពារ និងលើក កម្ពស់សិទ្ធិ និងសុខុមាលភាពជន។

## ២. ចំណោទបញ្ហា

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "ការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច" បាន បង្កើតនូវបញ្ហាចោទមួយចំនួនដូចជា៖

- សារប្រយោជន៍នៃការដាក់បញ្ចូលពិការភាព បានផលយ៉ាងដូចម្តេចខ្លះចំពោះជនពិការ និងសង្គមទាំងមូលនាពេលបច្ចុប្បន្ន និងអនាគត?
- តើមានច្បាប់អន្តរជាតិ និង ច្បាប់ជាតិណាខ្លះដែលគាំទ្រដល់ការបញ្ចូលពិការភាពទៅ ក្នុងអភិបាលកិច្ចក៏ដូចជាការលើកកម្ពស់សិទ្ធិជនពិការ? ជាពិសេសទៅទៀត តើមាន ផែនការយុទ្ធសាស្ត្រអ្វីខ្លះ សម្រាប់ការដាក់បញ្ជ្រាបពិការភាពទាំងថ្នាក់ជាតិ និងថ្នាក់ ក្រោមជាតិ? តើមានកត្តាអ្វីខ្លះដែលជួយគាំទ្រដល់ដំណើរការនេះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺមានគោលបំណងស្វែងយល់ពីស្ថានភាពជនពិការនៅក្នុងសង្គមកម្ពុជា ជាពិសេសគឺឧបសគ្គចំបងៗដែលរារាំងពួកគាត់មិនឱ្យទទួលបានឱកាសស្មើភាពគ្នា និងយន្តការ ទាំងឡាយ ដែលបានដាក់ចេញទាំងខាងរដ្ឋាភិបាល ក៏ដូចជាខាងអង្គការក្រៅរដ្ឋាភិបាលដើម្បី បញ្ចូលពិការភាពទៅក្នុងផ្នែកមួយនៃការសម្រេចចិត្តរបស់អ្នកគ្រប់គ្រង។ មួយវិញទៀត យើងធ្លាប់ បានដឹងពីច្បាប់ គោលនយោបាយ និងគម្រោងកម្មវិធីនានាដែលធ្វើឡើងដើម្បីគាំទ្រដល់ជនពិការក៏ ពិតមែន តែយើងប្រហែលជាមិនបានយកចិត្តទុកដាក់ទៅលើភាពលម្អិតនៃគម្រោងកម្មវិធី ឬគោល នយោបាយទាំងនោះទេ ជាពិសេសថាតើវាមានដំណើរការដល់ដំហានណាហើយ។ ដូច្នេះហើយ ការស្រាវជ្រាវទៅលើប្រធានបទនេះ គឺការចងក្រងឯកសារពាក់ព័ន្ធជនពិការ ដើម្បីជាចំណែកមួយ ក្នុងការចែកចាយព័ត៌មានទាក់ទងជនពិការទៅកាន់ជនមិនពិការ ក្នុងន័យឱ្យពួកគាត់បានគិតគូរអំពី ចំណែករបស់ជនពិការក្នុងសង្គមយើង ដែលផ្តោតទៅលើគោលបំណងពីរសំខាន់ៗគឺ៖

- ដើម្បីបង្ហាញឱ្យឃើញពីសារប្រយោជន៍នៃការដាក់បញ្ចូលពិការភាព។
- ដើម្បីសិក្សាស្វែងយល់ពីបទដ្ឋានគតិយុត្តិដែលគាំទ្រដល់ការដាក់បញ្ចូលពិការភាព និងកត្តា ផ្សេងៗទៀតដែលជួយជំរុញដល់ដំណើរការនេះ។

## ៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវសំដៅដល់ លិខិតបទដ្ឋានចំបងៗដែលរាជរដ្ឋាភិបាល និងក្រសួងអាទិភាពពាក់ព័ន្ធពិការភាពបានដាក់ចេញ ដើម្បីបញ្ជ្រាបនិងលើកកម្ពស់សិទ្ធិជនពិការនៅទូទាំងប្រទេស។ ហេតុផល និងសារសំខាន់ដែលយើងត្រូវគិតគូរពីការដាក់បញ្ចូលពិការភាពទៅក្នុងការសម្រេចចិត្ត។ លើសពីនេះទៀត ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងក្របខណ្ឌពេលវេលានៃឆ្នាំ២០១១ ដល់ពាក់កណ្តាលឆ្នាំ២០១៧ តែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

លទ្ធផលដែលទទួលបានពីការស្រាវជ្រាវនេះ មានសារៈសំខាន់សម្រាប់មហាជនទូទៅដែលមាន ចំណាប់អារម្មណ៍ទៅលើស្ថានភាពផ្សេងៗនៃសង្គមកម្ពុជា ខណៈការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចគឺជាផ្នែកមួយ ជួយជំរុញតម្លាភាព និងការចូលរួមឱ្យបានកាន់តែប្រសើរ។ ម្យ៉ាងវិញទៀត វាក៏ជាសារតូចមួយដើម្បីបង្វែរខ្សែចក្ខុរបស់អ្នកអានដែលជាមនុស្សមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្ត ជាពិសេសគឺមិត្តនិស្សិតដែលអនាគតជាអ្នកកាន់កិច្ចការគ្រប់គ្រងដឹកនាំប្រទេស ឱ្យបានសញ្ជឹងគិតពីតម្រូវការរបស់ ជនពិការនិងជួយសម្រួលស្ថានភាពជនពិការឱ្យដូចជនមិនពិការតាមលទ្ធភាពដែលអាចធ្វើទៅបាន។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

បន្ទាប់ពីធ្វើការកំណត់បញ្ហា និងគោលបំណងស្រាវជ្រាវរួចមក ការស្រាវជ្រាវនឹងចាប់ផ្តើមដំណើរការទៅតាមវិធីសាស្ត្រទិន្នន័យទីពីរ (Secondary Research) ដែលសំដៅទៅលើទិន្នន័យនិងព័ត៌មានមានស្រាប់ ជាការសិក្សាប្រមូលផ្តុំរាល់ឯកសារ សៀវភៅ របាយការណ៍ ឬស្ថិតិផ្សេងៗដែលពាក់ព័ន្ធនឹងការស្រាវជ្រាវ។ ការចងក្រងនូវទិន្នន័យពីប្រភពទិន្នន័យទី២នេះ គឺដើម្បីធ្វើអោយខ្លឹមសារមានអំណះអំណាងច្បាស់លាស់។ ប្រភពទិន្នន័យទី២នេះ គឺត្រូវបានប្រមូលពីបណ្តាស្ថាប័នអង្គការ និងមជ្ឈដ្ឋានសាធារណៈមួយចំនួនដូចជា៖

- បណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រ សេដ្ឋកិច្ច ក៏ដូចជាបណ្ណាល័យនៃក្រសួងមហាផ្ទៃ និងបណ្ណាល័យអេឡិចត្រូនិច
- ការស្វែងរកពត៌មានផ្សេងៗក៏បានធ្វើឡើងតាមរយៈគេហទំព័របច្ចេកវិទ្យា
- ឯកសារគតិយុត្តិ (មានច្បាប់ ផែនការយុទ្ធសាស្ត្រ...)
- បណ្តុំសំណៅឯកសារនានា (ឯកសារបោះផ្សាយ សៀវភៅណែនាំ របាយការណ៍...)។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- សេចក្តីផ្តើម
- ជំពូក១៖ ជំពូកនេះបង្ហាញពី ទិដ្ឋភាពទូទៅនៃពិការភាពនៅទូទាំងពិភពលោក និងនៅកម្ពុជា អំពីអភិបាលកិច្ចដែលរួមមានគោលបំណងនៃអភិបាលកិច្ច តួអង្គសំខាន់ៗក្នុងអភិបាលកិច្ច និងអ្វីទៅជាអភិបាលកិច្ចល្អ ព្រមទាំងលើកឡើងអំពីសារសំខាន់នៃការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច។
- ជំពូក២៖ ជំពូកនេះលើកឡើងអំពី មូលដ្ឋានគតិយុត្តទាក់ទងនឹងសិទ្ធិជនពិការ តួអង្គពាក់ព័ន្ធ និងគម្រោងកម្មវិធីទាក់ទងវិស័យពិការភាព ព្រមទាំងការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ ដែលជាក្របខណ្ឌគាំពារវិស័យពិការភាព។
- ជំពូកទី៣៖ ជំពូកនេះបង្ហាញពីរបកគំហើញលើការស្រាវជ្រាវ ដែលរួមមានកត្តារារាំងដល់ជនពិការក្នុងការអភិវឌ្ឍខ្លួន និងដំណោះស្រាយ។
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ

# ជំពូកទី១

# ពិការភាព និង អភិបាលកិច្ច

# ជំពូកទី១

# ពិការភាព និង អភិបាលកិច្ច

## ១.១ ទិដ្ឋភាពទូទៅនៃពិការភាពនៅទូទាំងពិភពលោក និងនៅកម្ពុជា

### ១.១.១ ពិការភាពនៅទូទាំងពិភពលោក

ពិការភាពនៅលើពិភពលោកមានចំនួន១៥% នៃចំនួនប្រជាជនសរុបក្នុងពិភពលោក ដែលក្នុងចំណោមមនុស្ស៧នាក់មានម្នាក់មានពិការភាព ហើយជីវិតរបស់ជនពិការត្រូវបានកំណត់សំគាល់ដោយ លទ្ធផលសុខភាពខ្សោយ សមិទ្ធផលនៃការអប់រំទាប ការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចមានតិចតួច អត្រានៃភាពក្រីក្រកាន់តែកើនឡើង ការកើនឡើងនៃភាពពឹងពាក់ (WHO & World Bank, 2011) ហើយប្រមាណ៨0% រស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ (WHO, 2014)។ ទោះបីជាពិការភាព មិនត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) របស់អង្គការសហប្រជាជាតិក្តី ក៏វាត្រូវបានបញ្ចូលជាបន្តបន្ទាប់ទៅក្នុងការអនុវត្ត MDGs និងក្នុងដំណើរការត្រួតពិនិត្យនិងវាយតម្លៃ ព្រមជាមួយការយកចិត្តទុកដាក់និងសកម្មភាពថ្មីៗបន្ថែមទៀតត្រូវបានសង្កេតឃើញតាមរយៈអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) របស់អង្គការសហប្រជាជាតិ និងផែនការសកម្មភាពពិការភាពពិភពលោក ឆ្នាំ២០១៤-២០២១ របស់អង្គការសុខភាពពិភពលោក "សុខភាពកាន់តែប្រសើរសម្រាប់ជនពិការទាំងអស់"។[3]

ដោយយោងទៅលើបទពិសោធន៍នៃការដាក់បញ្ចូលពិការភាពទៅក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ការដាក់បញ្ចូលពិការភាពបានបោះជំហានថ្មីមួយទៀតទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs)[4] ដែលមានលក្ខណៈច្បាស់លាស់និងត្រូវបានផ្តល់អាទិភាពជាងមុន។ SDGs មានបំណងបញ្ចប់ភាពក្រីក្រដែលមានកម្រិតខ្ពស់ វិសមភាព ភាពអយុត្តិធម៌ និងដោះស្រាយទៅលើការប្រែប្រួល អាកាសធាតុ សម្រាប់រយៈពេល១៥ឆ្នាំខាងមុខនៅក្នុងប្រទេសទាំងអស់។ បញ្ហាពិការភាពដែលត្រូវបានបញ្ចូលទៅក្នុង SDGs រួមមាន៖

- គោលបំណងទី១៖ ផ្តោតទៅលើ "លុបបំបាត់ភាពក្រីក្រ" ជាការអនុវត្តប្រព័ន្ធការពារសង្គមដែលមានឥទ្ធិពលវិជ្ជមានសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ជាការធានាថាគ្រប់បុរស

[3] "Developing Effective Policies to Reduce Disability from Road Crashes in Cambodia", Socheata Sann, p13

[4] SDGs ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១២ ដោយសន្និសីទអង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍដោយចីរភាពនៅទីក្រុង Rio de Janeiroនិងចាប់ដំណើរការនៅខែកញ្ញា ឆ្នាំ២០១៥ ដែលមានគោលបំណងចំនួន១៧ និងគោលដៅចំនួន១៦៩ សំដៅដល់ការឆ្លើយតបបញ្ហាប្រឈមផ្នែកបរិស្ថាន នយោបាយនិងសេដ្ឋកិច្ចដែលកំពុងប្រឈមនៅលើពិភពលោករបស់យើង។

និងស្ត្រី ជាពិសេសជនក្រីក្រនិងជនងាយរងគ្រោះមានសិទ្ធិស្មើគ្នាចំពោះសកម្មភាពសេដ្ឋកិច្ច ក៏ដូចជាការទទួលបានសេវាមូលដ្ឋាន កម្មសិទ្ធិនិងការគ្រប់គ្រងលើទ្រព្យសម្បត្តិផ្សេងៗ។

- គោលបំណងទី២៖ ផ្តោតទៅលើ "គ្មានភាពអត់ឃ្លាន" ធានាដល់ប្រជាជនគ្រប់រូបជាពិសេសជនក្រីក្រ ជនពិការ ជនងាយរងគ្រោះឱ្យទទួលបានដែលអាហារមានជីវជាតិ និងគ្រប់គ្រាន់។
- គោលបំណងទី៣៖ ផ្តោតទៅលើ "សុខភាពល្អនិងសុខុមាលភាព" សំដៅដល់ការកាត់បន្ថយអត្រាមរណភាពកុមារ ការលើកកំពស់សុខភាពមាតា និងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងផ្សេងៗ ដែលជាកត្តាមួយដែលអាចបណ្តាលឱ្យមានពិការភាព ដោយធ្វើការបង្ការនិងការព្យាបាល ការអប់រំ ការចាក់ថ្នាំការពារ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពបានប្តេជ្ញាចិត្តដើម្បីបញ្ចប់ប្រភេទជំងឺឆ្លងនានានៅឆ្នាំ២០៣០ ជាមួយនឹងវត្ថុបំណងដើម្បីទទួលបាននូវការធានារ៉ាប់រងសុខភាព លក្ខណៈទូទៅនិងផ្តល់លទ្ធភាពទទួលបាន ថ្នាំព្យាបាលនិងវ៉ាក់សាំងការពារ ដែលមានសុវត្ថិភាព និងមានតម្លៃសមរម្យសម្រាប់មនុស្សទាំងអស់។
- គោលបំណងទី៤៖ ផ្តោតទៅលើ "គុណភាពនៃការអប់រំ" ដែលនៅត្រឹមឆ្នាំ២០៣០ អាចលុបបំបាត់វិសមភាព យេនឌ័រក្នុងការអប់រំ និងធានាដល់ការទទួលបានការអប់រំស្មើៗគ្នានិងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនងាយរងគ្រោះរាប់ទាំងជនពិការ ជនជាតិដើមភាគតិចនិងកុមារនៅក្នុងស្ថានភាពងាយរងគ្រោះ។ ព្រមទាំងកសាង និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសសិក្សាដូចជាសម្ភារៈ សុវត្ថិភាព ភាពគ្មានហិង្សាសម្រាប់ជនពិការ និងការផ្តល់អាហារូបករណ៍សម្រាប់ប្រទេសកំពុងអភិវឌ្ឍដែលជនពិការក៏អាចទទួលបាន។
- គោលបំណងទី៨៖ ផ្តោតទៅលើ "ការងារសមរម្យនិងកំណើនសេដ្ឋកិច្ច" បង្កើនផលិតភាពនិងការងារសមរម្យ សម្រាប់ស្ត្រីនិងបុរសទាំងអស់រួមទាំងមនុស្សវ័យក្មេងនិងជនពិការនិងការទទួលប្រាក់ឈ្នួលស្មើគ្នាសម្រាប់ ការងារដែលមានតម្លៃស្មើគ្នា។
- គោលបំណងទី១០៖ ផ្តោតទៅលើ "ការកាត់បន្ថយវិសមភាព" ពង្រឹងនិងលើកកម្ពស់សង្គមបរិយាប័ន្ន សេដ្ឋកិច្ច និងនយោបាយទាំងអស់ដោយមិនគិតពីអាយុ ភេទ ភាពពិការ ពូជសាសន៍ប្រភពដើមសាសនា ឬស្ថានភាពផ្សេងទៀត។
- គោលបំណងទី១១៖ ផ្តោតទៅលើ "ទីប្រជុំជននិងសហគមន៍ចីរភាព" ផ្តល់លទ្ធភាពទទួលបានប្រព័ន្ធដឹកជញ្ជូនដែលមានសុវត្ថិភាព ជាពិសេសតាមរយៈការយកចិត្តទុកដាក់ទៅលើតម្រូវការរបស់អ្នកដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះដូចជាស្ត្រី កុមារ ជនពិការ និងមនុស្សចាស់។
- គោលបំណងទី១៦៖ ផ្តោតទៅលើ "សន្តិភាព យុត្តិធម៌ និងភាពរឹងមាំនៃស្ថាប័ន" បញ្ចប់ការរំលោភបំពាន ការកេងប្រវ័ញ្ច ការជួញដូរ និងគ្រប់ទម្រង់នៃអំពើហឹង្សា និងទារុណកម្ម ដែល

អាចបណ្តាលឱ្យបាត់បង់ជីវិត និងមានពិការភាព។ លើសពីនេះទៀតគឺ ការធានានូវការឆ្លើយតប ការបង្កើតសង្គមបរិយាប័ន្ន និងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កំរិត ព្រមទាំងការលើកកម្ពស់និងអនុវត្តច្បាប់គោលនយោបាយដែលមិនមានការរើសអើង។ ថ្វីបើ SDGs មានគោលដៅសំខាន់ៗទាក់ទងនឹងជនពិការក៏ដោយ ក៏នៅមិនទាន់អាចបង្កើនលទ្ធភាពមួយដ៏ល្អប្រសើរសម្រាប់ជនពិការនៅឡើយទេ ដែលវាទាមទារឱ្យមានការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច នៃប្រទេសនីមួយៗ។

**១.១.២ ពិការភាពនៅកម្ពុជា**

តាមការអង្កេតសេដ្ឋកិច្ចសង្គមឆ្នាំ២០១២ បានបង្ហាញថាអត្រាជនពិការ មានចំនួន៥ភាគរយនៃប្រជាជនសរុប ដែលភាគច្រើននៃជនពិការរស់នៅជនបទ។[5] គិតក្នុងឆ្នាំ២០១៤ ក្នុងចំណោមស្ថាប័ន រដ្ឋប្រមាណ៤០ មានជនពិការកំពុងបម្រើធ្វើការចំនួន២,៤៦០នាក់ ដែលមានតែក្រសួងព្រះបរមរាជវាំងមួយប៉ុណ្ណោះដែលមានករណីលើកលែងក្នុងការទទួលយកជនពិការចូលធ្វើការ។[6] រហូតដល់ឆ្នាំ ២០១៦ នៅតាមក្រសួង ស្ថាប័នរដ្ឋចំនួន៤៣ មានជនពិការបម្រើការងារចំនួន ២,៥៧៦នាក់។[7] ជាមួយគ្នាផងដែរ ក្នុងការអនុវត្តផែនការសកម្មភាពជាតិសម្រាប់ជនពិការរួមទាំងជនរងគ្រោះដោយសារមីន កាកសំណល់សង្គ្រាម (NPA) នៅឆ្នាំ២០១១ កត់សម្គាល់ឃើញថាកុមារនិងមនុស្សពេញវ័យចំនួន៧៨,៧១៤នាក់ (ស្រី៣,៣១៨នាក់) បានចុះឈ្មោះចូលរៀននៅសាលា ហើយយ៉ាងហោចណាស់មានសិស្សដែលពិការភ្នែកចំនួន២៦នាក់ បានកំពុងបន្តបរិញ្ញាបត្រនៅសាកលវិទ្យាល័យ។[8] នៅឆ្នាំ២០១៣ ក្រសួងអប់រំយុវជននិងកីឡា បានផ្តល់អាហារូបករណ៍ដល់សិស្សពិការចំនួន១០,៤៦៩នាក់ (ស្រី៤,៣៨៥)។ ក្រសួងក៏បានសម្របសម្រួលការសិក្សាបច្ចេកទេស ដល់ជនពិការចំនួន៧៨,៩៨៦ (ស្រី ៣៣,១២០នាក់)។[9]

ជាទូទៅ ជនពិការនៅកម្ពុជាមានភាពខ្សោយជារួមគឺភាពខ្សោយផ្នែកគំហើញ ភាពខ្សោយ

---

[5] សៀវភៅណែនាំសម្រាប់គ្រូបង្គោលស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៦, ទំព័រទី១៥

[6] ប្រសាសន៍សម្តេចតេជោហ៊ុន សែនក្នុងពិធីប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពី ពិការភាព ២០១៤-២០១៨ និងអបអរសាទរខួបគម្រប់ ៥ ឆ្នាំ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការនៅសាលមហោស្រពកោះពេជ្រ រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៤

[7] របាយការណ៍សង្ខេបក្នុងសិក្ខាសាលាពិគ្រោះយោបល់ទាក់ទងនឹង *«ការឆ្លុះបញ្ចាំងក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨ ដើម្បីប្រមូលទិន្នន័យយកមកធ្វើការវិភាពអំពីព័ត៌មាននានា និងធ្វើការអភិវឌ្ឍជារបាយការណ៍សង្ខេប»*

[8] "Situation Analysis for Disability-Inclusive Governance and Community Development in Cambodia" 2014, ទំព័រទី១៨

[9] Speech to the 56th Session of the CEDAW by Her Excellency Dr. Ing Kantha Phavi, Minister of Women's Affairs of Cambodia and Head of the Royal Government of Cambodia Delegation, ទំព័រទី៧

ផ្នែករាងកាយ និងការស្តាប់ ហើយភាគច្រើនចាប់ផ្តើមមានភាពខ្សោយក្រោយកំណើត។[10] ដោយប្រទេសកម្ពុជា ជាប្រទេសដែលមានប្រជាជនដ៏ច្រើនលើសលប់កាន់ព្រះពុទ្ធសាសនា ជនពិការជារឿយៗត្រូវបានគេគិតថាជាលទ្ធផលនៃអំពើបាប ទោះជាយ៉ាងនេះក្តីក៏មានកត្តាផ្សេងទៀតដែលមានឥទ្ធិពលទៅលើការយល់ឃើញរបស់មនុស្សអំពីពិការភាព។ វ័យជរា និងជំងឺ គឺជាមូលហេតុទូទៅដែលនាំឱ្យមានភាពខ្សោយ។ មូលហេតុផ្សេងទៀតរួមមានគ្រោះថ្នាក់ដោយសារគ្រាប់មីន ឬការរងរបួសដោយសារសង្គ្រាម គ្រោះថ្នាក់ចរាចរណ៍ និងគ្រោះថ្នាក់ការងារជាដើម។ កត្តាសង្គមដូចជាកង្វះអាហារូបត្ថម្ភ អំពើហិង្សា ក៏ជាចំណែកបណ្តាលឱ្យមានកម្រិតខ្ពស់ក្នុងការរីករាលដាលនៃការចុះខ្សោយខាងបញ្ញាស្មារតីនៅកម្ពុជាផងដែរ[11] ហើយគ្រួសាររបស់ពួកគេប្រឈមនឹងការមាក់ងាយ និងការរើសអើងយ៉ាងខ្លាំងពីមជ្ឈដ្ឋានខាងក្រៅ។

ជនពិការអាចប្រើប្រាស់សិទ្ធិរបស់ពួកគាត់ដោយពេញលេញ និងមានគុណភាពល្អប្រសើរជាងមុន នៅពេលពួកគាត់មានលទ្ធភាពទទួលបានការថែទាំសុខភាព ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬភាពដែលអាចបង្កើតការងារផ្ទាល់ខ្លួន និងការចូលរួមអភិវឌ្ឍសហគមន៍គ្នាដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ យ៉ាងណាមិញ ជនពិការជាពិសេសអ្នកនៅជនបទ និងតំបន់ដាច់ស្រយាលនៅព្រះរាជាណាចក្រកម្ពុជា អាចជួបប្រទះបញ្ហាប្រឈមជាច្រើនក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ រួមមានការរើសអើងនិងអាកប្បកិរិយាអវិជ្ជមានពីសង្គម កង្វះខាតលទ្ធភាពក្នុងការទទួលបានសេវានិងការអប់រំសមស្រប ភាពមិនមានលទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការទទួលបានសេវាសមរម្យចំពោះមនុស្សពេញវ័យនិងកុមារពិការធ្ងន់ធ្ងរផ្នែកផ្លូវចិត្តឬសតិបញ្ញានៅមានកម្រិត និងសេវាកម្មដែលនៅមានកំរិតនៅឡើយសម្រាប់ជនពិការដែលមានវ័យចំណាស់។ ចំណែកឯផ្នែកសុខុមាលភាព និងការចូលរួមរបស់ជនពិការនៅកម្ពុជា ស្ថិតក្នុងភាពមានកម្រិតដោយកង្វះខាតលទ្ធភាពក្នុងការទទួលបានភាពសមស្រប គុណភាព និងតំលៃសមរម្យនៃសេវាកម្មត្រួតពិនិត្យសុខភាពនិងការស្តារនីតិសម្បទា ហើយកត្តាមិនបានកំណត់អត្តសញ្ញាណប័ណ្ណជនពិការពីវ័យក្មេងបានធ្វើឱ្យពួកគាត់បាត់បង់ការជម្រុញនិងការគាំទ្រ ដែលមានប្រសិទ្ធភាពក្នុងការបង្កើនសមត្ថភាពរបស់ពួកគេក្នុងការសិក្សានិងការថែទាំ។[12] ទោះបីមានការផ្តល់អាហារូបករណ៍ក្តី ក៏នៅមានកុមារពិការជាច្រើនមិនចូលសាលារៀន ឬមានអត្រាបោះបង់ការសិក្សាចោលខ្ពស់ជាងកុមារដែលគ្មានពិការភាព ហើយបញ្ហានានាដែលរារាំងកុមារពិការចូលសាលារៀន រួមមាន ការរើសអើង កង្វះខាត

---

[10] សៀវភៅណែនាំស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៦ ទំព័រទី៣១

[11] របាយការណ៍របស់ Centre for International Law and Justice, *Mental Health and Human Rights in Cambodia*, ២០១២ ទំព័រទី១២

[12] Joint Programme Doucument: *Disability Rights Initiative Cambodia* របស់UN, ទំព័រទី១

ឧបករណ៍ជំនួយ ឧបសគ្គខាងរាងកាយ គ្រូបង្រៀនខ្វះវិធីសាស្ត្រក្នុងការបង្រៀន និងតម្រូវការសម្រាប់កុមារដើម្បីជួយជាមួយការងារផ្ទះ។ ហើយជារឿយៗចំណេះដឹងរបស់ឪពុកម្តាយដែលមានកូនពិការនៅមានកម្រិត ដែលធ្វើឱ្យពួកគាត់មិនបានដឹងអំពីអ្វីទៅជាពិការភាពឬសិទ្ធិជនពិការ របៀបចិញ្ចឹមកូនដែលមានពិការភាព ឬកន្លែងដែលត្រូវទៅទទួលការផ្តល់ជំបូន្មាននិងជំនួយ។ ស្ត្រីនិងក្មេងស្រីពិការ អាចប្រឈមមុខនឹងការរើសអើងនិងអាកប្បកិរិយាអវិជ្ជមានក៏ដូចជាទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទច្រើនជាងគេ ហើយមានឱកាសតិចជាងមុនគេក្នុងការទទួលបានការថែទាំសុខភាព ការអប់រំ និងឱកាសការងារទាប។

រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ជីវភាពជនពិការ តាមរយៈការទទួលស្គាល់សិទ្ធិ និងត្រូវបានបង្ហាញតាមរយៈការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) ក្នុងឆ្នាំ២០១២។ ជាបន្តបន្ទាប់គណៈកម្មាធិការសកម្មភាពជនពិការត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៦ នៅឆ្នាំដដែលនោះឈ្មោះត្រូវបានផ្លាស់ប្តូរទៅជាក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC)។ នៅឆ្នាំ២០០៥ គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីការហាមប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សជាតិ បានបង្កើតក្របខណ្ឌមួយ ដើម្បីជួយដល់បណ្តាប្រទេសដែលរងផលប៉ះពាល់ខ្លាំងបំផុត ដែលរួមមានប្រទេសកម្ពុជាផងដែរ។ DAC ក៏បានចាប់ផ្តើមដំណើរការកសាងផែនការសកម្មភាពជាតិសម្រាប់ជនពិការដែលរួមបញ្ចូលជនមានជីវិតបន្ទាប់ពីមានគ្រោះថ្នាក់នៃគ្រាប់មីន ២០០៩-២០១១ (NPA)។ នៅឆ្នាំ២០០៩ ច្បាប់ស្តីពីការលើកកម្ពស់និងការការពារសិទ្ធិរបស់ជនពិការត្រូវបានអនុម័ត (ហៅកាត់ថា "ច្បាប់ពិការភាព")។ ទោះយ៉ាងនេះមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាលក្តី ក៏នៅមានបញ្ហាប្រឈមសំខាន់ៗជាច្រើនក្នុងការអនុវត្ត CRPD[13] ដូចខាងក្រោមៈ

- ខ្វះការបែងចែកច្បាស់លាស់នៃតួនាទីនិងការទទួលខុសត្រូវទៅលើវិស័យពិការភាព
- កម្រិតបទពិសោធន៍តិចតួចនៅក្នុងអង្គភាពរដ្ឋាភិបាលទាំងនេះ
- មានការប្តេជ្ញាចិត្តតិចតួចដើម្បីធានានូវការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់អង្គការមនុស្សពិការ(DPOs) និងអង្គការសង្គមស៊ីវិល
- ការប្រឈមរបស់ MoSVY ក្នុងការសម្របសម្រួលជាមួយក្រសួងផ្សេងទៀត (MoSVY មានធនធានតិចជាងក្រសួងផ្សេងទៀត)
- ការខ្វះខាតទិន្នន័យដែលអាចទុកចិត្តបានអំពីពិការភាព។
- ការបែងចែកមូលនិធិក្នុងកម្រិតទាបរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ធ្វើការទៅលើវិស័យពិការភាព។

[13] Joint Programme Doucument: *Disability Rights Initiative Cambodia* របស់UN, ទំព័រទី៣

បញ្ហាប្រឈមត្រូវបានគិតគូរនិងចាប់ផ្តើមដោះស្រាយជាដំណាក់កាលៗ ដោយរួមមានការអនុម័តនិងពង្រឹងការអនុវត្តលិខិតបទដ្ឋាននានាដែលបានដាក់ចេញ ក្នុងនោះរួមមានផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងអប់រំយុវជននិងកីឡា និងក្រសួងកិច្ចការនារី គោលនយោបាយ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (សម្រាប់កំណើន ការងារសមធម៌និងប្រសិទ្ធភាព) របស់រាជរដ្ឋាភិបាលដែលមាន ផែនការអភិវឌ្ឍន៍និងការគាំពារសង្គមសម្រាប់មនុស្សពេញវ័យនិងកុមារពិការ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP) យុទ្ធសាស្ត្រជាតិគាំពារសង្គមសំរាប់ជនក្រីក្រនិងជនងាយរងគ្រោះ (NSPS) និងគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍន៍កុមារតូចជាអាទិ៍។ ជាពិសេសទាក់ទងនឹងអភិបាលកិច្ចមូលដ្ឋាននិងការអភិវឌ្ឍន៍សហគមន៍ ដោយពិការភាពគឺជាកម្មវិធីជាតិយ៉ាងសំខាន់មួយសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) ឆ្នាំ២០១០-២០១៩ ដែលទទួលស្គាល់នូវតម្រូវការស្មើៗគ្នាសម្រាប់ប្រជាពលរដ្ឋទាំងអស់ចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋានខ្លួន។

## ១.២ អំពីអភិបាលកិច្ច

អភិបាលកិច្ចត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើន អាស្រ័យនឹងស្ថានភាពជាក់ស្តែង។ ជាសាមញ្ញ អភិបាលកិច្ចមានន័យថា គឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ។ ស្រដៀងគ្នានេះដែរ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP1997) បានឱ្យនិយមន័យថា អភិបាលកិច្ចជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស។

### ១.២.១ គោលបំណង និងតួអង្គសំខាន់ៗក្នុងអភិបាលកិច្ច

#### ១.២.១.១ គោលបំណង

គោលបំណងនៃអភិបាលកិច្ច គឺដើម្បីគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងវិបត្តិទាំងឡាយ តាមមធ្យោបាយមួយដែលផ្តល់នូវផលរកប្រយោជន៍យ៉ាងច្រើនបំផុតដល់ប្រជាពលរដ្ឋ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើនេះ គេបានទទួលស្គាល់ជាទូទៅថា អភិបាលកិច្ចទាមទារនូវការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាព។ ចំណុចសំខាន់ៗនៃការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយនិរន្តរភាពរួមមានដូចខាងក្រោម៖

- ត្រូវមានសេវាថែទាំសុខភាពល្អសមស្រប និងគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋទាំងអស់ ដើម្បីជួយឱ្យពួកគេមានសុខភាពមាំមួន និងអាយុយឺនយូរ។ នេះជាកត្តាដែលអាចធ្វើអោយប្រជាពលរដ្ឋមានសុខុមាលភាព និងថាមពលគ្រប់គ្រាន់ ដើម្បីចូលរួមបានយ៉ាងពេញលេញនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម។

- ត្រូវមានសេវាអប់រំល្អ សមស្រប និងគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីឱ្យពួកគេមានចំណេះដឹងនិងជំនាញពេញលេញក្នុងការបង្កើតឱកាសឱ្យបានច្រើននិងសមស្របបំផុត។
- ត្រូវបង្កើតឱកាសសម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីទទួលបាននូវផលប្រយោជន៍ពីសកម្មភាពសេដ្ឋកិច្ច និងមានការងារធ្វើដើម្បីរកប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការជាមូលដ្ឋាន ដូចជាស្បៀងអាហារ សំលៀកបំពាក់ ជម្រកជាដើម សម្រាប់ពួកគេផ្ទាល់ និងក្រុមគ្រួសាររបស់ពួកគេ។

**១.២.១.២ តួអង្គសំខាន់ៗក្នុងអភិបាលកិច្ច**

កាលពីមុនគេយល់ឃើញថាមានតែរដ្ឋាភិបាលមួយគត់ ដែលជាតួអង្គនៃអភិបាលកិច្ច។ ប៉ុន្តែបច្ចុប្បន្ននេះ មានគំនិតថ្មីៗជាច្រើនបានបង្ហាញថា ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀតក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសផងដែរ។ ដូច្នេះតួអង្គសំខាន់ក្នុងអភិបាលកិច្ចមានបីគឺៈ

- រដ្ឋាភិបាល ជាតួអង្គសំខាន់ជាងគេ
- ផ្នែកឯកជន
- សង្គមស៊ីវិល

ឥទ្ធិពលនៃតួអង្គផ្នែកឯកជន និងសង្គមស៊ីវិលមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយអាស្រ័យលើលក្ខខណ្ឌមួយចំនួន ដូចជាប្រព័ន្ធនយោបាយ លក្ខណៈអំណោយផលខាងធនធានធម្មជាតិប្រជាពលរដ្ឋ ទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងកម្រិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច។ល។

ជាក់ស្តែង នៅក្នុងប្រទេសខ្លះ ផ្នែកឯកជន និងសង្គមស៊ីវិលមានអំណាចនិងវិសាលភាពយ៉ាងធំធេង ប៉ុន្តែប្រទេសមួយចំនួនផ្សេងទៀត ផ្នែកឯកជន និងសង្គមស៊ីវិលនេះមានអំណាចឱកាស និងឥទ្ធិពល តិចតួចទៅលើកិច្ចការប្រទេសជាតិ។

**១.២.២ អភិបាលកិច្ចល្អ**

អភិបាលកិច្ចជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ដោយបំពេញបាននូវគោលការណ៍ទាំង៩ខាងក្រោមនេះៈ

**១.២.២.១ ការចូលរួម**

ជាបរិបទអភិបាលកិច្ចល្អ សំដៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស ស្ត្រី ជនពិការ យុវជន និងក្រុមដទៃទៀតក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនោះ។ សារៈសំខាន់នៃការចូលរួម គឺដើម្បីធានាថា ព័ត៌មានទាំងឡាយស្តីពីបញ្ហាតម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ

ត្រូវបានប្រមូលនិងវិភាគបានគ្រប់ជ្រុងជ្រោយមុននឹងធ្វើការសម្រេចចិត្ត។ ជាទូទៅ ការចូលរួមធ្វើឡើងតាម២របៀបគឺៈ

- ការចូលរួមដោយផ្ទាល់ៈ ជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូបដោយខ្លួនឯងនៅក្នុងដំណើរការនៃការសម្រេចចិត្ត និងការអនុវត្តន៍សេចក្តីសម្រេចចិត្តនោះ។
- ការចូលរួមតាមរយៈអ្នកតំណាងៈ បានន័យថា អ្នកតំណាងប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត និងការអនុវត្តន៍សេចក្តីសំរេចនោះ។

**១.២.២.២ នីតិរដ្ឋ**

ក្នុងន័យអភិបាលកិច្ចល្អ ទាមទារឱ្យមានឯកសារក្របខណ្ឌច្បាប់គ្រប់គ្រាន់ ដើម្បីបំរើនិងការពារផលប្រយោជន៍សាធារណៈ ហើយច្បាប់ទាំងនោះត្រូវតែបានអនុវត្តដោយមិនលំអៀង។ លើសពីនេះទៀត ច្បាប់ទាំងនោះត្រូវតែការពារសិទ្ធិមនុស្ស ជាពិសេសក្រុមងាយរងគ្រោះ ឬក្រុមភាគតិច។ ដូច្នេះត្រូវមានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ និងសមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយ។

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អផ្តោតជាសំខាន់ទៅលើៈ

- ឯកសារក្របខណ្ឌច្បាប់
- សមត្ថកិច្ចពង្រឹង ការអនុវត្តន៍ច្បាប់ដោយមិនលំអៀង និងមិនពុករលួយ
- ការការពារសិទ្ធិមនុស្ស
- តុលាការឯករាជ្យ និងយុត្តិធម៌។

**១.២.២.៣ តម្លាភាព**

មានន័យថារាល់ការសម្រេចចិត្ត និងការអនុវត្តន៍សេចក្តីសម្រេចចិត្តនោះត្រូវធ្វើឡើងៈ

- ដោយអនុលោមទៅតាមច្បាប់ និងបទបទបញ្ញាត្តិនានា
- ព័ត៌មានពាក់ព័ន្ធនឹងការសម្រេចចិត្ត និងការអនុវត្តន៍សេចក្តីសម្រេចចិត្ត ត្រូវផ្សព្វផ្សាយជាចំហរ តាមរយៈប្រព័ន្ធសមស្រប និងអាចស្វែងរកបាន ជាពិសេសចំពោះអ្នកដែលទទួលរងគ្រោះនូវផលប៉ះពាល់ពីការសម្រេចចិត្ត និងការអនុវត្តន៍សេចក្តីសម្រេចចិត្តទាំងនោះ។
- ព័ត៌មានទាំងនោះត្រូវតែមានលក្ខណៈគ្រប់គ្រាន់និងងាយយល់។

**១.២.២.៤ ការព្រមព្រៀងឯកភាព**

ការព្រមព្រៀងឯកភាពក្នុងអភិបាលកិច្ចល្អ គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការ

សម្រេចចិត្ត ដោយមានការព្រមព្រៀងឯកភាពគ្នាលើជម្រើស និងវិធីសាស្ត្រល្អណាមួយដែលបម្រើផលប្រយោជន៍រួមសម្រាប់សហគមន៍ទាំងមូល។

**១.២.២.៥ សមធម៌**

សមធម៌នៅក្នុងន័យអភិបាលកិច្ចល្អមានន័យថា ក្រុមឬជនគ្រប់រូបទាំងអស់នៅក្នុងសហគមន៍ ជាពិសេសក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះមានឱកាសគ្រប់គ្រាន់ក្នុងការចូលរួមបញ្ចេញយោបល់លើកឡើងនូវតម្រូវការពិត អនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្រប ដើម្បីកែលម្អនិងថែរក្សាសុខុមាលភាពរបស់ពួកគេ។ សុខុមាលភាព មិនគ្រាន់តែគិតលើផ្នែករូបរាងកាយប៉ុណ្ណោះទេ តែត្រូវគិតដល់ផ្នែកជំនឿ សាសនា ស្មារតី ផ្លូវចិត្ត អារម្មណ៍ ព្រមទាំងភាពគ្រប់គ្រាន់ក្នុងជីវភាពរស់នៅផងដែរ។ សុខុមាលភាពរបស់សមាជិកឬក្រុមនីមួយៗគឺ សុខុមាលភាពរបស់សង្គមទាំងមូល។ លើសពីនេះទៀត ពួកគេមានអារម្មណ៍ថា ខ្លួនគឺជាសមាជិកពិតប្រាកដរបស់សង្គម និងមិនត្រូវបានសង្គមបោះបង់ចោលនោះទេ។

**១.២.២.៦ ប្រសិទ្ធិភាពខ្ពស់**

ជាដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព និងសន្សំ សំចៃខ្ពស់ ដើម្បីបង្កើតលទ្ធផលដែលមានគុណភាពខ្ពស់ បរិមាណច្រើន អាចបម្រើផលប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅតាមតម្រូវការពិតរបស់សង្គម។ គោលគំនិតនៃប្រសិទ្ធិភាពខ្ពស់នៅក្នុងបរិបទអភិបាលកិច្ចល្អក៏បានបញ្ចូលផងដែរ ចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយ និរន្តរភាព និងការការពារបរិស្ថាន។ ដើម្បីអនុវត្តសកម្មភាពឱ្យមានប្រសិទ្ធិភាពត្រូវជៀសវាងការអនុវត្តបែបការិយាធិបតេយ្យ និងគ្មានអំពើពុករលួយ។

**១.២.២.៧ គណនេយ្យភាព**

គណនេយ្យភាពក្នុងន័យអភិបាលកិច្ចល្អ គឺជាការអនុវត្តតួនាទីនិងភារកិច្ចនៅក្នុងដំណើរការ និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វី ដែលខ្លួនបានសម្រេចនិងអនុវត្ត។ គណនេយ្យភាពមិនត្រឹមតែជាការទទួលខុសត្រូវចំពោះអ្នកណាម្នាក់ ដែលបានស្នើសុំឱ្យធ្វើអ្វីមួយនោះទេ ប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាព ដែលបានអនុវត្តចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់ផងដែរ។ មិនមែនមានតែស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ ដែលត្រូវមានគណនេយ្យភាព អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនឯកជនក៏ត្រូវមានគណនេយ្យភាពជាសាធារណៈចំពោះអ្នកដែលពាក់ព័ន្ធទាំងអស់របស់ខ្លួនផងដែរ ពិសេសចំពោះអ្នកដែលទទួលរងផលប៉ះពាល់អំពីការសម្រេចចិត្ត។

#### ១.២.២.៨ ការឆ្លើយតប

ជាការព្យាយាម ខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័ន ដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នា និងមិនរើសអើងនៅក្នុងក្របខណ្ឌពេលវេលាមួយដ៏សមហេតុផល។ ការឆ្លើយតបអាចជាៈ

- ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើសុំ
- ដំណោះស្រាយដែលស្តែងឡើងជាសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាកនានា
- ការឆ្លើយបំភ្លឺអំពីមូលហេតុ ដែលមិនអាចឈានដល់ការធ្វើសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាកទាំងនោះ ព្រមទាំងជម្រាបអំពីសំណើសុំអន្តរាគមន៍នេះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងបញ្ហា ឬការលំបាកទាំងនោះ។

#### ១.២.២.៩. ចក្ខុវិស័យជាយុទ្ធសាស្ត្រ

សំដៅដល់ថ្នាក់ដឹកនាំទាំងអស់និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនៈយ៉ាងទូលំទូលាយ និងរយៈពេលវែងអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្ស ដោយយកចិត្តទុកដាក់អំពីតម្រូវការចាំបាច់នានាដែលត្រូវអភិវឌ្ឍលើការងារនេះ។ លើសពីនេះទៀត គឺត្រូវសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រ វប្បធម៌ ក៏ដូចជាភាពស្មុគស្មាញនៃសង្គមផងដែរ។

## ១.៣ សារសំខាន់នៃការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច

### ១.៣.១ និយមន័យពាក្យគន្លឹះ

- **ជនពិការ**

តាមច្បាប់របស់ប្រទេសកម្ពុជាបានកំណត់ថា "ជនពិការ សំដៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬ សតិបញ្ញាបណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬសកម្មភាពនានាប្រចាំថ្ងៃ ដូចជា ជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងទៀតដែល បណ្តាលឱ្យមានលក្ខណៈមិនប្រក្រតី។"[14] រីឯអនុសញ្ញាអន្តរជាតិវិញបានឱ្យនិយមន័យថា "ជនពិការសំដៅលើអ្នកទាំងឡាយដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទា ផ្លូវចិត្ត សតិបញ្ញា ឬញាណដឹង ដែលនៅពេលជួបប្រទះជាមួយឧបសគ្គនានា អាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គម ដោយស្មើភាពគ្នាជាមួយអ្នកដទៃបាន។"[15]

[14] មាត្រា៤នៃច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ឆ្នាំ២០០៩

[15] មាត្រា១នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ

- **ពិការភាព**

កើតឡើងនៅពេលដែលមនុស្សម្នាក់មានភាពខ្សោយ និងជួបប្រទះឧបសគ្គក្នុងការធ្វើសកម្មភាពអ្វីមួយ។[16] ភាពខ្សោយ គឺជាការបាត់បង់មុខងារណាមួយរបស់រាងកាយ។ រីងឧបសគ្គវិញ ជាគ្រឿងទាំងឡាយដែលមានចរិតរាំងដល់ដំណើរការអ្វីមួយ។

- **ការដាក់បញ្ចូលពិការភាព**

មានន័យថាជនពិការ អាចចូលរួមក្នុងសកម្មភាព គម្រោង និងកម្មវិធីនានាគ្រប់ដំណាក់កាលទាំងអស់ យើងអាចបានថាជាការផ្តល់លទ្ធភាពឱ្យគ្រប់គ្នាបានចូលរួមដោយដកចេញនូវឧបសគ្គទាំងឡាយ។

### ១.៣.២ អត្ថប្រយោជន៍នៃការដាក់បញ្ចូលពិការភាព

ការដាក់បញ្ចូលពិការភាពទៅក្នុងការសម្រេចចិត្តផ្សេងៗ គឺជាកម្លាំងចលករយ៉ាងមានប្រសិទ្ធភាពដែលអាចជំរុញនិងលើកទឹកចិត្តឱ្យជនពិការមានកម្លាំងចិត្ត និងការឱ្យតម្លៃដល់ខ្លួនឯងច្រើនជាងមុន។ បន្ថែមពីលើនេះទៀត បន្តិចម្តងៗពួកគាត់នឹងមានសកម្មភាពយ៉ាងក្លាវក្លាក្នុងសង្គម ដូចជានៅក្នុងផ្នែកសិក្សាអប់រំ ផ្នែកសេដ្ឋកិច្ច ផ្នែកវប្បធម៌ និងផ្នែកនយោបាយជាដើម។ យើងមើលឃើញថា ការដាក់បញ្ចូលបញ្ហាពិការភាពមិនត្រឹមតែផ្តល់ប្រយោជន៍ដល់ជនពិការប៉ុណ្ណោះទេ គឺថែមទាំងដល់សមាជិកគ្រួសាររបស់ជនពិការ និងដល់សង្គមទាំងមូលទៀតផង។ ការគិតគូរពីបញ្ហាពិការសភាពប្រៀបបានទៅនឹងការទំនុកបំរុងក្មេងម្នាក់ដែលតែងតែត្រូវការជំនួយពីអ្នកដទៃ ឱ្យក្លាយទៅជាមនុស្សពេញវ័យដែលមាន អត្តាធិនភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងនិងចាត់ចែងជីវិតផ្ទាល់ខ្លួន។

#### ១.៣.២.១ វិស័យអប់រំ

ការចុះឈ្មោះចូលរៀនដែលជាជំហានទីមួយក្នុងការទទួលបានចំណេះដឹងនិងជំនាញ គឺជាការដាក់ទុនលើកដំបូងនិងដ៏មានសារៈសំខាន់ក្នុងជីវិតមនុស្សម្នាក់ៗ។ យ៉ាងណាមិញ មិនមែនមនុស្សគ្រប់គ្នាសុទ្ធតែមានឱកាសក្នុងការសិក្សារៀនសូត្រ រហូតដល់ចប់ចុងចប់ដើមតាមបំណងប្រាថ្នាខ្លួននោះឡើយ ជាអាទិ៍ជនពិការជាច្រើនមិនបានទទួល ការអប់រំមូលដ្ឋាននៅឯសាលានោះទេ ព្រោះពួកគាត់ត្រូវបានរាំងដោយឧបសគ្គ។ ចំពោះជនពិការ ការចូលរួមក្នុងវិស័យអប់រំអាចនិយាយបានថា ជាគន្លឹះមួយដែលអាចនាំទៅរកការរស់នៅដោយសមរម្យនៅពេលអនាគត។ ភាពដែលជាផ្នែកមួយនៃវិស័យអប់រំអាចធ្វើឱ្យជនពិការទាំងឡាយមានការអភិវឌ្ឍជំនាញ ការបង្កើតបណ្តាញសង្គម ការទទួលយកពិការភាពប្រសើរជាងមុន និងជាពិសេសគឺការកាត់បន្ថយតម្រូវការក្នុងការថែទាំ។ អ្វី

[16] សៀវភៅណែនាំស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ២០១៦ ទំព័រទី២៧

ទាំងនេះនឹងនាំទៅរកបង្កើនការចូលរួមក្នុងវិស័យការងារ សកម្មភាពរកចំណូល និងបង្កើនផលិតភាពកម្លាំងពលកម្ម។ នៅពេលនោះហើយ យើងប្រាកដជាឃើញនូវផលចំណេញដែលបានផ្តល់ឱ្យខ្លួនជនពិការផ្ទាល់ ក្រុមគ្រួសារពួកគាត់ និងសង្គមជាតិ ព្រោះថាការដែលមានលទ្ធភាពក្នុងការប្រកបវិជ្ជាជីវៈឬអាជីពណាមួយ ជាកត្តាចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ហើយរដ្ឋនឹងមានកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង និងកាត់បន្ថយការចំណាយទៅលើកម្មវិធីផ្សេងៗ ដែលមិនសូវចាំបាច់ពាក់ព័ន្ធនឹងជនពិការ។




### ១.៣.២.២ វិស័យសុខាភិបាល

មិនខុសគ្នាទៅនឹងចំណុចអត្ថប្រយោជន៍នៃការដាក់បញ្ចូលពិការភាពក្នុងវិស័យអប់រំប៉ុន្មានទេ ការបញ្ជ្រាបបញ្ហាពិការភាពក្នុងវិស័យសុខាភិបាល ជាហេតុសំខាន់មួយអាចនាំឱ្យមានការសម្រេចនូវផលវិជ្ជមានជាបន្តបន្ទាប់សម្រាប់ជនពិការ។ ភាពខុសគ្នាមុននិងក្រោយពេលដាក់បញ្ចូលដែលយើងអាចឃើញយ៉ាងឆាប់រហ័សនោះគឺ វិសមភាពក្នុងការទទួលបានសេវាត្រូវបានកាត់បន្ថយ និងការលើកកម្ពស់សុខភាពជនពិការមានភាពល្អជាងមុន។ ដូចនេះ ការទទួលបានការយកចិត្តទុកដាក់ក្នុងផ្នែកសុខាភិបាល ជនពិការនឹងមានសុខភាពមាំមួនអាចបំពេញការងារនិងសកម្មភាពប្រចាំថ្ងៃដោយរលូន។




### ១.៣.២.៣ សមធម៌សង្គម និង បរិយាប័ន្ន

សមធមិសង្គម ជាការចាត់វិធានការជាក់លាក់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋរួមបញ្ចូលទាំងក្រុមបាត់បង់ឱកាសនិងក្រុមងាយរងគ្រោះ ដែលរួមមាន ស្ត្រី ជនពិការ ជនជាតិដើមភាគតិច មនុស្សចាស់ កុមារនៃគ្រួសារក្រីក្រជាដើម ដោយធ្វើការដោះស្រាយនូវភាពខុសគ្នានៃតម្រូវការ ការរើសអើង និងការបាត់បង់ឱកាសក្នុងចំណោមក្រុមប្រជាពលរដ្ឋផ្សេងៗគ្នា។ ចំណែកឯបរិយាប័ន្ន គឺជាដំណើរការដែលធានាថាប្រជាពលរដ្ឋគ្រប់រូបអាចចូលរួមបានពេញលេញនៅក្នុងដំណើរការរៀបចំគោលនយោបាយ ផែនការ ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ [17] ទាំងនេះគឺជាយន្តការដែលចូលចំណែកកាត់បន្ថយភាពក្រីក្រនិងវិសមភាពក្នុងសង្គម។ ជាក់ស្តែងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ជនពិការត្រូវបានយកចិត្តទុកដាក់ជាងពេលមុន។ យ៉ាងនេះក្តី តាមរយៈការសង្កេតមើលជនពិការ ដែលចូលរួមនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី៤ របស់អង្គការជនពិការកម្ពុជា បានលើកឡើងថា ជនពិការដែលចូលរួមក្នុងការបោះឆ្នោត នៅតែជួបការលំបាកដូចជា ការិយាល័យបោះឆ្នោតប្រមាណ៧០ភាគរយខ្វះជម្រាល ហិបឆ្នោតនៅខ្ពស់ ការផ្តល់អាទិភាពឲ្យជនពិការនៅមានកម្រិត ឬមិនមានការជួយ

[17] ឯកសារបច្ចេកទេសស្តីពីការលើកកម្ពស់សមធមិសង្គម និងបរិយាប័ន្ននៅថ្នាក់ក្រោមជាតិ ២០១៦, ទំព័រទី៥

សម្រួលដល់ជនពិការជាដើម។ [18] ការណ៍ដែលចាត់វិធានការនៅមានភាពខ្វះចន្លោះ ក្នុងធានាការចូលរួមរបស់ជនពិការក្នុងការបោះឆ្នោតដូចនេះ បានបណ្តាលឱ្យជនពិការមួយចំនួនបោះបង់ការទៅបោះឆ្នោត ដែលបានធ្វើឱ្យសម្លេងជនពិការហាក់មិនសូវជាទទួលបានការចាប់អារម្មណ៍ពីគណបក្សនយោបាយឡើយ។ ផ្ទុយមកវិញ គណបក្សទាំងឡាយច្បាស់ជាគិតគូរអំពីផលប្រយោជន៍ជនពិការយ៉ាងម៉ត់ចត់ បើសិនមានការសម្របសម្រួលកាន់តែប្រសើរជាងនេះ ដែលអាចឱ្យជនពិការដែលមានឈ្មោះបោះឆ្នោតអាចទៅបោះឆ្នោតដោយងាយស្រួលនិងមានទិន្នន័យច្បាស់លាស់។ ហេតុការណ៍ដូចនេះ គឺជាការបញ្ចូលទាំងអស់គ្នាទៅក្នុងការអភិវឌ្ឍ ស្របតាមទិសដៅដែលរាជរដ្ឋាភិបាល បានដាក់ចេញ និងបាវចនានៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព "ពុំទុកអ្នកណាម្នាក់ចោល"។ យ៉ាងណាមិញ យើងមានការរំពឹងវិជ្ជមានក្នុងការដើរទៅរកសង្គមសមធម៌ និង បរិយាប័ន្ន។



Source: DFID, (2002)

[18] កម្មវិធីភៀវប្រចាំថ្ងៃរបស់វិទ្យុបារាំងអន្តរជាតិ, *ឧបសគ្គមួយចំនួននៅតែកើតមានចំពោះជនពិការ ពេលបោះឆ្នោតឃុំសង្កាត់*, ចុះផ្សាយនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៧

# ជំពូកទី២

# ក្របខណ្ឌគាំពារវិស័យពិការភាព

# ជំពូកទី២

# ក្របខណ្ឌគាំពារវិស័យពិការភាព

## ២.១ មូលដ្ឋានគតិយុត្តទាក់ទងនឹងសិទ្ធិជនពិការ

### ២.១.១ ច្បាប់អន្តរជាតិ

ការផ្តល់សច្ចាប័នរបស់របស់រាជរដ្ឋាភិបាលកម្ពុជា ទៅលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) គឺជាការអភិវឌ្ឍន៍យ៉ាងសំខាន់មួយសម្រាប់វិស័យពិការភាពនៅកម្ពុជា ដែលគោលបំណងនៃអនុសញ្ញានេះគឺ "ដើម្បីលើកកម្ពស់ ការពារ និងធានានូវភាពពេញលេញនិងស្មើភាពគ្នានូវសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានរបស់មនុស្សពិការទាំងអស់"។ អនុសញ្ញាស្តីពីសិទ្ធិជនពិការលើកកម្ពស់គំរូសង្គមមួយដែលជនពិការមានសិទ្ធិមនុស្ស មានភាពសកម្មក្នុងការសម្រេចចិត្តទៅលើអ្វីដែលប៉ះពាល់ដល់ការរស់នៅរបស់ពួកគេ និងមានអំណាចដើម្បីទាមទារសិទ្ធិរបស់ពួកគេ។ ចំពោះប្រទេសកម្ពុជាវិញមានកាតព្វកិច្ច បំពេញនូវសិទ្ធិមនុស្សដែលមានស្រាប់ទៅក្នុងបរិបទនៃជនពិការ រួមមានសិទ្ធិស៊ីវិល សិទ្ធិវប្បធម៌ សិទ្ធិសេដ្ឋកិច្ច សិទ្ធិនយោបាយ និងសិទ្ធិសង្គម។ មាត្រាចំនួន៥០របស់អនុសញ្ញាស្តីពីសិទ្ធិជនពិការគ្របដណ្តប់បញ្ហាដូចជាៈ ការបង្កងាយស្រួល សុខភាព ការចល័តផ្ទាល់ខ្លួន សមត្ថភាពនិងការស្តារនីតិសម្បទា ការអប់រំ ការងារ ជីវភាពរស់នៅឱ្យបានគ្រប់គ្រាន់និងការការពារសង្គម ការរស់នៅដោយឯករាជ្យនិងត្រូវបានដាក់បញ្ចូលនៅក្នុងសហគមន៍ ការចូលរួមក្នុងជីវិតវប្បធម៌ ការកម្សាន្តកំសាន្តនិងកីឡា ការចូលរួមក្នុងជីវិតនយោបាយ ការបង្កើនការយល់ដឹង ការប្រមូលទិន្នន័យនិងស្ថិតិ ស្ត្រីពិការ កុមារពិការ សមភាពនិងភាពមិនរើសអើង លទ្ធភាពទទួលបានយុត្តិធម៌ សេរីភាពពីការកេងប្រវ័ញ្ច អំពើហឹង្សានិងការរំលោភបំពាន ស្ថានភាពនៃហានិភ័យនិងការសង្គ្រោះបន្ទាន់ផ្នែកមនុស្សធម៌ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ការអនុវត្តអនុសញ្ញានេះ ផ្តល់នូវឱកាសពង្រឹងក្របខណ្ឌច្បាប់និងគោលនយោបាយជាតិសម្រាប់ពិការភាព និងដើម្បីលើកកម្ពស់ជីវភាពប្រចាំថ្ងៃរបស់ជនពិការដោយផ្អែកលើច្បាប់។

រាជរដ្ឋាភិបាលកម្ពុជាក៏មានកាតព្វកិច្ចអន្តរជាតិផ្សេងទៀតដើម្បីលើកកម្ពស់សិទ្ធិ និងតម្រូវការរបស់មនុស្សពិការពេញវ័យ កុមារពិការ និងជនរងគ្រោះដោយសារគ្រាប់មីននិងសំណល់សង្គ្រាមដែលមានដូចជាៈ[19]

- អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)
- អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី (CEDAW)

[19] "Situation Analysis for Disability-Inclusive Governance and Community Development in Cambodia" 2014, ទំព័រទី៧

- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR)
- អនុសញ្ញាហាមឃាត់មីនប្រឆាំងមនុស្ស (APMBC) ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ កំណត់នូវសិទ្ធិជាមូលដ្ឋានរបស់កុមាររាប់បញ្ចូលទាំងការទទួលបានការថែទាំសុខភាពនិងការអប់រំផងដែរ។ មាត្រា២៣នៃអនុសញ្ញានេះទទួលស្គាល់ថា កុមារដែលមានពិការភាពខាងបញ្ញាឬពិការខាងរូបរាងកាយ ត្រូវមានជីវភាពពេញលេញនិងសមរម្យក្នុងលក្ខខណ្ឌដែលធានាដល់សេចក្តីថ្លៃថ្នូររបស់កុមារ លើកស្ទួយសេចក្តីទុកចិត្តខ្លួនឯងរបស់កុមារនិងសម្រួលឱ្យកុមារចូលរួមយ៉ាងសកម្មក្នុងជីវភាពសហគមន៍ ហើយថាកុមារពិការមានសិទ្ធិក្នុងការទទួលបានការថែទាំនិងការគាំទ្រពិសេស។

ទោះបីជាពិការភាពមិនត្រូវបានលើកឡើងជាក់លាក់នៅក្នុង អនុសញ្ញាCEDAW ឬ កតិកាសញ្ញាអន្តរជាតិ ICESCR ក៏ដោយតែលិខិតូបករណ៍ទាំងពីរនេះមានគោលបំណងលើកកម្ពស់ និងធានាសិទ្ធិស្មើគ្នារវាងស្ត្រីនិងបុរស សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សង្គមស៊ីវិល និងនយោបាយដែលរាប់បញ្ចូលទាំងអ្នកដែលមានពិការភាព។ មួយវិញទៀត រាជរដ្ឋាភិបាលកម្ពុជាធ្វើការរាយការណ៍ជូនគណៈកម្មាធិការ CEDAW អំពីបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងជនពិការ។

ដោយឡែក មាត្រា៦ កថាខណ្ឌ៣ នៃអនុសញ្ញាហាមឃាត់មីនប្រឆាំងមនុស្សជាតិ (APMBC) បានតម្រូវថា "រដ្ឋនីមួយៗដែលមានតួនាទី ត្រូវតែផ្តល់ជំនួយសម្រាប់ការថែទាំនិងការស្តារឡើងវិញ និងការធ្វើសមាហរណកម្មសង្គមនិងសេដ្ឋកិច្ចរបស់ជនរងគ្រោះដោយសារមីន ... " ។ ក្នុងនាមជារដ្ឋភាគី កម្ពុជាបានទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួន ក្នុងការជួយដល់ជនរងគ្រោះដោយសារគ្រាប់មីននិងគ្រួសាររបស់ពួកគេនៅក្នុងបរិបទទូលំទូលាយនៃពិការភាពនិងការអភិវឌ្ឍ។ ចាប់ពីឆ្នាំ ២០១១ ដល់ឆ្នាំ២០១៦ ការបោសសម្អាតមីនក្នុងផ្ទៃដីអាទិភាព ប្រមាណ១០៩លានម៉ែត្រក្រឡាមាន មីនប្រឆាំងមនុស្សចំនួន ២០.២៤០គ្រាប់ មីនប្រឆាំងរថក្រោះចំនួន ៣២៥គ្រាប់ និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន ២៩.៥៥០គ្រាប់ រីឯផែនការរំដោះមីនឲ្យអស់ចេញពីផ្ទៃដីកម្ពុជា របស់រដ្ឋាភិបាលគឺនៅឆ្នាំ២០២៥។[20]

លើសពីនេះទៀត ក្នុងនាមរដ្ឋជាសមាជិកនៃគណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក (UNESCAP) ប្រទេសកម្ពុជាបានអនុម័តយុទ្ធសាស្ត្រអ៊ិនឈាន់ (Incheon Strategy) នៅខែវិច្ឆិកា ឆ្នាំ២០១២ ដែលជាផ្នែកមួយនៃការចាប់ផ្តើមទសវត្សរ៍ទី៣សម្រាប់ជនពិការរបស់អាស៊ីនិងប៉ាស៊ីហ្វិក ឆ្នាំ២០១៣-២០២២។ យុទ្ធសាស្ត្រអ៊ិនឈាន់ បានផ្តល់

[20] គម្រោងបោសសម្អាតមីនក្រោមជំនួយគាំទ្ររបស់រដ្ឋាភិបាលស្វីសដើម្បីសម្រេចបានលទ្ធផលកម្ចាត់មីនជាអតិបរមាលើការអភិវឌ្ឍមនុស្សសម្រាប់សហគមន៍ក្រីក្រក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងប៉ៃលិន។

ជូននូវគោលការណ៍ឯកភាពដំបូងគេសម្រាប់ការដាក់បញ្ចូលពិការភាពទៅក្នុងគោលដៅអភិវឌ្ឍនៅក្នុងតំបន់។

**២.១.២ ច្បាប់ជាតិ**

**២.១.២.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

តាមរយៈច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅឆ្នាំ១៩៩៣ បានបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់។ បន្ថែមពីលើនេះទៀត រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបានលើកឡើងអំពីការគាំទ្រដល់ជនពិការផងដែរ ត្រង់ជំពូកទី៦ ស្តីពីការអប់រំ វប្បធម៌ និងសង្គមកិច្ច មាត្រា៧៤ ចែងថា «រដ្ឋត្រូវជួយឧបត្ថម្ភជនពិការ និងគ្រួសារយុទ្ធជនដែលបានបូជាជីវិត ដើម្បីប្រទេសជាតិ»។

**២.១.២.២ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ**

ប្រទេសកម្ពុជាមានច្បាប់ គោលនយោបាយ និងកម្មវិធីធំៗជាច្រើនដែលទាក់ទងទៅនឹងជនពិការ និងកុមារពិការ។ ច្បាប់ចំបង គឺច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ (ច្បាប់ពិការភាព) ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា នៅខែកក្កដា ឆ្នាំ២០០៩។ គោលបំណងនៃច្បាប់នេះគឺការពារ កាត់បន្ថយ និងលុបបំបាត់ការរើសអើង និងស្តារលទ្ធភាពពលកម្មជនពិការរួមមាន កាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីធានាថាជនពិការ រួមទាំងជនរងគ្រោះដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម អាចចូលរួមយ៉ាងពេញលេញ និងស្មើភាពនៅក្នុងសកម្មភាពសង្គម។ ច្បាប់នេះបានផ្តោតជាសំខាន់ លើជីវភាពរស់នៅ ការស្តារលទ្ធភាពពលកម្មកាយសម្បទា សតិបញ្ញា ការថែទាំសុខភាព និងការបង្ការ ការចេញចូលទីកន្លែងសាធារណៈ ការអប់រំ ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការលើកទឹកចិត្ត ការបោះឆ្នោត ការអនុវត្តសន្ធិសញ្ញា អន្តរជាតិ និង ទោសប្បញ្ញត្តិ ផ្សេងៗ។

នៅក្នុងបរិបទកម្ពុជា ការអនុវត្តច្បាប់ គោលនយោបាយ និងផែនការសកម្មភាព ត្រូវមានការជំរុញបន្ថែមដោយអនុក្រឹត្យ ប្រកាស សារាចរ និងលិខិតបទដ្ឋានផ្សេងៗដទៃទៀត។ យ៉ាងណាមិញដើម្បីលើកកម្ពស់និងបញ្ជ្រាបការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ពិការភាព ក៏ដូចជាការគាំទ្រផ្សេងទៀតសម្រាប់ជនពិការ លិខិតបទដ្ឋានគតិយុត្តិជាច្រើនត្រូវបានបង្កើត និងអនុម័តឡើង។

**២.១.២.៣ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព**

កាលពីឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តផែនការសកម្មភាពជាតិសម្រាប់ជនពិការ រួមទាំងជនរងគ្រោះដោយសារមីន កាកសំណល់សង្គ្រាម ២០០៩-២០១១ (NPA) ដែលស្ថិតក្នុងក្របខ័ណ្ឌនៃកាតព្វកិច្ចរបស់ អនុសញ្ញាហាមឃាត់មីនប្រឆាំងមនុស្សជាតិ។ ផែនការសកម្មភាពជាតិនេះ គ្រប

ដណ្តាប់ លើធាតុសំខាន់ៗចំនួនប្រាំមួយរួមមាន ការយល់ដឹងអំពីទំហំនៃបញ្ហាប្រឈម ការសង្គ្រោះបន្ទាន់និងការថែទាំសុខភាព ការស្តារនីតិសម្បទា ការគាំទ្រផ្លូវចិត្តនិងការធ្វើសមាហរណកម្មសង្គម ការធ្វើសមាហរណកម្ម សេដ្ឋកិច្ច ព្រមទាំងច្បាប់និងគោលនយោបាយសាធារណៈនានា។ នៅកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលជនពិការជាតិនៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ បានឯកភាពចាប់ផ្តើមដំណើរការបង្កើតផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព (NDSP) សម្រាប់ឆ្នាំ២០១៤-២០១៨។

ស្ថិតក្រោមដំណើរការដឹកនាំរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ត្រូវបានបង្កើតឡើងនិងចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីបន្ទាប់ពីមានការអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅខែមិថុនា ឆ្នាំ២០១៤។ ក្រុមប្រឹក្សាសកម្មភាពជនពិការ បានដាក់ឱ្យដំណើរការជាផ្លូវការនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ ២០១៤។ ទោះបីជាយ៉ាងនេះក្តី ក៏មានអ្នកពាក់ព័ន្ធមួយចំនួនបានសម្តែងការព្រួយបារម្ភទៅលើសមាសភាគចូលរួមចំពោះការតាក់តែងគោលនយោបាយនេះផងដែរ។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពត្រូវបានរៀបចំនិងអនុវត្តដោយផ្អែកលើគោលការណ៍ដែលមានចែងក្នុងមាត្រា៣ នៃអនុសញ្ញាសិទ្ធិកុមារ ស្របជាមួយគោលការណ៍ចំនួនបួនក្នុងបរិបទកម្ពុជា៖

- ការពារសិទ្ធិនិងសេរីភាពរបស់ជនពិការ
- ការពារផលប្រយោជន៍របស់ជនពិការ
- ទប់ស្កាត់កាត់បន្ថយនិងបំបាត់ការរើសអើងប្រឆាំងនឹងជនពិការ
- ផ្តល់ការស្តារនីតិសម្បទានិងកាយសម្បទា ដើម្បីធានានូវភាពត្រឹមត្រូវសម្រាប់ការចូលរួមពេញលេញនិងស្មើភាពដោយជនពិការនៅក្នុងសង្គម។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព មានចក្ខុវិស័យ ដាក់បញ្ចូលពិការភាពនៅគ្រប់វិស័យទាំងអស់ ដើម្បីឱ្យជនពិការនិងគ្រួសាររបស់ពួកគេមានគុណភាពជីវិតខ្ពស់ ហើយអាចចូលរួមយ៉ាងសកម្ម និងមានភាពស្មើភាពគ្នានៅក្នុងសង្គម ហើយសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់ពួកគេត្រូវបានគោរព។ រីឯបេសកកម្មវិញគឺ លើកកម្ពស់ការចូលរួមរបស់ស្ថាប័នរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិលក៏ដូចជាដៃគូអភិវឌ្ឍន៍នានាសម្រាប់កិច្ចការសង្គមរួមបញ្ចូលបញ្ហាពិការភាពដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងបេសកកម្មខាងលើគោលដៅនិងគោលបំណងចំនួនប្រាំត្រូវបានកំណត់៖

- បង្កើនជីវភាពរបស់ជនពិការនិងគ្រួសាររបស់ពួកគេ ការគោរពសេចក្តីថ្លៃថ្នូរ និងការរស់នៅដោយឯករាជ្យដែលគិតបញ្ចូលពីសុខុមាលភាព។

- លើកកម្ពស់សមភាពនៅចំពោះមុខច្បាប់និងលទ្ធភាពទទួលបានយុត្តិធម៌ ការរួចផុតពីការធ្វើទារុណកម្មការរំលោភបំពាន ការកេងប្រវ័ញ្ច អំពើហិង្សា និងដំណោះស្រាយក្នុងស្ថានភាពអាសន្ន ក៏ដូចជាសមភាពសម្រាប់ស្ត្រីនិងកុមារដែលមានពិការគ្រប់ប្រភេទ។
- ផ្តល់ការគាំពារសង្គម ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការរកការងារធ្វើ និងសេវាកម្មផ្សេងៗទៀតដល់ជនពិការ។
- ផ្តល់សិទ្ធិអំណាចតាមរយៈការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ជនពិការនៅក្នុងសង្គម។
- បង្កើនជម្រើសនៃការទទួលបានការដឹកជញ្ជូនសាធារណៈនិងគ្រឿងបរិក្ខារ ចំណេះដឹងព័ត៌មាន និងទំនាក់ទំនង។

- ទិសដៅជាយុទ្ធសាស្ត្រចំនួនដប់ដើម្បីសម្រេចគោលដៅនីមួយៗ៖
  - យុទ្ធសាស្ត្រទី១៖ កាត់បន្ថយភាពក្រីក្ររបស់ជនពិការតាមរយៈការបង្កើនការងារដែលសមស្របទៅនឹងជនពិការ ដើម្បីធានាជីវភាពរស់នៅឱ្យបានសមរម្យ និងបង្កើនភាពម្ចាស់ការ។
  - យុទ្ធសាស្ត្រទី២៖ ផ្តល់ជូនជនពិការនូវលទ្ធភាពទទួលបានសេវាសុខាភិបាលដូចគ្នា និងការស្តារនីតិសម្បទានិងកាយសម្បទា។
  - យុទ្ធសាស្ត្រទី៣៖ បង្កើនសេវាយុត្តិធម៌ដើម្បីកាត់បន្ថយការរើសអើង ការរំលោភបំពាន ការធ្វើបាប និងការកេងប្រវ័ញ្ចលើជនពិការ។
  - យុទ្ធសាស្ត្រទី៤៖ ពង្រឹងនិងពង្រីកសេរីភាព សន្តិសុខផ្ទាល់ខ្លួន និងការគ្រប់គ្រងហានិភ័យក្នុងស្ថានភាពគ្រោះមហន្តរាយ។
  - យុទ្ធសាស្ត្រទី៥៖ ធានាថាជនពិការមានសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពនិងសេវាកម្មបណ្តុះបណ្តាលវិជ្ជាជីវៈ។
  - យុទ្ធសាស្ត្រទី៦៖ លើកកម្ពស់ការចូលរួមរបស់ជនពិការក្នុងការបញ្ចេញមតិយោបល់ទទួលព័ត៌មាននិងការចូលរួមក្នុងជីវិតនយោបាយ។
  - យុទ្ធសាស្ត្រទី៧៖ ធានាការចូលរួមក្នុងសកម្មភាពសង្គម ដូចជាវប្បធម៌ សាសនា កីឡាសិល្បៈ ការកម្សាន្តនិងសកម្មភាពផ្សេងៗ។
  - យុទ្ធសាស្ត្រទី៨៖ បង្កើត និងបង្កភាពងាយស្រួលនៃការដឹកជញ្ជូនសាធារណៈនិងគ្រឿងបរិក្ខារ ចំណេះដឹងព័ត៌មាន និងទំនាក់ទំនងសម្រាប់ជនពិការ។
  - យុទ្ធសាស្ត្រទី៩៖ ធានាឱ្យបាននូវសមភាពយេនឌ័រ និងលើកកម្ពស់សមត្ថភាពរបស់ស្ត្រីនិងកុមារពិការ។

- យុទ្ធសាស្ត្រទី១០៖ ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងតំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព មានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលបំណងនៃផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០១៤-២០១៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា។

**២.១.២.៤ យុទ្ធសាស្ត្រនៅរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ**

**ក. យុទ្ធសាស្ត្រនៅរដ្ឋបាលថ្នាក់ជាតិ**

"យុទ្ធសាស្ត្រចតុកោណ" សម្រាប់កំណើនការងារ សមធម៌ និងប្រសិទ្ធភាពដំណាក់កាលទី៣ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអនុម័តនៅខែកញ្ញា ឆ្នាំ២០១៣។ យុទ្ធសាស្ត្រនេះបានលើកឡើងនូវកំណែទម្រង់អាទិភាពក្នុងការការពារសង្គមដូចជា ការកែលម្អក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រការពារសង្គម ដែលរួមមានការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រជាតិគាំពារសង្គមសំរាប់ជនក្រីក្រនិងងាយរងគ្រោះឆ្នាំ២០១១-២០១៥ ការអនុវត្តគោលនយោបាយជាតិស្តីពីពិការភាព ការពង្រឹងការអនុវត្តច្បាប់ស្តីពីពិការភាព និងការលើកកម្ពស់សិទ្ធិនិងសុខុមាលភាពរបស់ជនពិការ (អនុលោមទៅតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ)។ យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ (NSPS) ត្រូវបានអនុម័ត ក្នុងខែមេសា ឆ្នាំ២០១១ ហើយមានបំណងបំពេញបន្ថែមទៅលើគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រ វិស័យដែលមានស្រាប់ពាក់ព័ន្ធនឹងការការពារសង្គមដោយផ្ទាល់ ឬដោយប្រយោល។ យុទ្ធសាស្ត្រនេះមានចក្ខុវិស័យ "ប្រជាជនកម្ពុជា ជាពិសេសជនក្រីក្រនិងជនងាយរងគ្រោះ នឹងទទួលបានផលប្រយោជន៍ពីការបង្កើនសុវត្ថិភាពនិងសន្តិសុខសង្គម ដែលជាផ្នែកសំខាន់នៃប្រព័ន្ធគាំពារសង្គមជាតិប្រកបដោយនិរន្តភាព តំលៃ និងប្រសិទ្ធិភាព" ក្រោមយុទ្ធសាស្ត្រកំណត់អ្នកក្រីក្រនិងជនងាយរងគ្រោះថាជា ជាជនដែលរស់ក្រោមបន្ទាត់នៃភាពក្រីក្រ និងអ្នកដែលមិនអាចទប់ទល់នឹងវិបត្តិឬមានកំរិតខ្ពស់ខិតទៅនឹងការមានវិបត្តិ។ ជនពិការត្រូវបានចាត់ថ្នាក់ក្នុង "ក្រុមងាយរងគ្រោះបំផុត"។ គោលដៅទាំងប្រាំដែលមាននៅក្នុងយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ នឹងធ្វើអោយប្រសើរឡើងនូវគុណភាពនៃជីវិតប្រចាំថ្ងៃរបស់មនុស្សពេញវ័យនិងកុមារពិការនិងគ្រួសាររបស់ពួកគេ៖ 1). ជនក្រីក្រនិងជនងាយរងគ្រោះទទួលបានការគាំទ្រដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានរបស់ពួកគេរួមមានអាហារ ស្បៀង អនាម័យ ទឹក និងទីជម្រកជាដើមនៅក្នុងគ្រាមានអាសន្ននិងវិបត្តិ។ 2). ផលប្រយោជន៍ពីប្រព័ន្ធសុវត្ថិភាពសង្គមនឹងធ្វើអោយកុមារនិងម្តាយក្រីក្រដែលងាយរងគ្រោះ អាចកាត់បន្ថយ ភាពក្រីក្រ អសន្តិសុខស្បៀង និងលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សដោយកែលម្អសុខភាពអាហារូបត្ថម្ភមាតានិងទារក លើកកម្ពស់ការអប់រំ និងលុបបំបាត់ពលកម្មកុមារជាពិសេសទម្រង់ដ៏អាក្រក់បំផុតរបស់ខ្លួន។ 3). ជនក្រីក្រនិង

ជនងាយរងគ្រោះ ទទួលបានអត្ថប្រយោជន៍ពីឱកាសការងារ ដើម្បីធានាប្រាក់ចំណូល ម្ហូបអាហារ និងជីវភាពរស់នៅ ដែលរួមចំណែកដល់ការបង្កើតទ្រព្យសម្បត្តិហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម ប្រកបដោយចីរភាព។ 4). ជនក្រីក្រនិងជនងាយរងគ្រោះអាចទទួលបានការថែទាំសុខភាព ប្រកបដោយគុណភាពខ្ពស់ និងការការពារហិរញ្ញវត្ថុក្នុងករណីមានជំងឺ។ 5). ក្រុមងាយរងគ្រោះពិសេសរួមមានកុមារកំព្រា មនុស្សចាស់ ស្ត្រីដែលមានកូនពិការ ជនដែលផ្ទុកមេរោគអេដស៍ អ្នកជំងឺរបេងនិងជំងឺរ៉ាំរ៉ៃផ្សេងៗទៀតទទួលបានជំនួយខាងផ្លូវចិត្ត និងការថែទាំសង្គម។

នៅក្នុងកម្មវិធីអាទិភាព ត្រង់ចំណុចអភិវឌ្ឍសុខុមាលភាពជនពិការ នៃផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានលើកឡើងពីការប្តេជ្ញាជំរុញការអនុវត្តនូវគោលនយោបាយការពារលើកកម្ពស់សិទ្ធិជនពិការ និងលុបបំបាត់ការរើសអើងចំពោះជនពិការ ព្រមទាំងបង្កឱកាសឱ្យជនពិការបានចូលរួមគ្រប់សកម្មភាពសង្គម តាមរយៈការបន្តនិរន្តរភាពកម្មវិធីស្តារលទ្ធភាពពលកម្មជូនជនពិការដោយឥតគិតថ្លៃ ជំរុញការឧបត្ថម្ភជនពិការនៅតាមសហគមន៍ លើកទឹកចិត្តដល់ការបង្កើតអង្គការជនពិការ លើកទឹកចិត្តចលនាកីឡានិងសិល្បៈក៏ដូចជាបន្តជំរុញការផ្សព្វផ្សាយនិងអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការបន្ថែមលើបទដ្ឋានជាតិដែលមានស្រាប់។

ផែនការយុទ្ធសាស្ត្រស្តីពីសុខាភិបាលរបស់ក្រសួងសុខាភិបាលឆ្នាំ ២០០៨-២០១៥ មានគោលដៅ ដើម្បីកាត់បន្ថយពិការភាពរួមមានការមើលឃើញនិងការស្តាប់ និងដើម្បីបង្កើនលទ្ធភាពទទួលបានការព្យាបាលនិងការស្តារឡើងវិញចំពោះជំងឺមិនឆ្លងដែលរួមមានសុខភាពផ្លូវចិត្ត គ្រោះថ្នាក់និងរងរបួស។ មន្ទីរពេទ្យផ្តល់ជូនការព្យាបាលដោយចលនា និងអ្នកឯកទេសសម្រាប់ការថែទាំទៅលើកំសោយការមើល និងជំងឺផ្លូវចិត្ត។

ក្រសួងអប់រំ យុវជន និងកីឡាមានគោលនយោបាយនិងផែនការដើម្បីធានាថាកុមារទាំងអស់រួមទាំងកុមារពិការមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការរៀនសូត្រដែលមានគុណភាពដោយមិនគិតពីភេទ ទីកន្លែងដែលពួកគេរស់នៅ ឬស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ។ គោលនយោបាយ និងផែនការទាំងនេះមានដូចជា៖ ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៤-២០១៨ បានដាក់ចេញនូវគោលបំណងជាច្រើន ដែលមានរាប់បញ្ចូលទាំងជនពិការផងដែរ ដោយមានគូសបញ្ជាក់អំពីគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពជាក់ស្តែង ទាក់ទងនឹងកុមារពិការមានដូចជា បង្កើនការចុះឈ្មោះចូលរៀនរបស់ក្មេងចាប់ពីអាយុ០ដល់ក្រោម៦ឆ្នាំ ជាពិសេសសម្រាប់ជនក្រីក្រ ជនជាតិភាគតិច និងកុមារពិការ ហើយនិងធានាថាកុមារដែលគ្រប់អាយុចូលរៀនបានចុះឈ្មោះចូលរៀន និងចំនួនប្រហាក់ប្រហែលគ្នានេះត្រូវបានបន្តរហូតដល់ឆ្នាំបញ្ចប់នៃឆ្នាំការសិក្សា។ ការឆ្លើយតបមួយក្នុង

ចំណោម ការឆ្លើយតបនានាក្នុងផែនការនេះ គឺដើម្បីចាត់វិធានការកាត់បន្ថយចំនួនកុមារក្រៅសាលា ជាមួយនឹងការផ្តោតយកចិត្តទុកដាក់លើកុមារពិការ រួមមានការពង្រីកកម្មវិធី អប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ ជាពិសេសតាមសាលាមត្តេយ្យ និងផ្តល់ការគាំទ្រដល់កុមារពិការ តាមរយៈការពិនិត្យ និងការផ្តល់ឧបករណ៍ជំនួយនានា។ គោលនយោបាយជាតិស្តីពីការថែទាំកុមារដំបូង (ECCD) ដែលធ្វើឡើងដើម្បីធានាថាគ្មានបញ្ហាកង្វះអាហារូបត្ថម្ភ កង្វះទម្ងន់ និងការមានសុខភាពមិនល្អដែលនាំអោយពុំមានសមត្ថភាពក្នុងការរៀនសូត្រឱ្យបានល្អ ជាមួយគោលដៅ "ដើម្បីពង្រីកសេវាថែទាំសុខភាពនិងព្យាបាលជំងឺសម្រាប់ទារកទាំងអស់ចាប់ពីកំនើតដល់អាយុ៣ឆ្នាំ ដោយមានការពិនិត្យ សុខភាពជាទៀងទាត់ ការផ្តល់ការចាក់ថ្នាំបង្ការ និងការតាមដានទៅលើការផ្តល់អាហារូបត្ថម្ភ។" ក្រៅពីនេះទៀត គេឃើញ ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច (២០១៤-២០១៨) ដែលមានគោលបំណងអភិវឌ្ឍកុមារតូចពហុវិស័យបញ្ចូលគ្នា ដោយក្នុងនោះក៏មានផ្តោតលើ ការអភិវឌ្ឍន៍ផ្នែកសង្គមនិងអារម្មណ៍ និងផ្នែកបញ្ញាព្រមជាមួយការគិតដល់កុមារពីគ្រួសារក្រីក្រ និងកុមារមានពិការភាពផងដែរ។

ផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ក្រសួងកិច្ចការនារី ២០០៩-២០១៣ (នារីរតនៈទី៣) រួមបញ្ចូលទាំងស្ត្រីនិងកុមារីដែលមានពិការភាព ជាក្រុមគោលដៅជាក់លាក់មួយនៅក្នុងផ្នែកនៃការផ្តល់ អំណាចសេដ្ឋកិច្ចនិងការអប់រំ។ ផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៤-២០១៨ ក៏មានបញ្ចូលស្ត្រីនិងក្មេងស្រីដែលមានពិការភាពផងដែរ។ ផែនការសកម្មភាពជាតិរបស់ក្រសួងកិច្ចការនារីដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី២០១៣-២០១៧ កំណត់ថាស្ត្រីពិការមានហានិភ័យខ្ពស់ក្នុងទទួលរងអំពើហឹង្សាដែលទាមទារឱ្យមានការទប់ស្កាត់ពិសេស។

### ខ. យុទ្ធសាស្ត្ររដ្ឋបាលថ្នាក់ក្រោមជាតិ

កម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (NP-SNDD) ឆ្នាំ ២០១០-២០១៩ ត្រូវបានអនុម័តក្នុងខែឧសភា ឆ្នាំ២០១០ ដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រ វិមជ្ឈការនិងវិសហមជ្ឈការ ច្បាប់ស្តីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងកិច្ចការរដ្ឋបាលឃុំ សង្កាត់។ សម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (NP-SNDD) កត់សម្គាល់ថា "មានតម្រូវការឱកាសស្មើគ្នាសំរាប់ប្រជាពលរដ្ឋទាំងអស់ក្នុងការចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន និងទាមទារឱ្យមានសេវាកម្មសាធារណៈកាន់តែប្រសើរ និងកាន់តែទូលំទូលាយ ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋដែលនាំឱ្យមានការកាត់បន្ថយភាពក្រីក្រនិងផ្តោត លើក្រុមងាយរងគ្រោះ ជាពិសេសជនជាតិភាគតិច ស្ត្រី និងកុមារ"។ គោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

នៅថ្នាក់ក្រោមជាតិគឺ បង្កើតវប្បធម៌ចូលរួមតាមបែបលទ្ធិប្រជាធិបតេយ្យ បង្កើនគណនេយ្យភាពចំពោះប្រជាពលរដ្ឋ កែលម្អសេវាសាធារណៈនិងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។ កម្មវិធីបានបញ្ជាក់ថា ការផ្តល់សេវាសាធារណៈ មធ្យោបាយសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន គឺជាផ្នែកសំខាន់មួយនៅក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានគេផ្ទេរមុខងារ រួមជាមួយធនធានគ្រប់គ្រាន់ដើម្បីឱ្យពួកគេអាចផ្តល់សេវាកម្មសាធារណៈ សម្ភារៈចាំបាច់ និងហេដ្ឋារចនាសម្ព័ន្ធដល់មូលដ្ឋានរបស់ពួកគាត់។ ទោះបីជាមិនមានការដាក់បញ្ចូលបញ្ហាពិការភាពដោយផ្ទាល់ក៏ពិតមែន មនុស្សពេញវ័យនិងកុមារពិការ គឺស្ថិតក្នុងក្រុមងាយរងគ្រោះ។ ការលើកកម្ពស់ការអភិវឌ្ឍដែលរួមបញ្ចូលពិការភាព ដើម្បីធ្វើឱ្យប្រសើរឡើងនូវការរស់នៅប្រចាំថ្ងៃរបស់ជនពិការ និងគ្រួសាររបស់ពួកគេ គឺមានបញ្ចូលទៅក្នុងផែនការវិនិយោគឃុំសង្កាត់ និងផែនការអភិវឌ្ឍឃុំ សង្កាត់។

នៅថ្នាក់ក្រោមជាតិ គឺមានអនុក្រឹត្យស្តីពីគោលនយោបាយគាំទ្រជនពិការក្នុងសហគមន៍ ដែលអនុក្រឹត្យនេះមានបំណង៖

- ដាក់បញ្ចូលបញ្ហាពិការភាពក្នុទៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ និងគោលនយោបាយផ្សេងៗទៀត ដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ
- ផ្តល់សេវាសង្គ្រោះបន្ទាន់សម្រាប់ជនពិការនៅក្នុងសហគមន៍
- ស្តារនិងលើកកម្ពស់ជីវភាពរស់នៅរបស់ជនពិការនៅក្នុងសហគមន៍
- ទប់ស្កាត់និងកាត់បន្ថយចំណាកស្រុករបស់ជនក្រីក្រដែលមានពិការភាព
- កាត់បន្ថយភាពក្រីក្រនិងការសុំទានពីសំណាក់ជនពិការនៅតាមដងផ្លូវ
- ផ្តល់សេវាសុខុមាលភាពសង្គមដល់ជនក្រីក្រដែលមានពិការភាពប្រកបដោយប្រសិទ្ធភាព។

ទោះបីជាមានក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាច្រើនដែលអាចលើកកម្ពស់សិទ្ធិស្ត្រី កុមារ និងបុរសដែលមានពិការភាពក្តី ក៏បញ្ហាប្រឈមជាច្រើននៅតែមាន។ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព បានធ្វើការគូសបញ្ជាក់ពីភាពទន់ខ្សោយជាច្រើនរួមមាន ការផ្សព្វផ្សាយច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្តារឡើងវិញនូវនីតិសម្បទានៅមិនទាន់មានភាពទូលំទូលាយនៅឡើយ ការអនុវត្តគោលនយោបាយច្បាប់ផែនការជាតិនិងបទប្បញ្ញត្តិទាក់ទងនឹងពិការភាពនិងការស្តារនៅមាន កម្រិត កង្វះធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ និងការរើសអើងជនពិការនៅតែមាន។ អ្នកជំនាញក៏បានគូសបញ្ជាក់អំពីបញ្ហាផ្សេងៗទៀត ដូចជាអាជ្ញាធរថ្នាក់ក្រោមជាតិមិនបានចាត់ថ្នាក់បញ្ហាពិការភាពជាអាទិភាព ការយល់ដឹងទៅលើច្បាប់ស្តីពីពិការភាព និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀតនៅថ្នាក់ក្រោមជាតិគឺនៅមានកម្រិត កង្វះធនធានមនុស្ស

និងបច្ចេកទេសដើម្បីអនុវត្តច្បាប់និងគោលនយោបាយ និងភាពមានកម្រិតនៃការដាក់បញ្ចូលពិការភាពទៅក្នុងការធ្វើផែនការ។[21]

## ២.២ តួអង្គពាក់ព័ន្ធ និងសេវាកម្មទាក់ទងវិស័យពិការភាព

### ២.២.១ តួអង្គពាក់ព័ន្ធ

### ២.២.១.១ ក្រសួង និងស្ថាប័នរដ្ឋាភិបាល

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ជាអ្នកទទួលខុសត្រូវធំជាងគេក្នុងការធានាសុខុមាលភាព និងលើកស្ទួយកម្រិតជីវភាពរបស់ជនពិការ ក៏ដូចជាក្រុមងាយរងគ្រោះដទៃទៀត។ នាយកដ្ឋានសុខុមាលភាពជនពិការ (DWPD) ត្រូវបានបង្កើតឡើងដើម្បីដឹកនាំនិងគ្រប់គ្រងការងារដែលទាក់ទងនឹងពិការភាព។ កម្មវិធីការពារកុមាររបស់ UNICEF ផ្តល់ការគាំទ្រដល់ DWPD ដើម្បីលើកកម្ពស់និងសម្របសម្រួលកិច្ចការស្តារនីតិសម្បទា។ តួនាទីរបស់ DWPD រួមមាន៖ បង្កើតគោលនយោបាយ ច្បាប់និងក្របខ័ណ្ឌច្បាប់ផ្សេងៗទៀតដែលទាក់ទងទៅនឹងសុខុមាលភាពរបស់ជនពិការ លើកកម្ពស់និងត្រួតពិនិត្យលើការអនុវត្តប្រកប ដោយប្រសិទ្ធិភាពនៃច្បាប់ស្តីពីពិការភាព លើកកម្ពស់ការអនុវត្តសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធ នឹងពិការភាព រៀបចំផែនការសកម្មភាពសម្រាប់ការស្តារនីតិសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងដោះស្រាយការងារជូនជនពិការ បច្ចេកទេសសម្របសម្រួលពិការភាព សិល្បៈនិងកីឡា និងរៀបចំទិវាជាតិនិងទិវាកីឡាកម្ពុជាសម្រាប់ជនពិការ។
- ក្រុមប្រឹក្សាសកម្មភាពជនពិការ គឺជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាពិការភាព។[22] ក្រោយពីច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការបានចូលជាធរមាននៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ក្រុមប្រឹក្សាសកម្មភាពជនពិការមានតួនាទី៖ ១)ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម ២)ជួយ ក្រសួងស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការរៀបចំគោលនយោបាយ ផែនការជាតិនិងយុទ្ធសាស្ត្រដែល មានការពាក់ព័ន្ធទៅនឹង ពិការភាព និង

---

[21] "Situation Analysis for Disability-Inclusive Governance and Community Development in Cambodia" 2014, P11-12

[22] បង្កើតឡើងដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ក្នុងច្បាប់ស្តីពី កិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ។ ដើមឡើយ ក្រុមប្រឹក្សាសកម្មភាពជនពិការ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ ១៩៩៩ ដោយប្រកាសលេខ ៣០៨ ស.ក.ប.យ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (MOSALVY)និងអន្តរក្រសួង ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិចំនួន៥ផ្សេងទៀតរួមមានCT, HIF, NCDP, JRS, និង CDPO។

ការស្តារលទ្ធភាពពលកម្ម ៣)ជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធ និង បញ្ហាពិការភាព និងស្តារ លទ្ធភាពពលកម្ម ៤) លើកសំណើកែសម្រួលបំពេញបន្ថែម ធ្វើវិសោធនកម្មគោលនយោបាយ ច្បាប់ និង បទបញ្ញាផ្សេងៗពាក់ព័ន្ធ និងបញ្ហាពិការភាព ៥) តាមដានវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់និងបទបញ្ញា ផ្សេងៗពាក់ព័ន្ធនិងបញ្ហាពិការភាព ៦) ទំនាក់ទំនងជាមួយសហគមន៍ជាតិអន្តរជាតិ ដើម្បីផ្លាស់ប្តូរបទ ពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុងនិងក្រៅប្រទេស។ ក្រុមប្រឹក្សាសកម្មភាពជនពិការមានសមាសភាពតំណាងពីក្រសួងស្ថាប័នជាច្រើន ក្នុងនោះមានក្រសួងចំនួន៥ដែលត្រូវបានគេស្គាល់ថា កំពុងដោះស្រាយបញ្ហាពិការភាព និងផ្តល់សេវាសម្រាប់មនុស្សពេញវ័យនិងកុមារពិការៈ

1. ក្រសួងពាណិជ្ជកម្ម តាមរយៈវិទ្យាស្ថានជាតិស្ថិតិដែលទទួលខុសត្រូវក្នុងការប្រមូលទិន្នន័យពាក់ព័ន្ធនឹងពិការភាព។
2. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់វគ្គបណ្តុះបណ្តាលដល់ប្រជាជនទាំងអស់ និងបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជាង៣០កន្លែង ដើម្បីផ្តល់ការប្រឹក្សាការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រុមគោលដៅរួមមានស្ត្រីក្រីក្រ ក្រុមងាយរងគ្រោះ និងជនពិការ។
3. ក្រសួងអប់រំយុវជននិងកីឡា បានបង្កើតនិងអនុវត្តគោលនយោបាយ ផែនការនានាដើម្បីលើកកម្ពស់ការអប់រំកុមារនិងមនុស្សពេញវ័យដែលមានពិការភាព។
4. ក្រសួងសុខាភិបាល ផ្តល់សេវាថែទាំសុខភាពដល់ប្រជាជនទាំងអស់រួមទាំងជនពិការ។
5. ក្រសួងកិច្ចការនារី បានលើកកម្ពស់សិទ្ធិរបស់ស្ត្រីរាប់បញ្ចូលទាំងស្ត្រីពិការ តាមរយៈការផ្តល់អំណាចសេដ្ឋកិច្ច និងការទទួលបានការអប់រំ។ ក្រសួងកិច្ចការនារីក៏ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីចំនួន១៣កន្លែង និងជំនួយឥតសំណងខ្នាតតូចសម្រាប់ការចាប់ផ្តើមអាជីវកម្ម។

- គណៈកម្មាធិការជាតិសម្របសម្រួលពិការភាព(NDCC) ដោយមានក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាជាប្រធាន គណៈកម្មាធិការជាតិសម្របសម្រួលពិការភាពទទួលបន្ទុកពិនិត្យតាមដាន និងវាយតម្លៃ សម្របសម្រួល និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។
- មូលនិធិជនពិការ(PWDF) [23] ដែលទទួលខុសត្រូវទទួលខុសត្រូវចំពោះ ១)សេវាផ្តល់ប្រាក់កម្ចីសម្រាប់ជនពិការសម្រាប់ផ្នែកសុខភាព ការស្តារនីតិសម្បទា និងការអប់រំ។ ២)

[23] បង្កើតឡើងតាមស្មារតីតាមរយៈមាត្រា៤៦ នៃច្បាប់ស្តីពីពិការភាព

ការលើកកម្ពស់សុខុមាលភាពរបស់ជនពិការរួមជាមួយអ្នកក្រនិងអ្នកដែលមិនទទួលបានសេវាកម្មនិងការគាំទ្រ។ ៣)ផ្តល់ឥណទានដើម្បីឱ្យជនពិការមានកន្លែងស្នាក់នៅសមស្រប។

- ដោយរាជរដ្ឋាភិបាលបានប្រគល់តួនាទីដល់ក្រសួងមហាផ្ទៃក្នុងការធ្វើកំណែទម្រង់វិមជ្ឈការក្រសួងនេះ ស្ថិតក្នុងបរិបទយ៉ាងសំខាន់មួយក្នុងការការដាក់បញ្ចូលបញ្ហាពិការភាពនៅក្នុងការសម្រេចចិត្តរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គឺជាប្រធានគណៈ-កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (NCDD) ដែលជាយន្តការអន្តរក្រសួងកម្រិតខ្ពស់ មានគណនេយ្យភាពចំពោះការអនុវត្តច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន (CMAA)[24] មានភារកិច្ចសម្របសម្រួល និងត្រួតពិនិត្យជំនួយដល់ជនរងគ្រោះដោយគ្រាប់មីន ការប្រមូលទិន្នន័យ ការបញ្ជូននិងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិនិងតម្រូវការរបស់អ្នកនៅរស់រានមានជីវិតដោយសារមីន។
- អង្គការជនពិការកម្ពុជា (CDPO) [25] ដើរតួយ៉ាងសំខាន់ក្នុងនាមជាអ្នកអប់រំក្នុងសហគមន៍សម្រាប់ការលើកកម្ពស់សិទ្ធិរបស់ជនពិការ និងអនុវត្តសកម្មភាពនិងការកសាងសមត្ថភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ តាមរយៈការបង្កើតក្រុមជួយខ្លួនឯងនៅថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់ខេត្ត ដោយធ្វើការជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាខណ្ឌនិងខេត្ត ដើម្បីលើកកម្ពស់ការយល់ដឹងនិងលើកកម្ពស់ការបញ្ចូលជនពិការក្នុងដំណើរការរៀបចំផែនការ។
- អង្គការផ្សេងទៀតដែលធ្វើការជាមួយជនពិការៈ សមាគមពិការភ្នែកកម្ពុជា (ABC) ជាអង្គការជនពិការជាតិតែម្នាក់គត់ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ គឺជាសមាជិកនៃសហភាពពិការភ្នែកពិភពលោកនិងក្រុមប្រឹក្សាអន្តរជាតិសម្រាប់ការអប់រំភាពខ្សោយផ្នែកគំហើញ។ មជ្ឈមណ្ឌលសម្រាប់ការរស់នៅដោយឯករាជ្យ (PPCIL) គាំទ្រដល់សិទ្ធិរបស់ជនពិការនិងផ្តល់សិទ្ធិអំណាចដល់ពួកគេតាមរយៈការផ្តល់ជំនួយនិងការប្រឹក្សាដើម្បីលើកទឹកចិត្តដល់ការរស់នៅឯករាជ្យនៅក្នុងសហគមន៍។

[24] ដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជានៅខែកញ្ញាឆ្នាំ២០០០

[25] CDPO បង្កើតឡើងក្រោមត្រូវបានមហាសន្និបាតជាតិនៅឆ្នាំ 1995។ ក្នុងឆ្នាំ២០០១ CDPO ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា។ នៅថ្ងៃទី 15 ខែមីនាឆ្នាំ 2010 CDPO បានទទួលលិខិតអនុញ្ញាតមួយពីក្រសួងមហាផ្ទៃដើម្បីធ្វើការជាមួយក្រុមប្រឹក្សាឃុំចំនួន 46 នៅក្នុងខេត្តចំនួន 23 ក្នុងប្រទេសកម្ពុជា។

**២.២.១.២ អាជ្ញាធរថ្នាក់ក្រោមជាតិ**

- ក្រុមប្រឹក្សាពិការភាពថ្នាក់ខេត្ត គាំទ្រដល់ការអនុវត្តអនុក្រឹត្យស្ដីពីគោលនយោបាយគាំទ្រជនពិការក្នុងសហគមន៍ ដែលមានអភិបាលរងខេត្តជាសមាជិករបស់ DAC ។
- ក្រុមប្រឹក្សាឃុំ សង្កាត់ទទួលខុសត្រូវក្នុងការលើកកម្ពស់និងគាំទ្រអភិបាលកិច្ចល្អ ដោយគ្រប់គ្រងនិងប្រើប្រាស់ធនធានប្រកបដោយនិរន្តភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានរបស់សហគមន៍រួមមានទឹកស្អាតនិងអនាម័យ ការកសាងនិងជួសជុលផ្លូវ សេវាសុខភាព និងការអប់រំ។ សកម្មភាពរបស់ក្រុមប្រឹក្សាភាគច្រើនពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំផែនការអភិវឌ្ឍនិងផែនការវិនិយោគ។ កម្រិតនៃការយល់ដឹងអំពីពិការភាពក្នុងចំណោមក្រុមប្រឹក្សាមានលក្ខណៈខុសគ្នាខ្លាំងអាស្រ័យលើសកម្មភាពអង្គការមិនមែនរដ្ឋាភិបាលឬអង្គការជនពិការមាននៅក្នុងឃុំ សង្កាត់។ មានមេឃុំ ចៅសង្កាត់មួយចំនួនតូចមានការលើកទឹកចិត្តខ្ពស់និងចូលរួមក្នុងបញ្ហានេះ ប៉ុន្តែបញ្ហាប្រឈមគឺទាក់ទងធនធានហិរញ្ញវត្ថុដែលមានកំណត់ដើម្បីអនុវត្តសកម្មភាពការដាក់បញ្ចូលពិការភាព និងចំណេះដឹងតិចតួចអំពីសេវាកម្មដែលអាចរកបាននិងកន្លែងដែលត្រូវបញ្ជូនមនុស្សពិការនៅពេលមានតម្រូវការ។[26]
- ប្រធានភូមិក៏ដើរតួយ៉ាងសំខាន់នៅថ្នាក់ក្រោមជាតិផងដែរ ដោយសារតែពួកគេជាធម្មតាមានទំនាក់ទំនងល្អជាមួយប្រជាជនមូលដ្ឋាន ដើម្បីដឹងពីស្ថានភាពរបស់ជនពិការក្នុងភូមិដែលពួកគេរស់។ ប្រធានភូមិ មានការទទួលខុសត្រូវក្នុងការបង្ហាញអំពីបញ្ហាសំខាន់ៗទាក់ទងនឹងភូមិទៅក្រុមប្រឹក្សាឃុំសង្កាត់ក្នុងដំណើរការរៀបចំផែនការដើម្បីបញ្ចូលទៅក្នុងផែនការអភិវឌ្ឍនិងផែនការវិនិយោគ។

**២.២.១.៣ ភ្នាក់ងារអន្តរជាតិ**

- អង្គការពលកម្មអន្តរជាតិ (ILO) គឺជាដៃគូយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ហើយដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយស្តារជីវភាពរស់នៅបង្កើតការងារប្រកបដោយនិរន្តរភាព។ កន្លងមកអង្គការ ILO បានចូលរួមយ៉ាងសកម្មក្នុងវិស័យពិការភាពតាមរយៈការអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្រ វគ្គបណ្តុះបណ្តាលមិត្តអប់រំមិត្តជាដើម។
- ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNOHCHR) ផ្តល់ជំនួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់ និងគោរពសិទ្ធិមនុស្សរាប់

[26] "Situation Analysis for Disability-Inclusive Governance and Community Development in Cambodia" 2014, ទំព័រទី 24

បញ្ចូលទាំង សិទ្ធិជនពិការ។ UNOHCHR បានផ្តល់ការគាំទ្រក្នុងដំណើរការផ្តល់សច្ចាប័នរបស់ CRPD រួមទាំងការផ្តល់ដំបូន្មានលើសេចក្តីព្រាងសេចក្តីថ្លែងការណ៍នៃការផ្តល់សច្ចាប័នដែលបានដាក់ជូនសភា។

- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ធ្វើការដើម្បីលើកកម្ពស់សមត្ថភាពរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល សមធម៌និងគណនេយ្យភាព ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យដែលមានការចូលរួមជាមួយសង្គមស៊ីវិល ការបង្កើតបរិយាកាសងាយស្រួល សម្រាប់ការដាក់បញ្ចូលការអភិវឌ្ឍវិស័យឯកជន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ផ្នែកសំខាន់ៗពីរនៃការងាររបស់ UNDP មានជាប់ទាក់ទងក្នុងការលើកកម្ពស់គុណភាពជីវិតប្រចាំថ្ងៃរបស់ជនពិការ មានដូចជាកាត់បន្ថយ ភាពក្រីក្រ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។
- អង្គការយូនីសេហ្វកម្ពុជា (UNICEF) មានប្រវត្តិការងារយូរជាមួយរាជរដ្ឋាភិបាលដើម្បីកសាងសមត្ថភាព និងបង្កើនលទ្ធភាពទទួលបានសេវា។ កម្មវិធីឆ្នាំ២០១១-២០១៥ ធ្វើការដើម្បីលើកកម្ពស់បរិស្ថានដែលមានសុខភាពល្អនិងស្អាតស្អំ និងការការពារកុមារអាចលូតលាស់និងឈានដល់សក្តានុពលពេញលេញរបស់ពួកគេ។ ផ្នែកកម្មវិធីចំនួនប្រាំពីរផ្តោតលើការការពារកុមារ ការអប់រំ សុខភាពនិងអាហារូបត្ថម្ភ ជម្ងឺអេដស៍ អភិបាលកិច្ចមូលដ្ឋាន ការការពារសង្គមនិងទឹកស្អាតមានអនាម័យ (WASH) ដែលតំបន់កម្មវិធីទាំងអស់ពាក់ព័ន្ធនឹងការធានាសិទ្ធិ និងការដោះស្រាយតម្រូវការរបស់មនុស្សដែលមានពិការភាព ជាពិសេសស្ត្រីនិងកុមារ។
- យុទ្ធសាស្ត្រសហប្រតិបត្តិការរបស់អង្គការសុខភាពពិភពលោកសម្រាប់ឆ្នាំ ២០០៩-២០១៩ គូសបញ្ជាក់នូវវិស័យអាទិភាពចំនួនបី គឺឧត្តមភាពផ្នែកបច្ចេកទេសក្នុងកម្មវិធីជំងឺនិងសុខភាពសាធារណៈ លទ្ធភាពទទួលបានសេវាសុខភាពដែលមានគុណភាព និងការថែទាំប្រកបដោយ ប្រសិទ្ធភាពនៃវិស័យសុខាភិបាល។ ទាំងនេះមានសក្តានុពលក្នុងការលើកកម្ពស់សុខភាពនិងសុខុមាលភាពរបស់ជនពិការនៅកម្ពុជា។

**២.២.១.៤ អង្គការក្រៅរដ្ឋាភិបាល**

សេវា សម្រាប់មនុស្សពេញវ័យនិងកុមារពិការនៅកម្ពុជាភាគច្រើនត្រូវបានផ្តល់ឬគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល និងCDPO។ ការប្រមូលផ្តុំប្រភពផ្សេងៗគ្នា រាប់បញ្ចូលទាំងគម្រោងផែនទីទិន្នន័យពិការភាពរបស់ CDPO និងកូនសៀវភៅសេវាសម្រាប់ជនពិការ ការគូសផែនទីអង្គការ

មិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល សហព័ន្ធនិងអ្នកផ្តល់សេវាផ្សេងៗបានបង្ហាញអង្គភាពចំនួន១៣៨ ដែលធ្វើការជាមួយឬសម្រាប់ជនពិការ។[27] ទោះជាយ៉ាងណាក៏ដោយ សេវាកម្មទាំងនេះមិនគ្របដណ្តប់គ្រប់ស្រុកទាំងអស់នៅក្នុងខេត្ត ឬគ្រប់ភូមិនិងឃុំនៅក្នុងស្រុកឡើយ។

### ២.២.២ សេវាកម្មទាក់ទងជនពិការ

រដ្ឋមានទីតាំងជាច្រើនកន្លែងដែលផ្តល់សេវាថែទាំសុខភាពដល់ជនពិការនិងជនមិនពិការ រួមមានមន្ទីរពេទ្យ មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងមន្ទីរសុខាភិបាល ប៉ុន្តែការទទួលបានសេវាថែទាំសុខភាព ដែលសមស្រប និងមានតំលៃសមរម្យគឺនៅតែជាបញ្ហាប្រឈមមួយសម្រាប់ប្រជាជនមួយភាគធំនៅក្នុងប្រទេសកម្ពុជា ជាពិសេសអ្នកដែលរស់នៅតាមជនបទឬតំបន់ដាច់ស្រយាល។ ទោះបីជាមានសេចក្តីរបស់ក្រសួងសុខាភិបាលឆ្នាំ២០០៩ ដែលផ្តល់ឱ្យជនក្រីក្រជាមួយភាពពិការអាចទទួលបានសេវា ថែទាំសុខភាពដោយឥតគិតថ្លៃក្តី ជនពិការនៅតែបន្តជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនដូចជា មណ្ឌលសុខភាពនៅថ្នាក់ឃុំពុំមានបុគ្គលិកគ្រប់គ្រាន់ ជំនាញដែលទាក់ទងនឹងពិការភាពនិងការកំណត់អត្តសញ្ញាណពិការភាពនៅមានកំរិត ការចំណាយទៅលើមធ្យោបាយធ្វើដំណើរនិងចម្ងាយឆ្ងាយពីផ្ទះទៅកាន់មណ្ឌលសុខភាព ការបង់កម្រៃក្រៅផ្លូវការ ជនពិការក៏ដូចជាក្រុមគ្រួសារគាត់ចំណេះដឹងតិចតួចទាក់ទងទៅសិទ្ធិនិងសេវាដែលជនពិការអាចទទួលបាន និងកត្តារាំងដោយហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ឧបសគ្គដ៏ចំបងមួយទៀតក្នុងការទទួលបានសេវាថែទាំសុខភាពគឺធនធានហិរញ្ញវត្ថុ។[28]

មូលនិធិសមធម៌សុខាភិបាល (HEF)[29] ជាគម្រោងផ្តល់ហិរញ្ញប្បទានសុខាភិបាល សំដៅជួយដល់ប្រជាជនក្រីក្រដោយផ្តោតលើគ្រួសារក្រីក្រដែលគេបានកំណត់អត្តសញ្ញាណនៅក្នុងតំបន់ជាក់ស្តែងណាមួយ ដោយផ្តល់ជំនួយផ្នែកសង្គម និងជំនួយហិរញ្ញវត្ថុ ដើម្បីឲ្យអ្នកក្រអាចមានលទ្ធភាពច្រើនជាងមុនក្នុងការប្រើប្រាស់សេវាសុខភាពរបស់រដ្ឋ។ HEF ជាអ្នកចេញថ្លៃលើចំណាយផ្ទាល់សម្រាប់សេវាសុខភាព និងថ្នាំសង្កូវផ្សេងៗឲ្យអ្នកក្រ ព្រមទាំងជួយចេញសំណងថ្លៃធ្វើដំណើរឲ្យអ្នកជំងឺ រួមទាំងប្រាក់ឧបត្ថម្ភថ្លៃម្ហូបអាហារឲ្យអ្នកកំដររបស់អ្នកជំងឺក្នុងពេលត្រូវសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យទៀតផង។

---

[27] *Situation Analysis for Disability-Inclusive Governance and Community Development in Cambodia* 2014, ទំព័រទី២៧

[28] Working Paper, *Barriers to and Facilitators of Health Services for People with Disabilities in Cambodia*, ២០១២, ទំព័រទី៥-៦

[29] ជាផ្នែកនៃយុទ្ធសាស្ត្រគាំពារសុខភាពសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា។ អង្គការ URC ជាអ្នកនាំមុខគេក្នុងការគាំទ្រដល់ការអនុវត្ត HEF នៅកម្ពុជាចាប់តាំងពីឆ្នាំ២០០៣ ដែលផ្តល់មូលនិធិដោយទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ដោយមានកិច្ចសហការដោយផ្ទាល់ជាមួយនឹងក្រសួងសុខាភិបាលកម្ពុជា។

សេវាកម្មស្តារនីតិសម្បទា រួមមានការព្យាបាលដោយចលនា ការផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយ អវយវៈសិប្បនិម្មិត និងរណប ការស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ និងឧបករណ៍ជំនួយផ្សេងៗទៀត ត្រូវបានផ្តល់ជូនដោយមជ្ឈមណ្ឌលស្តារសម្បទា(PRC) ចំនួន១១កន្លែង។[30] ក្រៅពីនេះក៏មានមជ្ឈមណ្ឌលស្តារសម្បទាថ្នាក់ខេត្តកម្រិតតូចនៅខេត្តកំពង់ធំ ខេត្តព្រះវិហារនិងខេត្តស្វាយរៀងផងដែរ។ សេវាស្តារនីតិសម្បទាសម្រាប់កុមារពិការ ឬអ្នកដែលមានបញ្ហាខួរឆ្អឹងខ្នង ក៏មានជាសេវាកម្មតាមផ្ទះផងដែរ ដែលជាផ្នែកមួយនៃកម្មវិធីស្តារនីតិសម្បទាតាមសហគមន៍(CBR) ដែលត្រូវបានអនុវត្តន៍ដោយអង្គការមិនមែនរដ្ឋាភិបាល។ [31] លើសពីនេះទៀតក៏មានអង្គការដែលជួយមើលថែកុមារពិការពេលថ្ងៃនៅក្នុងតំបន់គោលដៅរបស់ពួកគេផងដែរ ដូចជា DDSP, មេត្តាហៅស៍, KPF ជាដើម។

ចំពោះការអប់រំវិញ គេឃើញមានសាលារៀនដែលផ្តល់ការអប់រំដល់កុមារដែលមានពិការភាពផ្នែកសតិបញ្ញាកម្រិតមធ្យមនិងធ្ងន់ធ្ងរ ការលើកកម្ពស់ការអប់រំនៅក្នុងថ្នាក់រៀនរួមគ្នានៅសាលារៀនរដ្ឋ ការដាក់បញ្ចូលពិការភាពទៅក្នុងការអប់រំតាមរយៈការផ្តល់ការបណ្តុះបណ្តាលនិងការលើកទឹកចិត្តដល់គ្រូបង្រៀន និងការបង្កើនលទ្ធភាពក្នុងការមកសាលារៀន ព្រមទាំងការផ្តល់អាហារូបករណ៍ដើម្បីកែលម្អលទ្ធភាពទទួលបានការអប់រំខ្ពស់។[32] សម្រាប់ជនពិការគ ថ្លង់ និងភ្នែក មានសាលាចំនួនប្រាំដែលបង្រៀនពួកគាត់ និងមានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីភាសាសញ្ញានិងអក្សរស្ទាបដោយអង្គការ គ្រួសារថ្មី[33] សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានបកបានបកប្រែភាសាសញ្ញានិងអក្សរស្ទាបស្របតាមកម្មវិធីសិក្សាថ្នាក់ទី១ដល់ទី១២ និងបង្កើត ព្រមទាំងផ្សព្វផ្សាយសម្ភារៈភាសាសញ្ញាជាង២,០០០។ រីឯកម្មវិធីអភិវឌ្ឍន៍ជនគថ្លង់វិញ (DDP) ក៏បានបង្កើតនិងក៏បានបង្កើតនិងបោះផ្សាយសៀវភៅនិងវចនានុក្រមភាសាសញ្ញា។[34] លើសពីនេះទៀតសមាគមជនពិការភ្នែកកម្ពុជា(ABC) បានរៀបចំបណ្ណាល័យធនធានមួយដែលមានសៀវភៅនិងឧបករណ៍សម្លេងសម្រាប់ជំនួយជនពិការភ្នែក។

---

[30] មាននៅរាជធានីភ្នំពេញ (២កន្លែង) បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ ក្រចេះ ព្រៃវែង សៀមរាប ខេត្តព្រះសីហនុ និងតាកែវ។ វគ្គជំនាញសម្រាប់អ្នកបច្ចេកទេស អាចរកបាននៅសាលា Cambodian School of Prosthetics and Orthotics និង The Technical School for Medical Care។

[31] មានដូចជាអង្គការបេសកកម្មអភិវឌ្ឍន៍ជនពិការកម្ពុជា(CDMD) អង្គការកសាងសមត្ថភាពជនពិការក្នុងសហគមន៍(CABDICO) កម្មវិធីអភិវឌ្ឍន៍ពិការភាព(DDSP) អង្គការកុមារពិការ(KPF) អង្គការប្រតិបត្តិការកុមារកម្ពុជា(OEC) អង្គការ Safe Haven និងអង្គការអតីតយុទ្ធជនអន្តរជាតិកម្ពុជា(VI-C)។

[32] មានសាលារៀនទន្សាយ (RSO), ផ្ទះស្នាមញញឹមរបស់អង្គការហោហ្កា, CABDICO, CDMD, DDSP, អង្គការគ្រួសារថ្មី (KT), អង្គការកុមារនៃក្តីសង្ឃឹម (KNKS) , KPF, OEC, CT…។

[33] តាម Joint Programme Doucument: *Disability Rights Initiative Cambodia* របស់UN, ទំព័រទី៨៥ គេប៉ាន់ប្រមាណថាមនុស្សចំនួន៥ម៉ឺននាក់នៅក្នុងប្រទេសកម្ពុជាគឺថ្លង់ប៉ុន្តែមានតែមនុស្ស១,៨០០ នាក់ដែលថ្លង់ត្រូវបានបង្រៀនភាសាសញ្ញា

[34] *Situation Analysis for Disability-Inclusive Governance and Community Development in Cambodia* 2014, ទំព័រទី19

យ៉ាងណាក៏ដោយ កត្តាខ្វះខាតធនធានមនុស្សខាងផ្នែកចិត្តវិទ្យា បច្ចេកទេស និងធនធានហិរញ្ញវត្ថុ បានចោទជាការប្រឈមមួយសម្រាប់ជនមានបញ្ហាផ្នែកសតិអារម្មណ៍ បើទោះបីក្រសួងសុខាភិបាលមានចក្ខុវិស័យថា ប្រជាជនកម្ពុជាគ្រប់រូបរស់នៅសមស្របទៅនឹងសុខុមាលភាពផ្លូវចិត្ត និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចល្អបំផុត ដើម្បីសម្រេចបាននូវគុណភាពជីវិតដែលពេញចិត្តដូចដែលគាត់ចង់បានសម្រាប់ជម្ងឺសតិអារម្មណ៍ក្តី។ គេឃើញមានមជ្ឈមណ្ឌលសុខភាពផ្លូវចិត្តសម្រាប់កុមារនិងមនុស្សពេញវ័យជ័យជម្នះ (CCAMH) មួយកន្លែងនៅខេត្តកណ្តាល ដែលផ្តល់សេវាកម្មព្យាបាលនិងការថែទាំសុខភាពដល់កុមារដែលមានបញ្ហាសុខភាពផ្លូវចិត្ត។ ក្រៅពីនេះក៏មានអង្គការក្រៅរដ្ឋាភិបាល មួយចំនួនដូចជា Social Services of Cambodia, Transcultural Psychosocial Organization, ក្រុមជួយខ្លួនឯង (SHG) ជាដើម ដែលផ្តល់ការគាំទ្រចិត្តវិទ្យា បច្ចេកទេស វគ្គបណ្តុះបណ្តាល សេវាកម្ម សុខភាពផ្លូវចិត្តនិងជាដៃគូតាមរយៈកម្មវិធីCBR ផងដែរ។

កីឡាត្រូវបានចាត់ថាជាមធ្យោបាយដែលមានប្រសិទ្ធភាពនិងចំណាយទាប ក្នុងការលើកកម្ពស់សុខុមាលភាព ផ្លូវកាយ ផ្លូវចិត្ត និងការដាក់បញ្ចូលមនុស្សពេញវ័យនិងកុមារពិការទៅក្នុងសកម្មភាពសង្គមសម្រាប់។ អង្គការដែលធ្វើការដើម្បីលើកកម្ពស់កីឡាសម្រាប់ជនពិការរួមមានគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា ក្រុមជម្រើសជាតិកីឡាបាល់ទះជនពិការកម្ពុជា (CNVLD), Spirit of Soccer និងគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC)។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា បានសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន៩កន្លែង ដើម្បីផ្តល់ការបណ្តុះបណ្តាលនៅសហគមន៍ដល់ជនពិការ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈបន្ទាយព្រាប[35] មានបានផ្តល់កន្លែងស្នាក់នៅដល់ស្ត្រីនិងបុរសពិការប្រមាណ១០០នាក់ទូទាំងប្រទេស។ ក្នុងការរួមចំណែកពង្រឹងអំណាចសេដ្ឋកិច្ចរបស់ជនពិការ គឺមានគម្រោងបង្កើតចំណូល ដែលមាននិរន្តរភាពសម្រាប់ជនរងគ្រោះពីគ្រាប់មីននិងជនពិការផ្សេងទៀត (TIGA) ដែលផ្តោតលើការអភិវឌ្ឍជំនាញបច្ចេកទេសនិងសហគ្រិនភាពសេវាកម្មហិរញ្ញវត្ថុ ការការពារសង្គម និងការបង្កើតការងារសម្រាប់ខ្លួនឯង ដែលធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន។[36] ក្រុមជួយខ្លួនឯងជាច្រើនត្រូវបានគាំទ្រនិងបង្កើតឡើងដើម្បីលើកកម្ពស់ការពង្រឹងអំណាចសេដ្ឋកិច្ចតាមរយៈ ការធ្វើសកម្មភាពដូចជាការសន្សំប្រាក់ធនាគារគោនិងស្រូវ ព្រមទាំងការចិញ្ចឹមជ្រូក។ ក្រុមទាំងនេះត្រូវបានចាត់ទុកថាមានសារៈសំខាន់

[35] បង្កើតនិងគ្រប់គ្រងដោយ Jesuit Refugee Service

[36] *Good Practices from the Project: Towards Sustainable Income Generating Activities for Mine Victims and Other Persons with Disabilities in Cambodia*, Handicap International Federation, 2010

ដោយសារតែជនពិការជារឿយៗមិនអាចទទួលបាននូវគម្រោងឥណទានខ្នាតតូចតាមប្រព័ន្ធ មីក្រូហិរញ្ញវត្ថុដោយសារភាពក្រីក្រនិងការខ្វះទំនុកចិត្ត។[37]

បន្ថែមពីលើគម្រោងក៏ដូចជាសេវាកម្មដែលផ្តល់ជូនជនពិការ ក៏មានកម្មវិធី CIDI របស់កាកបាទក្រហមអូស្ត្រាលី(ARC) ដែលបានលើកទឹកចិត្តនិងបណ្តុះបណ្តាលអង្គការមិនមែនរដ្ឋាភិបាលធ្វើការទាក់ទង និងមិនទាក់ទងវិស័យពិការភាព ដើម្បីរួមបញ្ចូលជនពិការ នៅក្នុងកម្មវិធីរបស់ពួកគេ។[38]

## ២.៣ ការដាក់បញ្ចូលពិការភាពទៅក្នុងដំណើរការកសាងផែនការ

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាព និងការឆ្លើយតបចំពោះបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋគ្រប់រូបក្នុងសហគមន៍របស់ខ្លួន ជាពិសេសជនងាយរងគ្រោះ។ ផែនការអនុវត្តរយៈពេល៣ឆ្នាំ ដំណាក់កាលទី២ (ផអ៣ទី២) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផ្តោតជាសំខាន់លើបរិយាប័ន្ន និងសមធម៌សង្គម ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អ ដែលកំពុងបានផ្តល់ឱកាសឱ្យជនពិការបានចូលរួមក្នុងដំណើរការអភិវឌ្ឍ។ តាមពិតទៅគម្រោងទាំងអស់ ដូចជាការអប់រំសាធារណៈ សកម្មភាពបង្កើនប្រាក់ចំណូល ឬព័ត៌មានសាធារណៈ គឺសុទ្ធតែតែការពាក់ព័ន្ធជាមួយនឹងជនពិការ ប៉ុន្តែប្រជាពលរដ្ឋជាច្រើនគិតថាមានតែគម្រោងស្តារលទ្ធភាពពលកម្ម ឬការអប់រំពិសេសប៉ុណ្ណោះដែលទាក់ទងនឹងជនពិការ។ ខាងក្រោមគឺជាសកម្មភាពជាក់លាក់ដែលធានាដល់ការចូលរួមរបស់ជនពិការនៅមូលដ្ឋាន។

### ២.៣.១ ថ្នាក់ឃុំ សង្កាត់

**សកម្មភាពជាក់លាក់សម្រាប់ដាក់បញ្ចូលពិការភាព**[39]

- <u>ជំហានទី១៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់</u>
  - ប្រមូល និងចែករំលែកទិន្នន័យអំពីជនពិការនៅក្នុងឃុំ សង្កាត់
  - អញ្ជើញជនពិការ និងគ្រួសាររបស់ពួកគេឱ្យចូលរួមនៅក្នុងកិច្ចប្រជុំភូមិ
  - ធានាថា ទីតាំងសម្រាប់កិច្ចប្រជុំភូមិ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ
  - ធ្វើការវិភាគលើឧបសគ្គនានាជាមួយនឹងជនពិការ
  - កំណត់រកក្រុមជនពិការ និងបង្កើតបណ្តាញជាមួយពួកគេ

---

[37] Komar Pikar Foundation, *Self-Help Groups and Parents/Carers of Children with Disability – A Participatory Action Research Initiative*, 2012, ទំព័រទី១១

[38] *Cambodia Initiative for Disability Inclusion*, Youtube, ចុះផ្សាយថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៤

[39] សៀវភៅណែនាំសម្រាប់អ្នកចូលរួមស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលឃុំ សង្កាត់, ខែឧសភា ២០១៧, ទំព័រទី៥៧-៥៨

- កំណត់ទីតាំងអ្នកផ្តល់សេវាដល់ជនពិការ និងអង្គការដែលធ្វើការផ្នែកពិការភាព

• <u>ជំហានទី២ ៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់</u>

- ក្នុងការជ្រើសរើសគម្រោង គ.ផ.ថ. គួរពិចារណារលើ គម្រោងដែលឆ្លើយតបទៅនឹងតម្រូវការរបស់ជនពិការ ស្ត្រី កុមារ យុវជន និងជនងាយរងគ្រោះ(បរិយាប័ន្ន និងសមធមិសង្គម) ទាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត និងគម្រោងសេវាកម្មនានា
- រៀបចំផែនការសម្រាប់គម្រោងកសាងសមត្ថភាពអំពីការដាក់បញ្ចូលពិការភាពទៅក្នុងគម្រោងនៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់ភូមិ (ឧទាហរណ៍ ៖ ការលើកកម្ពស់ការយល់ដឹង)
- ធានាថា អគារសាធារណៈ និងសម្ភាររូបវន្តដែលមានស្រាប់ និងថ្មីៗ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ
- ធានាថាព័ត៌មានសាធារណៈ (ឧទាហរណ៍ ៖ សុខភាព កសិកម្ម ។ល។) អាចទទួលបាន និងអាចយល់ដឹងបានដោយជនពិការទៅតាមប្រភេទនៃពិការភាព
- រៀបចំសូចនាករដែលមានការដាក់បញ្ចូលពិការភាពនៅក្នុងគម្រោង ឧទាហរណ៍ ចំនួនជនពិការចូលរួមក្នុងការផ្តល់យោបល់ និងចំនួនជនពិការទទួលផលប្រយោជន៍ពីគម្រោង។ល។
- ធានាឱ្យមានវិភាជន៍ថវិកាសម្រាប់ការបង្កភាពងាយស្រួលដល់ជនពិការ ដូចជា ជួលអ្នកបកប្រែភាសាសញ្ញា ឬការបង្កភាពងាយស្រួលដល់ការធ្វើដំណើរនៃជនពិការកាយសម្បទា។ល។
- ផ្តល់អាទិភាពដល់ក្រុមដែលទន់ខ្សោយជាងគេ ឬជាងគេបំផុត (ដូចជា ស្ត្រីពិការ)
- អញ្ជើញតំណាងអង្គការជនពិការឱ្យចូលរួមនៅក្នុងសិក្ខាសាលា
- ធ្វើឱ្យអង្គការមិនមែនរដ្ឋាភិបាល យល់ដឹង ចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- ដាក់បញ្ចូលគម្រោង ឬសូចនាករដែលពាក់ព័ន្ធផ្ទាល់ទៅនឹងពិការភាពក្នុងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការដាក់បញ្ចូលពិការភាពក្នុងគម្រោងផ្អែកទៅតាមសូចនាករ និងការវាស់វែងលើផលប៉ះពាល់របស់គម្រោងទៅលើជនពិការ
- មានតំណាងជនពិការនៅក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

• <u>ជំហានទី៣ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់</u>

- មានតំណាងជនពិការចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់
- ធ្វើឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្ត យល់ដឹង ចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព

- មេឃុំ ចៅសង្កាត់ ឬ គ.ផ.ថ គប្បីណែនាំឱ្យមានការផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ជាពិសេសជនពិការ តាមរយៈកិច្ចប្រជុំនានា វេទិកាសាធារណៈ សារព័ត៌មាន វិទ្យុ និងមធ្យោបាយផ្សេងៗទៀត។

ក្រុមប្រឹក្សាឃុំ សង្កាត់ គួរជ្រើសរើស ឬតែងតាំងជនពិការជាសមាជិក គ.ផ.ថ ដើម្បីឱ្យពួកគាត់បានចូលរួមគ្រប់ដំណាក់កាល នៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់។

### ២.៣.២ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**សកម្មភាពជាក់លាក់សម្រាប់ដាក់បញ្ចូលពិការភាព[40]**

- ជំហានទី១ ៖ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត/ ក្រុង ស្រុក ខណ្ឌ
  - រៀបចំផែនការសម្រាប់កសាងសមត្ថភាពអំពីការដាក់បញ្ចូលពិការភាពទៅក្នុងគម្រោងនៅ ថ្នាក់រាជធានី ខេត្ត/ ក្រុង ស្រុក ខណ្ឌ
  - ចែករំលែកទិន្នន័យអំពីជនពិការនៅក្នុងរាជធានី ខេត្ត/ ក្រុង ស្រុក ខណ្ឌ នៅក្នុងកិច្ចប្រជុំណែនាំដើម្បីកំណត់និងរៀបចំសំណើគម្រោងវិនិយោគ
  - អញ្ជើញតំណាងជនពិការចូលរួមប្រជុំស្តីពីការប្រមូលតម្រូវការអាទិភាព និងកិច្ចប្រជុំបូកសរុប បញ្ជីគម្រោងអាទិភាព
  - អញ្ជើញស្ថាប័នដែលធ្វើការផ្នែកពិការភាព ឬធ្វើការជាមួយជនពិការ ឱ្យចូលរួមនៅក្នុងកិច្ចប្រជុំណែនាំ និងចែករំលែកបញ្ហានានាទាក់ទងនឹងជនពិការ
  - ធានាថា ទីតាំងសម្រាប់កិច្ចប្រជុំ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ។
- ជំហានទី២ ៖ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត/ ក្រុង ស្រុក ខណ្ឌ
  - ធានាថា អគារសាធារណៈ និងសម្ភាររូបវន្តដែលមានស្រាប់ និងថ្មីៗ មានការបង្កភាពងាយស្រួលសម្រាប់ជនពិការ
  - ធានាថាព័ត៌មានសាធារណៈ (ឧទាហរណ៍ ៖ សុខភាព កសិកម្ម ។ល។) អាចទទួលបាន និងអាចយល់ដឹងបានដោយជនពិការទៅតាមប្រភេទនៃពិការភាព
  - រៀបចំសូចនាករដែលមានការដាក់បញ្ចូលពិការភាពនៅក្នុងគម្រោង ឧទាហរណ៍ ចំនួនជនពិការចូលរួមក្នុងការផ្តល់យោបល់ និងចំនួនជនពិការទទួលផលប្រយោជន៍ពីគម្រោង។ល។

[40] សៀវភៅណែនាំស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ,២០១៦, ទំព័រទី១០៦ និង១១៤

- ធានាឱ្យមានវិភាជន៍ថវិកាសម្រាប់ការបង្កភាពងាយស្រួលដល់ជនពិការ ដូចជា ជួលអ្នកបកប្រែភាសាសញ្ញា ឬការបង្កភាពងាយស្រួលដល់ការធ្វើដំណើរនៃជនពិការកាយសម្បទា។ល។
- ផ្តល់អាទិភាពដល់ក្រុមដែលទន់ខ្សោយជាងគេ ឬជាងគេបំផុត (ដូចជា ស្ត្រីពិការ)
- អញ្ជើញតំណាងអង្គការជនពិការឱ្យចូលរួមនៅក្នុងសិក្ខាសាលា
- ធ្វើឱ្យអង្គការមិនមែនរដ្ឋាភិបាល យល់ដឹង ចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
- ដាក់បញ្ចូលគម្រោង ឬសូចនាករដែលពាក់ព័ន្ធផ្ទាល់ទៅនឹងពិការភាពក្នុងក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការដាក់បញ្ចូលពិការភាពក្នុងគម្រោងផ្អែកទៅតាមសូចនាករ និងការវាស់វែងលើផលប៉ះពាល់របស់គម្រោងទៅលើជនពិការ
- មានតំណាងជនពិការនៅក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

• <u>ជំហានទី៣ ៖ ការពិនិត្យ អនុម័ត និងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ</u>
  - មានតំណាងជនពិការចូលរួមក្នុងកិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ
  - ធ្វើឱ្យក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ យល់ដឹង ចាប់អារម្មណ៍អំពីការដាក់បញ្ចូលពិការភាព
  - អភិបាលរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ ឬក្រុមការងារកសាងផែនការ គប្បីណែនាំឱ្យមានការផ្សព្វផ្សាយខ្លឹមសារកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ សង្កាត់ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ជាពិសេសជនពិការ តាមរយៈកិច្ចប្រជុំនានា វេទិកាសាធារណៈ សារព័ត៌មាន វិទ្យុ និងមធ្យោបាយផ្សេងៗទៀត។

ស្របទៅតាមស្ថានភាពនៃរដ្ឋបាលរបស់ខ្លួន រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិអាចជ្រើសរើសយកវិធីសាស្ត្រផ្សេងៗមកប្រើប្រាស់តាមការចាំបាច់ ដែលធានាបាននូវការលើកកម្ពស់សមធម៌សង្គម និងបរិយាប័ន្ននៅក្នុងការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន ដោយរួមមានការបង្កលក្ខណៈងាយស្រួលចេញចូលទីកន្លែងសាធារណៈសម្រាប់ជនពិការគ្រប់ប្រភេទ ដូចជាការរៀបចំចំណតយានយន្ត សម្រាប់ជនពិការ ការធ្វើជម្រាល ការបំពាក់ឧបករណ៍ផ្ទាក់ដៃនៅតាមបន្ទប់ទឹក ការដាក់ស្លាកសញ្ញានានា នៅតាមក្រសួង ស្ថាប័ន មន្ទីរ ផ្លូវថ្នល់ ទីកន្លែងលំហែកាយ មជ្ឈមណ្ឌលវប្បធម៌ កន្លែងលេងកីឡា កន្លែងកំសាន្ត គ្រឹះស្ថានអប់រំ សណ្ឋាគារ មន្ទីរពេទ្យ មណ្ឌលសុខភាពព្រមទាំង

បង្កើនការយកចិត្តទុកដាក់គិតគូរពីផលប្រយោជន៍ និងការលើកតម្កើងជីវភាពរស់នៅរបស់ជនពិការ ឲ្យបានសមរម្យស្របតាមសេដ្ឋកិច្ចជាតិ និងបានបំផុសលើកទឹកចិត្តដល់ពលរដ្ឋ សប្បុរសជន ផ្នែកឯកជន និងអង្គការសង្គមស៊ីវិល ឲ្យចូលរួមឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្តដល់ជនពិការ។

# ជំពូកទី៣

# របកគំហើញលើការស្រាវជ្រាវ

# ជំពូកទី៣

# របកគំហើញលើការស្រាវជ្រាវ

## ៣.១. កត្តារារាំងដល់ជនពិការក្នុងការអភិវឌ្ឍខ្លួន

### ៣.១.១. ភាពមានកម្រិតក្នុងប្រមូលទិន្នន័យជនពិការ

ការប្រមូលទិន្នន័យជនពិការត្រូវបានមើលឃើញថា មិនទាន់មានភាពជាក់លាក់និងគ្រប់គ្រាន់នៅឡើយទេ។ ដោយសារការប្រមូលទិន្នន័យមានសារសំខាន់ក្នុងដំណើរការជំរុញការអនុវត្តច្បាប់ស្តីពីពិការភាព ការអភិវឌ្ឍន៍គោលនយោបាយនិងផែនការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងសុខាភិបាល បានចេញប្រកាសអន្តរក្រសួងស្តីពីការកំណត់លក្ខណវិនិច្ឆ័យប្រភេទនិងកម្រិតពិការភាពនៅឆ្នាំ២០១១ ក្នុងគោលបំណងធ្វើឱ្យការប្រមូលទិន្នន័យមានលក្ខណៈស្តង់ដារជារួមមួយ។ នៅក្នុងប្រកាសបានកំណត់អំពីប្រភេទពិការភាពចំនួនបួន ដែលរួមមាន ពិការកាយសម្បទា ពិការសតិបញ្ញា ពិការផ្លូវចិត្ត និងពិការផ្សេងៗ។ ទោះបីជាយ៉ាងនេះក្តី ភាពត្រឹមត្រូវច្បាស់លាស់ និងភាពទូលំទូលាយនៃទិន្នន័យជនពិការក៏នៅមិនទាន់មាន។ តាមការស្រាវជ្រាវ ការប្រើប្រាស់យន្តការផ្សេងៗគ្នាក្នុងការកំណត់ចំនួនជនពិការនាំឱ្យទិន្នន័យជនពិការនៅកម្ពុជាមានសភាពមិនប្រាកដប្រជា ដែលនឹងធ្វើការលើកឡើងជាបន្តបន្ទាប់នៅខាងក្រោម៖

- យោងតាមរបាយការណ៍អង្គការសុខភាពពិភពលោក និង ធនាគារពិភពលោក ឆ្នាំ២០១១ ដែលប៉ាន់ប្រមាណថា មានជនពិការចំនួន១៥ភាគរយនៃចំនួនប្រជាជនសរុប និងមាន២.២ភាគរយក្នុងនោះមានភាពលំបាកខ្លាំងក្នុងការដំណើរការមុខងារនៃរាងកាយ។ ក្នុងករណីអនុលោមតាមការប៉ាន់ប្រមាណនេះ ប្រទេសកម្ពុជាអាចមានមនុស្សពេញវ័យនិងកុមារពិការប្រមាណ២លាននាក់ ដែលមនុស្សចំនួនជាង៣២០,០០០នាក់មានដំណើរការពិបាកយ៉ាងខ្លាំង។ ការកើនឡើងនៃតួលេខជនពិការកម្ពុជាក្នុងយន្តការនេះ គឺពាក់ព័ន្ធនឹងការកំណត់និយមន័យដោយតាមនិយមន័យច្បាប់ពិការភាពកម្ពុជា ផ្តោតលើស្ថានភាពនៃបុគ្គលដូចជាការខ្វះខាតអវយវៈឬបញ្ញា ឯអនុសញ្ញាស្តីពីសិទ្ធិជនពិការវិញ គឺសង្កត់ធ្ងន់ទៅលើឧបសគ្គដែលជនមានភាពអន់ខ្សោយរយៈពេលយូរជួបប្រទះ។
- ដោយឡែក យន្តការប្រមូលទិន្នន័យចំនួនជនពិការរបស់រាជរដ្ឋាភិបាលកម្ពុជា ហាក់មិនមានភាពស៊ីសង្វាក់គ្នាឡើយ។ ជាក់ស្តែង ការអង្កេតសង្គមសេដ្ឋកិច្ចកម្ពុជា (CSES) នៅឆ្នាំ២០១២ បានបញ្ជាក់ថាពិការភាព ក្នុងប្រទេសកម្ពុជាមានចំនួន៥ភាគរយនៃប្រជាជនសរុប ឬប្រហែល៦២៤,០០០នាក់។ រីឯ ការជំរឿនប្រជាសាស្ត្រ ឆ្នាំ២០១៣ បានបង្ហាញថាមានជនពិការចំនួន២,១ភាគរយ ស្មើនឹង៣០១,៦២៩នាក់។

- ការប្រមូលទិន្នន័យមូលដ្ឋាននៅតាមឃុំ សង្កាត់ធ្វើឡើងជារៀងរាល់ឆ្នាំផ្អែកលើការស្ទង់មតិស្តង់ដារដែលរួមមានសំណួរចំនួនពីរគឺ ចំនួនជនពិការក្នុងភូមិ និងមូលហេតុនៃពិការភាព។ ទិន្នន័យឃុំសង្កាត់ឆ្នាំ២០១១ បានបង្ហាញថាមានជនពិការចំនួន៨៥,៦៣៦នាក់ ដែលស្មើនឹង ០,៨៩ភាគរយនៃប្រជាជនសរុប។ ការប្រមូលទិន្នន័យនៅមូលដ្ឋាន អាចជាការស្រង់តួលេខជនពិការបានប្រសើរជាងគេព្រោះជារដ្ឋបាលដែលនៅជិតប្រជាពលរដ្ឋជាងគេ យ៉ាងណាមិញការស្រង់ដោយសំអាងលើតែសំណួរ មិនមានជំនាញបច្ចេកទេស អាចបណ្តាលឱ្យទិន្នន័យជនពិការផ្លូវចិត្ត សតិបញ្ញាជាអាទិ៍ត្រូវបានបាត់បង់ និងមិនមានលក្ខណៈស្តង់ដារពីឃុំ សង្កាត់មួយទៅមួយ។
- កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (គម្រោងប័ណ្ណជនក្រីក្រ) របស់ក្រសួងផែនការ សហការជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋានរបស់ក្រសួងមហាផ្ទៃ (DoLA)[41] ធ្វើការប្រមូលទិន្នន័យជនក្រីក្រ រួមទាំងជនពិការផង ដើម្បីអនុវត្តវិធានការកែលម្អស្ថានភាពរបស់ជនក្រីក្រ ប៉ុន្តែសម្រង់ជនពិការធ្វើឡើងតែចំពោះមេគ្រួសារ ដូច្នេះកូនក្នុងបន្ទុកដែលជាជនពិការមិនបានរាប់ក្នុងទិន្នន័យឡើយ។
- យន្តការផ្សេងៗទៀតដើម្បីប្រមូលទិន្នន័យពាក់ព័ន្ធនឹងពិការភាពរួមមាន៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំរបស់ក្រសួងអប់រំយុវជននិងកីឡា (EMIS), ផែនទីសេវាកម្មសង្គមរបស់អង្គការយូនីសេហ្វ, មជ្ឈមណ្ឌលស្តារនីតិសម្បទារាងកាយ (PRC), ទិន្នន័យដែលប្រមូលបានពី PWDF/MoSVY ទាក់ទងនឹងមូលនិធិគាំពារសង្គមសម្រាប់ជនពិការនិងអតីតយុទ្ធជន, ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារគ្រាប់មីននិងកាកសំណល់សង្គ្រាមកម្ពុជា (CMVIS), អង្គការជនពិការកម្ពុជា (CDPO) ក៏បានប្រមូលទិន្នន័យស្តីពីជនពិការនៅក្នុងតំបន់គោលដៅរបស់ពួកគេ ជាដើម។

តាមទិន្នន័យដែលទទួលបានអំពីជនពិការនៅកម្ពុជា អាចបញ្ជាក់បានថាការប្រមូលទិន្នន័យធ្វើឡើងមានលក្ខណៈតាមតំបន់គោលដៅ និង តាមជំនាញឬគម្រោងកម្មវិធីណាមួយតែប៉ុណ្ណោះ។ ការធ្វើបែបនេះអាចបណ្តាលឱ្យជនពិការមួយចំនួនមិនត្រូវបានរាប់បញ្ចូល ដែលទាំងនេះនឹងអាក់ខានពួកគាត់ក្នុងដំណើរធ្វើឱ្យជីវិតមានសុខុមាលភាព និងជីវភាពល្អប្រសើរ។

### ៣.២.២. ឧបសគ្គចម្បងៗដែលជនពិការជួបប្រទះ

ឧបសគ្គ គឺកត្តាដែលរារាំងជនពិការមិនឱ្យធ្វើអ្វីមួយដូចមនុស្សផ្សេងទៀតបាន។ ជាការពិតមួយជនពិការអាចពុំមានសមត្ថភាពធ្វើអ្វីមួយដូចអ្នកផ្សេងទៀតព្រោះតែកាយសម្បទារបស់ពួកគាត់ ប៉ុន្តែ

[41] បច្ចុប្បន្នមានឈ្មោះថា នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់

ប្រសិនបើមជ្ឈដ្ឋានជុំវិញនិងមនុស្សស្វាគមន៍ ជម្រុញនិងលើកទឹកចិត្តពួកគាត់នោះ កាយសម្បទាដែលមិនគ្រប់គ្រាន់នោះមិនមែនជាបញ្ហាទៀតឡើយ។ ជនពិការអាចជួបប្រទះនឹងឧបសគ្គ នៅកន្លែងធ្វើការ ក្នុងសង្គម និងនៅផ្ទះ ដែលឧបសគ្គទាំងនោះអាចមានលក្ខណៈផ្សេងៗគ្នាទៅតាមបុគ្គលដោយសារតែជនពិការមានប្រភេទនៃភាពខ្សោយផ្សេងៗគ្នា។ ជាឧទាហរណ៍ អ្នកដែលពិការជើងអាចជួបការលំបាកក្នុងការផ្លាស់ទីទៅកន្លែងណាមួយ ដូចនេះនៅពេលដែលមានកិច្ចប្រជុំណាមួយធ្វើឡើងនៅកន្លែងដែលចាំបាច់ត្រូវឡើងជណ្ដើរ វាច្បាស់ណាស់ជាឧបសគ្គសម្រាប់គាត់ តែប្រសិនបើមានជម្រាលនៅទីនោះ ឬមានប្រអប់យន្ត ឬកិច្ចប្រជុំធ្វើឡើងនៅជាន់ផ្ទាល់ដី នោះពួកគាត់នឹងអាចមកចូលរួមក្នុងកិច្ចប្រជុំជាក់ជាមិនខាន។

ឧបសគ្គចែកជា៤ប្រភេទដូចខាងក្រោម៖

- ឥរិយាបថ៖ កើតឡើងនៅពេលដែលជនមិនពិការគិតបែបអវិជ្ជមាន ក៏ដូចជាសម្ដែងអាកប្បកិរិយាឬនិយាយមិនសមរម្យបន្ទាបបន្ថោកទៅលើជនពិការ។
- ការប្រាស្រ័យទាក់ទង៖ ជាផ្នែកដែលជនពិការមិនអាចចែករំលែកនូវព័ត៌មាន គំនិត និងអារម្មណ៍ ក៏ដូចជាការមិនទទួលបាននូវព័ត៌មានដូចជនដែលមិនពិការ។
- ការបង្កភាពងាយស្រួល៖ ជាភាពមួយដែលជនពិការពិបាកចេញចូលក្នុងអគារ ឬទីកន្លែងសាធារណៈ។
- ការចូលរួម៖ ជនពិការមានរនាំងក្នុងការចូលរួម ឬចែករំលែកនូវអ្វីមួយនៅក្នុងសកម្មភាពសង្គម។

## ៣.២. ដំណោះស្រាយ

### ៣.២.១. ឥរិយាបថ

ឥរិយាបថ គឺជាលទ្ធផលកើតចេញ ពីការវាយតម្លៃ ឬវិនិច្ឆ័យទៅលើបុគ្គលណាម្នាក់ វត្ថុ ព្រឹត្តិការណ៍ ឬគំនិតអ្វីមួយរបស់មនុស្សម្នាក់ គឺជារបៀបដែលយើងគិតអាចបែបវិជ្ជមាន ឬអវិជ្ជមាន។ គំនិតដែលបានពីការគិតទាំងនេះ ជាធម្មតាមានឥទ្ធិពលលើរបៀបដែលយើងធ្វើសកម្មភាពជាក់ស្ដែង។ ជារឿយៗ ជនពិការត្រូវបានគេផាត់ចេញពីសេចក្ដីសម្រេចជាអាទិភាពទាំងឡាយ ដោយសារតែគេមានគំនិតអវិជ្ជមាន ឬគិតខុសទៅលើជនពិការ ដូចជាគំនិតដែលថាការដែលមានកាយសម្បទាមិនគ្រប់គ្រាន់ គឺជាបណ្ដាសារឬបាបកម្មពីទង្វើមិនល្អដែលជននោះបានប្រព្រឹត្ត ឬជាគំនិតដែលថាជនពិការជាមនុស្សដែលគួរឱ្យអាណិត ព្រោះប្រហែលជាពួកគាត់មិនអាចធ្វើអ្វីដើម្បីខ្លួនឯងបានឡើយគឺតែងតែត្រូវការជំនួយពីជនដទៃជានិច្ច។ ឧទាហរណ៍ថា ឪពុកម្ដាយមានគំនិតថា កូនស្រីដែលមានភាពខ្សោយផ្នែកគំហើញរបស់ខ្លួនមិនអាចរៀនចេះឡើយ ឬមិនគួរទៅរៀនទេដើម្បីកុំឱ្យទទួលការរើសអើង

ពីក្មេងដទៃ នោះពួកគាត់ប្រាកដជាមិនបញ្ជូនកូនទៅសាលារៀន ផ្ទុយទៅវិញកូនស្រីអាចនឹងទទួលបានការអប់រំដូចកុមារដទៃទៀត ឬអាចជាសិស្សពូកែទៀតផង ប្រសិនបើពួកគាត់មិនមានការគិតបែបអវិជ្ជមានខាងលើ។

ការគិតអវិជ្ជមានរបស់អ្នកដទៃជាទូទៅនាំឱ្យជនពិការគិតថាខ្លួនគាត់ជាមនុស្សដែលពុំមានតម្លៃ និងត្រូវការឱ្យគេជួយឬជាបន្ទុកទៅលើអ្នកជុំវិញ ជាពិសេសគឺក្រុមគ្រួសារ។ ការណ៍ទាំងនេះញ៉ាំងឱ្យជនពិការមិនមានជំនឿចិត្តលើខ្លួនឯង ឬខិតខំហាត់រៀនជំនាញអ្វីមួយនោះទេព្រោះយល់ថាគេស្អប់ខ្ពើមពួកគាត់ហើយមិនទទួលឱ្យធ្វើការឡើយ។ លើសពីនេះទៀត វាអាចដល់ការសម្រេចចិត្តធ្វើអត្តឃាតទៀតផង។ យ៉ាងណាមិញ នៅពេលដែលមានគំនិតវិជ្ជមានទៅកាន់ជនពិការ ការផ្តល់ការស្វាគមន៍ និងការជំរុញលើកទឹកចិត្តឱ្យមានភាពផុសផុលក្នុងការចូលរួមពីសំណាក់ជនពិការ នឹងក្លាយជាផ្នែកយ៉ាងសំខាន់ក្នុងការលើកគុណតម្លៃនៃជីវិតរបស់ពួកគាត់។ ការផ្លាស់ប្តូរការគិតអវិជ្ជមានទៅលើជនពិការ ជាកម្លាំងរុញច្រានឱ្យជនពិការអាចទទួលបានការប្រតិបត្តិប្រកបដោយការគោរព និងសេចក្តីថ្លៃថ្នូរ។

- គប្បីប្រើប្រាស់ពាក្យពេចន៍វិជ្ជមាន និងជៀសវាងពាក្យពេចន៍អវិជ្ជមានទៅកាន់ជនពិការៈ ពាក្យពេចន៍វិជ្ជមាន គឺជាពាក្យដែលផ្តោតលើអ្វីដែលមនុស្សម្នាក់អាចធ្វើបាន ជាការចាត់ទុកជនពិការដូចជនមិនពិការ ជាការចាត់ទុកជនពិការថាមានភាពស្មើភាពគ្នា និងអាចធ្វើកិច្ចការបានជាច្រើន។ រីឯពាក្យពេចន៍អវិជ្ជមានវិញ គឺជាពាក្យដែលបន្ទោសដល់ជនពិការព្រោះភាពខ្សោយរបស់ពួកគាត់ ការសម្តែងភាពខ្ពើមរអើមឬការស្អប់ជាដើម។

### ៣.២.២. ការប្រាស្រ័យទាក់ទង

ការប្រាស្រ័យទាក់ទង គឺជាដំណើរការមួយសម្រាប់ឈានទៅដល់ការយោគយល់គ្នាទៅវិញទៅមក ដោយអ្នកចូលរួមត្រូវចែករំលែកព័ត៌មាន គំនិត និងអារម្មណ៍។ វាគឺជាដំណើរការទ្វេទិស បានសេចក្តីថាយើងអាចយល់ពីអ្វីមួយដែលជនពិការបានប្រាប់យើង ហើយយើងអាចឆ្លើយតបវិញបាន និងយើងបានផ្តល់ព័ត៌មានអ្វីមួយទៅកាន់ពួកគាត់ ហើយពួកគាត់អាចទទួលបាន។ ការប្រាស្រ័យទាក់ទង អាចកើតឡើងតាមបែបផែនច្រើនយ៉ាងដូចជា ការប្រើពាក្យសម្តីឬការនិយាយ ការប្រើសញ្ញាដូចជាកាយវិការ ទឹកមុខ ទំនាក់ទំនងតាមកែវភ្នែក និងការសរសេរ។

យើងសង្កេតឃើញថា តាមធម្មតាវាមានការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយជនពិការដោយរនាំងធម្មជាតិ និងចិត្តសាស្ត្រ។ យ៉ាងនេះក៏ដោយក្តី នៅពេលដែលការប្រាស្រ័យទាក់ទងតាមបែបផែនណាមួយហាក់បី ដូចជាពិបាក គេនៅតែអាចរិះរកវិធីផ្សេងទៀតសម្រាប់ធ្វើការ

ប្រាស្រ័យទាក់ទង។ ឧទាហរណ៍ ប្រសិនបើការប្រាស័យទាក់ទងដោយការសរសេរ និងការប្រើសញ្ញាពុំមានប្រសិទ្ធភាពសម្រាប់អ្នកដែលខ្សោយខាងគំហើញ នោះគេអាចប្រើសារជាពាក្យសម្ដីឬសម្លេងបាន។ យើងអាចប្រើប្រាស់សារជាលាយល័ក្ខណ៍អក្សរ គំនូរ ឬកាយវិការអាចមានប្រសិទ្ធភាពល្អចំពោះជនពិការគ ថ្លង់។

### ៣.២.៣. ការបង្កភាពងាយស្រួលដល់ជនពិការ

ការបង្កភាពងាយស្រួល ជាទូទៅសំដៅដល់ ភាពងាយស្រួលក្នុងការចេញចូលទីកន្លែងណាមួយសម្រាប់ជនពិការ ដែលអាចឱ្យជនពិការៈ

- ផ្លាស់ទីដោយមានទំនុកចិត្ត និងប្រកបដោយការគោរពដោយសេរី
- ផ្លាស់ទី ដោយពុំមានឧបសគ្គ
- ផ្លាស់ទី ដោយម្ចាស់ការខ្លួនឯងដោយពុំមានជំនួយផ្ទាល់ពីអ្នកដទៃ

ជាការសំខាន់ណាស់ដែលត្រូវកែសម្រួលបរិស្ថានទាំងឡាយ ដើម្បីផ្ដល់ភាពងាយស្រួលដល់មនុស្សគ្រប់គ្នាអាចប្រើប្រាស់បាន។ ការដោះស្រាយចំពោះការបង្កភាពងាយស្រួលសម្រាប់ជនពិការ គប្បីធ្វើនៅដំណាក់កាលរៀបចំផែនការគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ដូចជា អគារ ឬអណ្ដូង ព្រោះវាត្រូវការចំណាយថវិកាតិចជាង ការចំណាយទៅលើការកែលម្អឱ្យប្រសើរនូវអគារដែលសាងសង់រួច។ តម្រូវការនូវការបង្កភាពងាយស្រួលសម្រាប់ជនពិការប្រែប្រួលខុសៗគ្នាទៅតាមមនុស្សម្នាក់ៗ។ ការបង្កភាពងាយស្រួល មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការចូលរួមរបស់ជនពិការនៅក្នុងសហគមន៍។

### ៣.២.៤.ការចូលរួមឱ្យបានសកម្ម

ការចូលរួម មិនមែនត្រឹមតែមានវត្តមានប៉ុណ្ណោះទេ តែគឺជាភាពដែលអាចបង្ហាញពីការយល់ឃើញរបស់ខ្លួន និងអាចមានឥទ្ធិពលលើការសម្រេចចិត្តនានា ជាពិសេសទៅទៀតនោះ ជនពិការទទួលបានការស្វាគមន៍ និងទទួលបានការផ្ដល់ភាពអង់អាចឱ្យចូលរួមយ៉ាងសកម្ម។ ជនពិការគឺជាសមាជិករបស់សង្គម និងជាសមាជិករបស់សហគមន៍ ដែលពួកគេកំពុងរស់នៅដូចជាប្រជាពលរដ្ឋដទៃទៀតដែរ ដូចនេះហើយពួកគេគួរអាចចូលទៅកាន់គ្លីនិកឬមណ្ឌលសុខភាព សាលារៀន និងចាប់ផ្ដើមប្រកបរបរអាជីវកម្មដោយស្មើភាពគ្នា។ ផែនការនានាដូចជា ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានឥទ្ធិពលដោយផ្ទាល់ ឬប្រយោលមកលើការរស់នៅរបស់ជនពិការ ដូច្នេះជនពិការគួរត្រូវបាននិយាយដោយខ្លួនឯង និងចែករំលែកគំនិតយោបល់អំពីអ្វីដែលពួកគេចង់ធ្វើ និងមិនចង់ធ្វើ។ មានពាក្យស្លោកមួយត្រូវបានប្រើប្រាស់ដើម្បីរៀបរាប់ពីសារប្រយោជន៍នៃការចូលរួមរបស់ជនពិការសម្រាប់ជនពិការខ្លួនគាត់ផ្ទាល់ *"ពុំមានអ្វីសម្រាប់យើង*

*ដោយគ្មានការចូលរួមពីយើងឡើយ"* ដែលបានសេចក្តីថា មានតែការចូលរួម បញ្ចេញយោបល់ និងការលើកឡើងពីតម្រូវការពីសំណាក់ជនពិការដោយផ្ទាល់ឬអ្នកតំណាងប៉ុណ្ណោះទេ ដែលអាចឱ្យការអនុម័តអ្វីមួយមានការគិតគូរពីពួកគាត់និងអនុវត្តស្របទៅនឹងបរិបទនៃជនពិការ។ ជនពិការអាចចូលរួមតាមបែបផែនផ្សេងៗគ្នាដូចជា៖

- ចូលរួម ក្នុងការរៀបចំផែនការ និងកម្មវិធីនានា
- ទទួលបានប្រយោជន៍ពីកម្មវិធី និងសេវានានា
- ចូលរួមក្នុងការងារគ្រប់គ្រង និងដឹកនាំ

ដោយសារការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ មានផលប៉ះពាល់ធំធេងទៅលើផលប្រយោជន៍ជនពិការ ការមានភាពស្និទ្ធស្នាលនិងការផ្លាស់ប្តូរយោបល់រវាងជនពិការនិងអាជ្ញាធរមានសមត្ថកិច្ច ពិតជាអាចជំរុញឱ្យការដាក់បញ្ចូលពិការភាពកាន់តែមានប្រសិទ្ធភាពខ្ពស់។ ការផ្តល់ឱកាសដល់ជនពិការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត រួមទាំងការកសាងផែនការ ថវិកា ការត្រួតពិនិត្យ តាមដាន និងធ្វើការវាយតម្លៃ អាចធ្វើទៅបានលុះណាតែអាជ្ញាធរក្នុងមូលដ្ឋានបានយល់ដឹងអំពីពិការភាព គួបផ្សំនឹងបច្ចេកទេសសំខាន់ៗមួយចំនួនក្នុងការដាក់បញ្ចូលពិការភាពផងដែរ។ បច្ចុប្បន្ននេះ សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត ក្នុងការធ្វើឱ្យជនពិការអាចចូលរួមនៅក្នុងកម្មវិធីនានារបស់រាជរដ្ឋាភិបាល។ ដូច្នេះហើយ ការពង្រឹងនិងពង្រីកសមត្ថភាពដល់មន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការបង្កលក្ខណៈឱ្យជនពិការបានចូលរួមក្នុងអភិបាលកិច្ចនិងការអភិវឌ្ឍ តាមរយៈការផ្តល់ជាវគ្គបណ្តុះបណ្តាលគ្រូបង្គោល ឬការផ្សព្វផ្សាយជាអាទិ៍ ពិតជាមានសារសំខាន់និងជាដំណោះស្រាយមួយប្រកបដោយលទ្ធផលវិជ្ជមាន។

កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីការបញ្ចូលពិការភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាដំណើរការមួយដែលជំរុញយ៉ាងខ្លាំងក្នុងការផ្លាស់ប្តូរជាវិជ្ជមានសម្រាប់រយៈពេលវែង ដើម្បីមានការចូលរួមរបស់ជនពិការពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ។ កត្តានេះរួមមាន៖

- អ្នកធ្វើសេចក្តីសម្រេចចិត្ត និងទីប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិនឹងមានសមត្ថភាព (ចំណេះដឹង ជំនាញ និងឥរិយាបទ) ប្រសើរឡើងក្នុងការកំណត់ និងលុបបំបាត់ឧបសគ្គនានាដែលរារាំងជនពិការ ដើម្បីឱ្យពួកគាត់អាចទទួលបានសិទ្ធិស្មើភាព និងការអភិវឌ្ឍប្រកបដោយសមធម៌នៅក្នុងមូលដ្ឋានរបស់ខ្លួន។
- ផ្តល់ការគាំទ្រដល់ការប្រមូលស្ថិតិបែងចែកតាមពិការភាព និងរក្សាបច្ចុប្បន្នភាពស្ថិតិទាំងនេះ នៅគ្រប់កម្រិតទាំងអស់

- ពិគ្រោះយោបល់ជាមួយនឹងជនពិការក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិនិយោគបីឆ្នាំរំកិលនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីផ្ដល់លទ្ធភាពឱ្យជនពិការអាចចូលរួម នៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត។
- ធានាជនពិការអាចទទួលបានសេវាសាធារណៈកាន់តែប្រសើរជាងមុន ដូចជា លទ្ធភាពចេញចូលទីកន្លែង និងលទ្ធភាពទទួលបានព័ត៌មានជាដើម។

សរុបមក ការបំបែកនូវឧបសគ្គទាំងពួង វាគឺសកម្មភាពគោរពនិងបង្កើនការផ្ដល់តម្លៃដល់ជនពិការ និងធ្វើឱ្យជនពិការយល់ថាខ្លួនគាត់មានតម្លៃ។

# សេចក្តីសន្និដ្ឋាន
# និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន

ការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច គឺជាការសម្រេចចិត្តលើរឿងអ្វីមួយដោយបានគិតគូរពីតម្រូវការ ផលប្រយោជន៍ និងផលប៉ះពាល់ដែលអាចកើតមានពីសេចក្តីសម្រេចចិត្តនោះទៅដល់ជនពិការ។ យើងក៏អាចនិយាយយ៉ាងសាមញ្ញបានថា ជាការដកចេញនូវឧបសគ្គទាំងឡាយដែលបានរារាំងសកម្មភាពនិងឆន្ទៈជនពិការមិនឱ្យមានការប្រព្រឹត្តទៅដូចអ្នកដទៃ។ ឧបសគ្គទាំងនេះរួមមានឥរិយាបថ ការប្រាស្រ័យទាក់ទង ការបង្កភាពងាយស្រួល និងការចូលរួម។ ការដាក់បញ្ចូលពិការភាព មានភាពចាំបាច់ណាស់ វាមិនត្រឹមតែផលប្រយោជន៍ដល់ជនពិការប៉ុណ្ណោះទេ តែគឺសង្គមទាំងមូល ព្រោះពួកគាត់អាចទទួលបានការសិក្សាខ្ពង់ខ្ពស់ មានសុខភាពល្អ ដែលជាហេតុនាំអាចបញ្ចូលខ្លួនទៅក្នុងសកម្មភាពសេដ្ឋកិច្ច ដែលជាលទ្ធផលគឺការទទួលបានជីវភាពរស់នៅដ៏សមរម្យមួយដោយមិនត្រូវតែចាំបាច់ស្នើសុំនូវអំណោយសប្បុរសធម៌ឡើយ។

កិច្ចការដាក់បញ្ចូលនេះ គឺជាសកម្មភាពដែលត្រូវចំណាយពេលនិងចិត្តគំនិតជាច្រើនទៀត ព្រោះបញ្ហាប្រឈមមានលក្ខណៈជាប់ទាក់ទងគ្នា។ បញ្ហាប្រឈមក្នុងការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចក្នុងនៃប្រទេសកម្ពុជាដែលសម្គាល់ឃើញរួមមាន ការរើសអើងនិងឥរិយាបថអវិជ្ជមាន ចំណេះដឹងអំពីសិទ្ធិនិងសមត្ថភាពរបស់ជនពិការ ភាពមានកម្រិតនូវធនធានហិរញ្ញវត្ថុ បច្ចេកទេស ព្រមទាំងកត្តាធនធានមនុស្ស។ ជំនឿដក់ជ្រៅក្នុងចិត្តរបស់ប្រជាជនជាច្រើន ជាពិសេសអ្នកដែលរស់នៅតំបន់ជនបទ បានសន្មត់ថាជនពិការគឺជាបុគ្គលដែលបានប្រព្រឹត្តកំហុសឬអំពើមិនល្អទើបបានទទួលរូបរាងកាយឬមានបញ្ញាមិនពេញលេញដូចអ្នកឯទៀត ហើយក៏ជាហេតុនាំឱ្យជនពិការត្រូវបានគេរើសអើងខ្លាំង។ មួយវិញទៀត គឺពាក់ព័ន្ធទៅនឹងចិត្តអាណិតអាសូរចំពោះជនពិការ ដែលកាន់តែធ្វើឱ្យពួកគាត់ស្ថិតក្នុងសភាពមួយដែលមានភាពខុសឆ្ងាយពីអ្នកដទៃ។ ជនមិនពិការតែងយល់ថា ការគិតបែបនេះមិនមានអ្វីខុសឆ្គងទេ តែការពិតទៅជនពិការមិនមែនជាបុគ្គលដែលត្រូវរស់នៅក្រោមការអាណិតរបស់អ្នកដទៃឡើយ ព្រោះពួកគាត់អាចធ្វើអ្វីៗដូចគេគ្រប់គ្នាបានបើសិនជាពួកគាត់ត្រូវបានដាក់បញ្ចូលទៅក្នុងការសម្រេចចិត្តផ្សេងៗ ដែលជះផលផ្ទាល់ឬដោយប្រយោលទៅកាន់ពួកគាត់។

ជាការពិតណាស់ ជនពិការក៏ជាសមាជិកនៃសង្គមមួយដែរ ដូចនេះហើយពួកគាត់ក៏គួរទទួលនូវអ្វីដែលជនដទៃទៀតទទួលបានផងដែរ ដូចជាទទួលបានការអប់រំ ការថែទាំសុខភាព ជាពិសេសការប្រកបមុខរបរដែលខ្លួនពេញចិត្តនិងមិនត្រូវបានគេរើសអើងក្នុងការផ្តល់ការងារ។ តែផ្ទុយពីនេះ ជនពិការត្រូវបានគេមើលឃើញថា ភាគច្រើនមិនសូវជាបានយល់អំពីសិទ្ធិរបស់ខ្លួនឬមិនសូវជាមានទំនុកចិត្តលើខ្លួនឯងឡើយ ដែលធ្វើឱ្យបាត់បង់ឱកាសជាច្រើនក្នុងការទទួលបានសេវា ដើម្បី

មានជីវភាពរស់នៅសមរម្យនិងមានសុខុមាលភាព។ ប៉ុន្តែអ្វីដែលសំខាន់នេះទៅទៀត គឺភាពមានកំណត់នៃធនធានហិរញ្ញវត្ថុ បច្ចេកទេសនិងធនធានមនុស្ស។ វិស័យពិការភាពនៅកម្ពុជាហាក់មានភាពវិវត្តន៍ទៅមុខគួរឱ្យកត់សម្គាល់និងត្រូវបានបញ្ជ្រាបទូលំទូលាយជាងមុន យ៉ាងណាមិញកត្តាបច្ចេកទេស និងអ្នកដែលធ្វើការ ក្នុងផ្នែកនេះនៅមិនទាន់មានភាពគ្រប់គ្រាន់ ។ ម៉្យាងទៀត ទិន្នន័យជនពិការកម្ពុជាហាក់នៅមានភាពមិនច្បាស់លាស់ ព្រោះការកំណត់អត្តសញ្ញាណ ក៏ដូចជាការបែងចែកប្រភេទជនពិការ នៅមិនទាន់មានគោលការណ៍រួមតែមួយ។ បើក្រឡេកមកមើលផ្នែកថវិកាវិញ គឺពឹងផ្អែកស្ទើរទាំងស្រុងទៅលើជំនួយបរទេស។

ទោះបីជាការដាក់បញ្ចូលនេះ ជួបនូវបញ្ហាប្រឈមជាច្រើនក្តី កិច្ចខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍវិស័យពិការភាពនៅតែមានសកម្មភាពជាបន្តបន្ទាប់។ ដោយការស្ថិតក្រោមអនុសញ្ញាស្តីសិទ្ធិជនពិការ ក៏ដូចជាបទដ្ឋានគតិយុត្តិអន្តរជាតិជាច្រើនទៀត កម្ពុជាបានអនុម័តច្បាប់ស្តីពីការលើកកម្ពស់សិទ្ធិជនពិការកម្ពុជា ព្រមទាំងដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពជាគោល និងស្របតាមស្មារតីរដ្ឋធម្មនុញ្ញ ហើយមានការរួមចំណែកដោយផែនការយុទ្ធសាស្ត្រនៃក្រសួង អាទិភាព ដូចជាក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងអប់រំយុវជននិងកីឡា ក្រសួងកិច្ចការនារីជាដើម និងយុទ្ធសាស្ត្រពាក់ព័ន្ធទាំងឡាយទៀត។ លើសពីនេះទៀត គឺការបញ្ជ្រាបអំពីពិការភាពទៅក្នុងរដ្ឋបាលមូលដ្ឋានសម្រាប់ការកសាងកម្មវិធីអភិវឌ្ឍនិងកម្មវិធីវិនិយោគ ដែលជារដ្ឋបាលនៅជិតជនពិការនិងប្រជាជនដទៃទៀត។ ចំណែកឯកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន រដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល អង្គការសមាគមនានា ក៏ជាកត្តាមិនអាចខ្វះបានក្នុងការជម្នះបញ្ហាប្រឈមនៃការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចផងដែរ។

# អនុសាសន៍

បន្ទាប់ពីបានស្រាវជ្រាវលើប្រធានបទ "ការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ច" អស់មួយរយៈកាលរួចមក យើងឃើញថាវិស័យពិការភាពមានដំណើរវិវត្តទៅមុនសន្សឹមៗ យ៉ាងណាមិញ ទន្ទឹមនឹងនេះក៏មានបញ្ហាមួយចំនួនកំពុងបន្តធ្វើជារនាំងនៃការដាក់បញ្ចូលផងដែរ។ ខាងក្រោមគឺជាការរួមយោបល់ជាមតិមួយចំនួនដើម្បីដោះស្រាយការប្រឈមដែលកើតមាន៖

- ត្រូវបង្កើតលក្ខណវិនិច្ឆ័យក្នុងការកំណត់អត្តសញ្ញាណជនពិការ និងការបែងចែកប្រភេទឱ្យបានច្បាស់លាស់ជាងមុន ដើម្បីឱ្យការប្រមូលចំនួនទិន្នន័យពីជនពិការមានភាពស្រុះស្រួលគ្នានិងងាយស្រួលក្នុងការកំណត់កម្មវិធី ផែនការសកម្មភាពជាដើម។
- ត្រូវប្រើវិធីសាស្ត្របញ្ជ្រាបបញ្ហាពិការភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធិភាព ដោយមានរបាយការណ៍ច្បាស់លាស់អំពីសកម្មភាពផ្សព្វផ្សាយអំពីការដាក់បញ្ចូលពិការ-ភាព ទៅកាន់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត បន្ទាប់ពីបានទទួលការបណ្តុះបណ្តាលពីថ្នាក់ជាតិ ដើម្បីឱ្យក្រុមប្រឹក្សាការដាក់បញ្ចូលពិការភាពទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ និងធានាការចូលរួមពីសំណាក់អ្នកតំណាង ក៏ដូចជាជនពិការផ្ទាល់។
- ត្រូវបង្កើនកិច្ចសហប្រតិបត្តិជាមួយអង្គការក្រៅរដ្ឋាភិបាល អង្គការសមាគម ដៃគូអភិវឌ្ឍនានា ព្រមទាំងអ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីអាចបង្គ្រប់ភាពខ្វះខាតនៃធនធានមនុស្ស បច្ចេកទេស និងធនធានហិរញ្ញវត្ថុ។
- ត្រូវបញ្ជ្រាបការយល់ដឹងអំពីសិទ្ធិជនពិការក្នុងចំណោមប្រជាជន ជាពិសេសអ្នកដែលរស់នៅតាមតំបន់ជនបទឱ្យបានទូលំទូលាយជាងមុន។ ទីមួយ ដើម្បីឱ្យអ្នកដែលមានកូនពិការអាចស្វែងរកជំនួយឱ្យបានតាមតម្រូវការ។ ទីពីរ ដើម្បីផ្លាស់ប្តូរផ្នត់គំនិតដែលគិតអវិជ្ជមានទៅលើជនពិការ។
- ត្រូវផ្តល់អាទិភាពដល់ការកសាងសមត្ថភាពរបស់ជនពិការ ក្នុងការបង្កើតប្រាក់ចំណូល ការងារ ការអប់រំ និងឱកាសផ្សេងៗទៀត ដើម្បីលើកកម្ពស់ការបញ្ចូលសង្គមនិងជីវភាពរស់នៅឱ្យប្រសើរឡើង។
- ជម្រុញការអនុវត្ត ការបង្កភាពងាយស្រួលសម្រាប់ជនពិការ នៅពេលមានការកសាងអគារផ្សេងៗជាពិសេសអគារនិងបន្ទប់ទឹកសាធារណៈជាដើម (មានជម្រាលតាមមាត្រដ្ឋានស្តង់ដារទំហំកន្លែងអាចរទេះរុញចេញចូលបាន...)។

# ឯកសារយោង

# ឯកសារយោង

- **ឯកសារជាភាសាខ្មែរ**


I. **ច្បាប់ និង លិខិតគតិយុត្តជាតិ**

1. *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា*, ១៩៩៣.
2. រាជរដ្ឋាភិបាលកម្ពុជា, *ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ,* ២០០៩.
3. ក្រសួងមហាផ្ទៃ, *អភិបាលកិច្ចល្អ*, បោះពុម្ពលើកទី២, ២០១០.
4. រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ,* ២០១១.
5. រាជរដ្ឋាភិបាលកម្ពុជា, *ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨,* ២០១២.
6. រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣*, ២០១៣.
7. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, *ផែនការយុទ្ធសាស្ត្រ២០១៤-២០១៨.*
8. ក្រសួងសុខាភិបាល, *ផែនការយុទ្ធសាស្ត្រស្តីពីសុខាភិបាល២០០៨-២០១៥.*
9. ក្រសួងអប់រំ យុវជន និងកីឡា, *ផែនការយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៤-២០១៨.*
10. ក្រសួងកិច្ចការនារី, *ផែនការយុទ្ធសាស្ត្រ២០០៩-២០១៣.*
11. ក្រសួងកិច្ចការនារី, *ផែនការយុទ្ធសាស្ត្រ២០១៤-២០១៨.*

II. **បទដ្ឋានគតិយុត្តអន្តរជាតិ**

12. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា, *ច្បាប់សិទ្ធិ មនុស្សកម្ពុជា,* ២០០៨.
13. អង្គការសហប្រជាជាតិ, យុទ្ធសាស្ត្រអ៊ីនឈាន់៖ ធ្វើឱ្យសិទ្ធិក្លាយជាការពិតសម្រាប់ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក, ២០១២.

III. **សៀវភៅ**

14. ឯកសារបច្ចេកទេសស្តីពីវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់សម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ២០១២.
15. ក្រសួងមហាផ្ទៃ យូនីសេហ្វ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអូស្ត្រាលី, *សៀវភៅណែនាំសម្រាប់គ្រូបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលពិការភាព ទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ,* ២០១៦.

16. ក្រសួងមហាផ្ទៃ យូនីសេហ្វ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអូស្ត្រាលី, *សៀវភៅណែនាំសម្រាប់អ្នកចូលរួមស្តីពីការដាក់បញ្ចូលពិការភាពទៅក្នុងអភិបាលកិច្ចនៅរដ្ឋបាលឃុំ សង្កាត់*, ២០១៧.
17. សេចក្តីណែនាំអំពីការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់, ២០១៧.

IV. **របាយការណ៍**

18. ក្រុមប្រឹក្សាសកម្មភាពជនពិការ, *របាយការណ៍ប្រចាំឆ្នាំ២០១១*.

- **ឯកសារជាភាសាបរទេស**

19. Socheata Sann, *Developing Effective Policies to Reduce Disability from Road Crashes in Cambodia*, 2017.
20. Sheree Bailey AM and Sophak Kanika Nguon, Situation Analysis for Disability-Inclusive Governance and Community Development in Cambodia, 2014.
21. UN, Joint Programme Doucument: *Disability Rights Initiative Cambodia .*
22. Pauline Kleinitz, Fareen Walji, Kong Vichetra, Ouch Nimul, and Priya Mannava: Working Paper, *Barriers to and Facilitators of Health Services for People with Disabilities in Cambodia*, 2012.
23. Centre for International Law and Justice, *Mental Health and Human Rights in Cambodia*, 2012.

- **គេហទំព័រ**

24. ក្រុមប្រឹក្សាសកម្មភាពជនពិការ, http://dac.org.kh/kh/
25. UNDP, Sustainable Development Goals, http://www.undp.org/content/undp/en/home/sustainable-development-goals.html
26. វិទ្យុបារាំងអន្តរជាតិ, http://km.rfi.fr/
27. http://www.urccambodia.org/site/index.php?lang=kh
28. វិទ្យាស្ថានជាតិស្ថិតិ, https://www.nis.gov.kh

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៩ អនក្រ

## សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពជាតិ ស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម សម្រាប់រយៈពេល ០៣ ឆ្នាំ (២០០៩-២០១១)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការ ដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មមាត្រា៤ មាត្រា៥ និងមាត្រា១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល សំរាប់ការអភិវឌ្ឍន៍ជាតិលើវិស័យពិការភាព

## សម្រេច

**ប្រការ ១:** ត្រូវបានដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពជាតិ ស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម សម្រាប់រយៈពេល ០៣ ឆ្នាំ (២០០៩-២០១១)

**ប្រការ ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អគ្គលេខាធិការអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន រដ្ឋមន្ត្រីគ្រប់ក្រសួង និងគ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធ២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥០ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសម្របសម្រួលលើវិស័យពិការភាព

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មមាត្រា ៤ មាត្រា ១០ និងមាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ១០០ អនក្រ/បក ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០៥ ស្តីពី វិសោធនកម្ម ជំពូកទី ៤ ជំពូកទី ៥ ជំពូកទី ៦ ជំពូកទី ៧ ជំពូកទី ៨ ជំពូកទី ១៣ និងជំពូកទី ១៥ នៃអនុក្រឹត្យលេខ ៧៦ អនក្រ/បក ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ/បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលសំរាប់ការអភិវឌ្ឍន៍ជាតិលើវិស័យពិការភាព

# ស ម្រេ ច

ប្រការ ១ :

បង្កើត **គណៈកម្មាធិការជាតិសម្របសម្រួលលើវិស័យពិការភាព** មានអក្សរកាត់ថា " **គ.ជ.ស.ព** " ជាភាសាអង់គ្លេស NATIONAL DISABILITY COORDINATION COMMITTEE មានអក្សរកាត់ថា " NDCC " ដែលមានបេសកកម្ម ពិនិត្យតាមដាន សម្របសម្រួល វាយតម្លៃ និងជំរុញលើការងារអនុវត្តផែនការសកម្មភាពជាតិ ស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារមីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម និងបញ្ហាសំខាន់ៗ ពាក់ពន្ធ័នឹងពិការភាព ។

ប្រការ ២ :

**គ.ជ.ស.ព** មានសមាសភាព ៖

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ជាប្រធាន |
| ២- អគ្គលេខាធិការ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន | | ជាអនុប្រធាន |
| ៣- រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | ជាអនុប្រធាន |
| ៤- អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល | ០១ រូប | ជាសមាជិក |
| ៥- អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | ០១ រូប | ជាសមាជិក |
| ៦- អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និង កីឡា | ០១ រូប | ជាសមាជិក |
| ៧- អនុរដ្ឋលេខាធិការ ក្រសួងផែនការ | ០១ រូប | ជាសមាជិក |
| ៨- អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | ០១ រូប | ជាសមាជិក |
| ៩- អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១ រូប | ជាសមាជិក |
| ១០- នាយក ក្រុមប្រឹក្សាសកម្មភាពជនពិការ | ០១ រូប | អ្នកសម្របសម្រួល |
| ១១- នាយក មជ្ឈមណ្ឌលជាតិសំរាប់ជនពិការ | ០១ រូប | ជាសមាជិក |
| ១២- នាយក អង្គការជនពិការកម្ពុជា | ០១ រូប | ជាសមាជិក |
| ១៣- តំណាងដៃគូអភិវឌ្ឍន៍ | ០១ រូប | ជាសមាជិក |
| ១៤- តំណាងទីភ្នាក់ងារអង្គការសហប្រជាជាតិ | ០១ រូប | ជាសមាជិក |
| ១៥- ប្រធាននៃអនុគណៈកម្មាធិការជំនាញទាំងប្រាំមួយ | ០៦ រូប | ជាសមាជិក ។ |

ប្រការ ៣ :

ក្រុមប្រឹក្សាសកម្មភាពជនពិការ **គ.ស.ព** ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ សម្របសម្រួលលើវិស័យពិការភាព និងជាអនុគណៈកម្មាធិការជំនាញនានា ដែលមានទីតាំងនៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ប្រការ ៤ :

**គ.ជ.ស.ព** ត្រូវបើកអង្គប្រជុំយ៉ាងតិចមួយដងក្នុងរយៈពេលបីខែ ។ បើចាំបាច់គណៈកម្មាធិការនេះ អាចបើកអង្គប្រជុំបានគ្រប់ពេល តាមការអញ្ជើញរបស់ប្រធាន ឬលេខាធិការដ្ឋាន ។

**គ.ជ.ស.ព** ប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬលេខាធិការដ្ឋាន ។

ប្រការ ៥ :

**គ.ជ.ស.ព** មានភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យតាមដាន សម្របសម្រួល វាយតម្លៃ និងជំរុញលើការអនុវត្តន៍ផែនការសកម្មភាពជាតិស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារមីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ឆ្នាំ ២០០៩-២០១១ ។
- បង្កើតគោលនយោបាយនានា ដើម្បីកែលំអការសម្របសម្រួលវិស័យពិការភាព និងការផ្តល់សេវាឱ្យកាន់តែមានប្រសិទ្ធភាព ។
- គាំទ្រ និងសហប្រតិបត្តិការជាមួយក្រសួង និងស្ថាប័នពាក់ពន្ធ័នានា ដើម្បីបង្កើតនូវគោលនយោបាយនានា នៃការបញ្ចូលពិការភាព និងសេវាកម្មទៅក្នុងគ្រប់វិស័យទាំងអស់ ។
- ទំនាក់ទំនងជាមួយនិងក្រសួងពាក់ពន្ធ័ អង្គការផ្តល់សេវាកម្ម និងភ្នាក់ងារម្ចាស់ជំនួយនានា ដើម្បីផលប្រយោជន៍ដល់ជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារមីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ។
- ប្រមូលរបាយការណ៍ពីសកម្មភាព និងកម្មវិធីនានាលើវិស័យពិការភាព ពីបណ្តាក្រសួងពាក់ពន្ធ័ អង្គការផ្តល់សេវាកម្មនានា អនុគណៈកម្មការ និងភ្នាក់ងារដទៃទៀត ។
- ជួយបំពេញកាតព្វកិច្ចចំពោះមជ្ឈដ្ឋានអន្តរជាតិ រួមបញ្ចូលអនុសញ្ញាស្តីពីការហាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីន និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ និង ពិធីសារបន្ថែម ក្រោយពីព្រះរាជាណាចក្រកម្ពុជាផ្តល់សច្ចាប័ន ។
- ជួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តន៍ច្បាប់ស្តីពីកិច្ចការពារ និងការលើកកំពស់សិទ្ធិជនពិការ ដែលត្រូវបានអនុម័ត ។
- ជួយធ្វើការកំណត់ និងកៀងគរប្រភពធនធាននានាសម្រាប់សកម្មភាពវិស័យពិការភាព រួមបញ្ចូលកិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ។

- ពិនិត្យតាមដាន សម្របសម្រួល វាយតម្លៃ និងសម្រេចលើបទដ្ឋានការងាររបស់អនុគណៈកម្មាធិការនីមួយៗ ។
- ឆ្លើយតបចំពោះការផ្តល់អនុសាសន៍នានារបស់អនុគណៈកម្មាធិការ ។

ប្រការ ៦ :

**គ.ជ.ស.ព** អាច ៖

- បង្កើតអនុគណៈកម្មាធិការជំនាញមួយចំនួនដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួនតាមការចាំបាច់ ។
- សមាសភាព និងភារកិច្ចរបស់អនុគណៈកម្មាធិការជំនាញនីមួយៗត្រូវកំណត់ដោយបទដ្ឋានការងារដោយឡែក ដែលសម្រេចដោយប្រធាននៃ **គ.ជ.ស.ព** ។

ប្រការ ៧ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អគ្គលេខាធិការអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២ និង ៧*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០៧ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ០៨អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥២អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥៥អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៨៩អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារស្រប តាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណង ដូចតទៅ ៖

- ជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងកម្មវិធីនយោបាយរាជរដ្ឋាភិបាលចំពោះជនពិការ
- ផ្តល់ឱកាសការងារ លើកទឹកចិត្តដល់ជនពិការ ដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង ចូលបម្រើការងារ
- លើកកម្ពស់សេចក្តីថ្លៃថ្នូរ សុខុមាលភាព និងសិទ្ធិរបស់ជនពិការកម្ពុជាតាមរយៈការទទួលស្គាល់សមត្ថភាពជនពិការ ប្រសើរជាងការមើលឃើញតែពីការភាពរបស់ជនពិការ
- ចូលរួមបំពេញនូវកាតព្វកិច្ចរបស់កម្ពុជាជាហត្ថលេខីនៃអនុសញ្ញា និងកតិកាសញ្ញាដែលទាក់ទងសិទ្ធិមនុស្ស និងសិទ្ធិជនពិការ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមានកាតព្វកិច្ចក្នុងការជ្រើសរើសជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងចូលបម្រើការងារ។

**មាត្រា៤.-**

**ការសម្របសម្រួលសមស្របមានបន្ទុកធ្ងន់ធ្ងរហួសហេតុ** សំដៅដល់ការសម្របសម្រួលលើប្រភេទ និងលក្ខខណ្ឌការងារ ការហ្វឹកហ្វឺន ផ្នែកបរិស្ថាន ទីកន្លែងការងារ មធ្យោបាយ សម្ភារបរិក្ខារ ដែលហួសពីលទ្ធភាពរបស់ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល។

## ជំពូកទី២
## ការកំណត់អត្រាជនពិការចូលបម្រើការងារ

**មាត្រា៥.-**

ក្រសួង ស្ថាប័នរដ្ឋ ដែលមានមន្ត្រីរាជការ ចាប់ពី ៥០ (ហាសិប) នាក់ឡើងទៅ ត្រូវតែមានជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងទៅតាមប្រភេទការងារ ដូចកំណត់តាមមាត្រា១១នៃអនុក្រឹត្យនេះ ចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការក្នុងអត្រា២ (ពីរ) ភាគរយ នៃចំនួនមន្ត្រីរាជការសរុប។

ការកំណត់ចំនួនជនពិការឲ្យចូលបម្រើការងារក្នុងកងយោធពលខេមរភូមិន្ទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា៦.-**

នីតិបុគ្គល ដែលមានកម្មករ និយោជិត ចាប់ពី ១០០ (មួយរយ) នាក់ឡើងទៅ ត្រូវមានជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងទៅតាមប្រភេទការងារ ដូចកំណត់តាមមាត្រា១១នៃអនុក្រឹត្យនេះ ក្នុងអត្រា ១ (មួយ) ភាគរយ នៃចំនួនកម្មករ និយោជិតសរុប។

**មាត្រា៧.-**

ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមានមន្ត្រីរាជការ និងកម្មករ និយោជិតតិចជាងចំនួនដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ហើយបានជ្រើសរើសជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងចូលបម្រើការងារ ត្រូវទទួលបានការលើកទឹកចិត្តដូចមានចែងក្នុងមាត្រា១៧ នៃអនុក្រឹត្យនេះ។

**មាត្រា៨.-**

វិធីសាស្ត្រនៃការគណនាជនពិការស្របតាមលក្ខណវិនិច្ឆ័យ ប្រភេទ និងកម្រិតនៃពិការភាពដូចកំណត់ក្នុងមាត្រា៣០នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការត្រូវអនុវត្តដូចខាងក្រោម៖

| ប្រភេទការងារ | ប្រភេទពិការភាព | កម្រិតពិការភាព | គណនាចំនួន |
|---|---|---|---|
| មន្ត្រីរាជការ និយោជិត បម្រើការងារពេញម៉ោង | ជនពិការកាយសម្បទា | ធ្ងន់ | ជនពិការ១នាក់ត្រូវគិតជា២នាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |
| | ជនពិការកាយសម្បទា | ស្រាល មធ្យម | ជនពិការ១នាក់ត្រូវគិតជា១នាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |
| និយោជិត បម្រើការងាររយៈពេលខ្លី | ជនពិការកាយសម្បទា | ធ្ងន់ | ជនពិការ១នាក់ត្រូវគិតជា១នាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |
| | ជនពិការកាយសម្បទា | ស្រាល មធ្យម | ជនពិការ១នាក់ត្រូវគិតជាកន្លះនាក់ |
| | ជនពិការសតិបញ្ញា ដែលបានស្តារនីតិសម្បទា | | |

## ជំពូកទី៣
## បែបបទជ្រើសរើស

**មាត្រា៥.-**

ក្រសួង ស្ថាប័នរដ្ឋ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ នៅក្នុងខែមករា ជារៀងរាល់ឆ្នាំ អំពី ៖

- ចំនួនមន្ត្រីរាជការសរុប លើកលែងកងកម្លាំងប្រដាប់អាវុធ
- ចំនួនជនពិការ ដែលគ្រោងនឹងជ្រើសរើស តាមអត្រាកំណត់
- ចំនួនមន្ត្រីរាជការជាជនពិការកាយសម្បទា កម្រិតស្រាល មធ្យម
- ចំនួនមន្ត្រីរាជការជាជនពិការកាយសម្បទា កម្រិតធ្ងន់
- ចំនួនមន្ត្រីរាជការជាជនពិការសតិបញ្ញា កម្រិតស្រាល មធ្យម
- ចំនួនមន្ត្រីរាជការជាជនពិការសតិបញ្ញា កម្រិតធ្ងន់។

ក្នុងករណី ក្រសួង ស្ថាប័នរដ្ឋ ទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ឲ្យជ្រើសរើសក្របខណ្ឌមន្ត្រីរាជការចូលធ្វើការងារ ត្រូវកសាងផែនការជ្រើសរើសជនពិការតាមអត្រាកំណត់ ដូចមានចែងក្នុងមាត្រា៤ ខាងលើ ផ្ញើជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីទទួលបានគោលការណ៍អនុញ្ញាត ។

**មាត្រា១០.-**

នីតិបុគ្គល ដែលមានកម្មករ និយោជិត ចាប់ពី ១០០ (មួយរយ) នាក់ឡើងទៅ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរជាទៀងទាត់រៀងរាល់ឆ្នាំទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងខែមករា ជារៀងរាល់ឆ្នាំ អំពី ៖

- ចំនួនកម្មករ និយោជិត ធ្វើការពេញម៉ោង សរុប
- ចំនួនកម្មករ និយោជិតជាជនពិការ ដែលគ្រោងជ្រើសរើស តាមអត្រាកំណត់
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតស្រាល មធ្យម ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតធ្ងន់ ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតស្រាល មធ្យម ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតធ្ងន់ ធ្វើការពេញម៉ោង
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតស្រាល មធ្យម ធ្វើការរយៈពេលខ្លី
- ចំនួនកម្មករ និយោជិតជាជនពិការកាយសម្បទាកម្រិតធ្ងន់ ធ្វើការរយៈពេលខ្លី
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតស្រាល មធ្យម ធ្វើការរយៈពេលខ្លី
- ចំនួនកម្មករ និយោជិតជាជនពិការសតិបញ្ញាកម្រិតធ្ងន់ ធ្វើការរយៈពេលខ្លី ។

ក្នុងករណីដែលនីតិបុគ្គលជ្រើសរើសកម្មករ និយោជិត ជាជនពិការកាយសម្បទា ឬសតិបញ្ញា ចូលធ្វើការមិនទាន់គ្រប់ចំនួនតាមអត្រាកំណត់ ដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវកសាងផែនការជ្រើសរើសឡើងវិញ ផ្ញើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមុនដំណាច់ខែធ្នូនៃឆ្នាំ។

**មាត្រា១១.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់ប្រភេទការងារ ដែលជនពិការអាចធ្វើបាន ផ្ញើជូនគ្រប់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលដែលមានកាតព្វកិច្ចជ្រើសរើសជនពិការចូលបម្រើការងារ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយ ជាសាធារណៈ។

**មាត្រា១២.-**

កាលបរិច្ឆេទនៃការប្រឡងជ្រើសរើសណាមួយ ដែលអាចមានជនពិការកាយសម្បទា ឬសតិបញ្ញាដែលមានលក្ខណសម្បត្តិ និងសមត្ថភាព ឲ្យចូលក្នុងក្របខណ្ឌមន្ត្រីរាជការ ត្រូវកំណត់ និងផ្សព្វផ្សាយយ៉ាងតិច ៣ (បី) ខែមុនថ្ងៃបើកឲ្យចូលប្រឡង។ ក្នុងករណីដែលមានការប្រញាប់ ការផ្សព្វផ្សាយត្រូវធ្វើយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ។

ចំពោះការជ្រើសរើសចូលបម្រើការងារក្នុងសហគ្រាស គ្រឹះស្ថាន និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវផ្សព្វផ្សាយយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ។

**មាត្រា១៣.-**

គ្រប់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមិនទាន់មានជនពិការ ដែលមានលក្ខណសម្បត្តិ និងសមត្ថភាព បំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងតាមអត្រាកំណត់ ដូចមានចែង

មាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវកសាងផែនការប្រឡងជ្រើសរើសបំពេញបន្ថែម ឲ្យបានគ្រប់ចំនួនក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ឆ្នាំ។

ការកសាងផែនការជ្រើសរើសបំពេញបន្ថែម ត្រូវធ្វើជារៀងរាល់ឆ្នាំ។ ក្នុងមួយឆ្នាំៗ ត្រូវជ្រើសរើសឲ្យបានយ៉ាងតិច ៣០ (សាមសិប) ភាគរយ នៃគម្រោងផែនការជ្រើសរើសសរុបរយៈពេល ៣ (បី) ឆ្នាំ។

## ជំពូកទី៤
## ភាតព្វកិច្ច និងការសម្របសម្រួលសមស្រប

**មាត្រា១៤.-**

ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវមានកាតព្វកិច្ចធ្វើការសម្របសម្រួលសមស្រប សម្រាប់មន្ត្រីរាជការ កម្មករ និយោជិត ឬកូនជាង ឬកម្មសិក្សាការីជាជនពិការ ជាអាទិ៍ ការសម្របសម្រួលលើប្រភេទ និងលក្ខខណ្ឌការងារ ការហ្វឹកហ្វឺន ផ្នែកបរិស្ថាន ទីកន្លែងការងារ មធ្យោបាយ សម្ភារបរិក្ខារ លើកលែងតែ ការសម្របសម្រួលសមស្រប មានបន្ទុកធ្ងន់ធ្ងរហួសហេតុ។

## ជំពូកទី៥
## ការបង់ភាគទាន ការលើកទឹកចិត្ត និងការពិន័យ

**មាត្រា១៥.-**

ប្រធានក្រសួង ស្ថាប័នរដ្ឋ ដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ ត្រូវបង់ភាគទានចូលហិបមូលនិធិជនពិការជាប្រាក់ស្មើនឹង៥០ (ហាសិប) ភាគរយ នៃប្រាក់បៀវត្សមូលដ្ឋានប្រចាំខែរបស់មន្ត្រីរាជការក្នុងមួយខែតាមប្រភេទក្របខណ្ឌ សម្រាប់មន្ត្រីរាជការជាជនពិការ ១ (មួយ) នាក់។

នីតិបុគ្គល ដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវបង់ភាគទានចូលហិបមូលនិធិជនពិការជាប្រាក់ស្មើនឹង ៤០ (សែសិប) ភាគរយ នៃប្រាក់បៀវត្សអប្បបរមាប្រចាំខែរបស់កម្មករ និយោជិត ក្នុងមួយខែ សម្រាប់កម្មករ និយោជិតជាជនពិការ ១ (មួយ) នាក់។

**មាត្រា១៦.-**

ការបង់ភាគទាន ដូចមានចែងក្នុងមាត្រា១៥ ខាងលើត្រូវអនុវត្តតាមនីតិវិធី ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិជនពិការ។

**មាត្រា១៧.-**

ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលបានបំពេញកាតព្វកិច្ចលើសអត្រាកំណត់ ដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវទទួលបានការលើកសរសើរ និង/ឬការលើកទឹកចិត្ត[illegible]ក្រសួង

តាមច្បាប់ជាធរមាន ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិជនពិការ។

**មាត្រា១៨.-**

ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៥ មាត្រា៦ និងមាត្រា១៥ នៃ អនុក្រឹត្យនេះ ហើយមិនព្រមបង់ភាគទានចូលហិបមូលនិធិជនពិការ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចមានចែងក្នុងមាត្រា៥៤ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

ក្នុងករណីមិនគោរពតាមកថាខណ្ឌខាងលើ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា៥៦ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គលត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ៤



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ សរសេរកាត់ថា **ម.ជ.ព.** ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២.-**

**ម.ជ.ព.** ជានីតិបុគ្គល និងមានស្វ័យភាពហិរញ្ញវត្ថុ។

**ម.ជ.ព.** មានទីស្នាក់ការកណ្តាលនៅមជ្ឈមណ្ឌលជាតិស្តារលទ្ធភាពពលកម្មជនពិការគៀនឃ្លាំង ស្ថិតនៅភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ **ម.ជ.ព.**។

**មាត្រា៣.-**

**ម.ជ.ព.** មានភារកិច្ចជាអាទិ៍ ដូចតទៅ ៖

- ផ្តល់សេវាស្តារលទ្ធភាពពលកម្ម ជូនជនពិការ
- គ្រប់គ្រងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ជូនជនពិការ
- ផ្តល់មូលនិធិ សម្រាប់ការអនុវត្តគម្រោងកម្មវិធីផ្សេងៗ ដែលជួយដល់ជនពិការ និងគាំទ្រដល់ស្ថាប័ន គ្រឹះស្ថាននានា ដែលផ្តល់សេវាកម្មដល់ជនពិការ ដូចជា ផ្នែកសុខាភិបាល ស្តារលទ្ធភាពពលកម្ម អប់រំ បណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងការរកការងារឲ្យធ្វើ
- លើកកម្ពស់ និងបង្កើនសុខុមាលភាពជនពិការ
- ធ្វើសមាហរណកម្មជនពិការទៅក្នុងសហគមន៍
- គ្រប់គ្រងថវិកាដែលទទួលបានពីការឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ប្រភពហិរញ្ញប្បទាន សហប្រតិបត្តិការពីដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលនានា និងទទួលអំណោយសប្បុរសធម៌ពីសប្បុរសជន និងផលចំណេញពីការវិនិយោគ និងអាជីវកម្មស្របច្បាប់
- ប្រមូលភាគទាន ប្រាក់ពិន័យអន្តរការណ៍ និងប្រាក់ពិន័យផ្សេងៗទៀត ពីប្រធានស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមិនអាចបំពេញតាមកាតព្វកិច្ច ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បំផុសលើកទឹកចិត្តពលរដ្ឋ សប្បុរសជនផ្នែកឯកជន និងអង្គការ[illegible]ម្ភដល់ជនពិការ

- រៀបចំគោលនយោបាយផ្គត់ផ្គង់ និងឧបត្ថម្ភដល់ជនពិការ
- រៀបចំហិរញ្ញវត្ថុប្រាក់វិភាគទានសប្បុរសធម៌ សម្រាប់ជនពិការ
- រៀបចំឲ្យមានមូលនិធិ សម្រាប់សេវាកម្មផ្សេងៗ ជាប្រយោជន៍ដល់ជនពិការ
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិនៃ **ម.ជ.ព.**
- ស្រាវជ្រាវបច្ចេកទេស និងបណ្តុះបណ្តាលធនធានមនុស្សក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ
- ធ្វើសហប្រតិបត្តិការនានា ក្រោមការណែនាំពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី ២
## ការដឹកនាំ និងការគ្រប់គ្រងរបស់ ម.ជ.ព.
## ផ្នែកទី ១
## ក្រុមប្រឹក្សាភិបាលរបស់ ម.ជ.ព.

**មាត្រា៤.-**

**ម.ជ.ព.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិទូលំទូលាយ ដើម្បីចាត់ចែងការងារក្នុងក្របខណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ព.**។

**មាត្រា៥.-**

៥.១. ក្រុមប្រឹក្សាភិបាលមានសមាជិក ៩ (ប្រាំបួន) រូប ដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងអង្គការជនពិការ ដែលជាជនពិការ | សមាជិក |
| - លេខាធិការក្រុមប្រឹក្សាសកម្មភាពជនពិការ | សមាជិក |
| - ប្រធានរដ្ឋបាលសិទ្ធិជនពិការ | សមាជិក |
| - ឥស្សរជនដែលមានចំណេះដឹង និងបទពិសោធខាងវិស័យសង្គមកិច្ច | សមាជិក |
| - នាយក **ម.ជ.ព.** | សមាជិក |
| - តំណាងបុគ្គលិកនៃ **ម.ជ.ព.** | សមាជិក។ |

៥.២.តំណាងបុគ្គលិកនៃ**ម.ជ.ព.** ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក**ម.ជ.ព.** សម្រាប់អាណត្តិនីមួយៗ។

៥.៣.ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យ សម្រាប់អាណត្តិ ៣ (បី) ឆ្នាំ និងអាចបន្តបានទៀត តាមសំណើរបស់ក្រសួង ឬស្ថាប័ន ដែលសមាជិក នោះជាតំណាង។

៥.៤.អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលាដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ឬស្ថាប័ន ដែលសមាជិកនោះជាតំណាង។

**មាត្រា៦.-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបម្រើការងារយ៉ាង តិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានបទពិសោធគ្រប់គ្រាន់ មានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលបានទទួលទណ្ឌកម្មពីបទមជ្ឈិម ឬបទឧក្រិដ្ឋឡើយ។

**មាត្រា៧.-**

៧.១.ប្រធានក្រុមប្រឹក្សាភិបាលមានភារកិច្ចកោះប្រជុំនិងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

៧.២.ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធលើវិស័យវិទ្យាសាស្ត្រសេដ្ឋកិច្ច សង្គមកិច្ច និងតំណាងដៃគូអភិវឌ្ឍឲ្យចូលរួមអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

**មាត្រា៨.-**

ក្រុមប្រឹក្សាភិបាលនៃ **ម.ជ.ព.** មានបេសកកម្មដឹកនាំ តម្រង់ទិស និងត្រួតពិនិត្យដំណើរការរបស់ **ម.ជ.ព.**។ ក្នុងក្របខណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

- ពិនិត្យ និងសម្រេចលើគម្រោងផែនការអភិវឌ្ឍនៃ **ម.ជ.ព.** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និងសម្រេចលើគម្រោងផែនការសកម្មភាពនៃ **ម.ជ.ព.**
- ពិនិត្យ និងសម្រេចលើចំណូល និងចំណាយប្រចាំឆ្នាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ព.**
- ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពីការងារគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងការបែងចែកភារកិច្ចជាទូទៅដល់គ្រប់ការិយាល័យ និងអង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍតាមការចាំបាច់របស់ **ម.ជ.ព.**
- កំណត់បែបបទនៃការជ្រើសរើស ការដំឡើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក **ម.ជ.ព.** ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះមន្ត្រីមុខងារសាធារណៈ
- សម្រេចលើក្របខណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសម្រាប់ **ម.ជ.ព.**
- សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្មសាធារណៈ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ

- កែសម្រួលបទបញ្ជាផ្ទៃក្នុងនៃ ម.ជ.ព. ដោយមានការយល់ព្រមពីប្រធានស្ថាប័ន ឬ ក្រសួងអាណាព្យាបាលទាំងពីរ
- វាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ ម.ជ.ព. ហើយកំណត់វិធានការកែតម្រូវដើម្បីអនុវត្ត។

**មាត្រា៩.-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា១០.-**

១០.១.ក្រុមប្រឹក្សាភិបាលនៃ ម.ជ.ព. ត្រូវធ្វើការប្រជុំយ៉ាងតិច ៣ (បី) ខែម្តង តាមគំនិតផ្តួចផ្តើម និងការអញ្ជើញរបស់ប្រធាន ឬតាមការស្នើរបស់សមាជិកចំនួន ២/៣ (ពីរភាគបី) ឡើងទៅ ឬតាមការស្នើសុំរបស់នាយក ម.ជ.ព.។ ក្នុងករណីមានធុរៈ ប្រធានត្រូវផ្ទេរសិទ្ធិជូនសមាជិកណាម្នាក់ក្នុងចំណោមសមាជិកក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ១ (មួយ) រូប ដែលមិនមែនជាសមាជិកនៃក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ។

របៀបវារៈព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ។

១០.២.ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានចំនួនសមាជិកលើសពី ៥០ (ហាសិប) ភាគរយនៃចំនួនសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឲ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឲ្យមានកូរ៉ុមគ្រប់ចំនួនឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញលើកមុន។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំមានឧត្តមានុភាព។

១០.៣.សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ការរបស់ ម.ជ.ព. និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះត្រូវបង្ហាញអត្ថន័យនៃការពិភាក្សាឲ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ.១០ (ដប់) ថ្ងៃក្រោយពេលប្រជុំ។

១០.៤.ម.ជ.ព. ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដែល

- កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់ ម.ជ.ព.
- គម្រោងថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។

១០.៥.ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនហួសពី ១៥ (ដប់ប្រាំ) ថ្ងៃ។

## ផ្នែកទី ២

## អង្គភាពប្រតិបត្តិរបស់ ម.ជ.ព.

**មាត្រា១១.-**

ម.ជ.ព. ត្រូវគ្រប់គ្រងដោយនាយកមួយរូបដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នាយកមានតួនាទីជានាយកប្រតិបត្តិ។

**មាត្រា១២.-**

១២.១.នាយក ម.ជ.ព. មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។

នាយក ម.ជ.ព. មានភារកិច្ច ៖

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍ និងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ព.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ម.ជ.ព.** ក្នុងការកម្រិតក្របខណ្ឌចំនួនបុគ្គលិកដែលកំណត់ដោយ ក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ **ម.ជ.ព.** ដែលក្រុមប្រឹក្សាភិបាលកំណត់តាមការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឲ្យដំណើរការនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

១២.២. នាយក **ម.ជ.ព.** ជាតំណាងរបស់មូលនិធិជនពិការ ក្នុងការទាក់ទងជាមួយតតិយជន។

១២.៣.នាយក **ម.ជ.ព.** ត្រូវស្នើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សុំតែងតាំងនាយករង មួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។ នាយក និងនាយករងត្រូវមានចំណេះដឹងលើផ្នែកគ្រប់គ្រង។

## ផ្នែកទី ៣
## បុគ្គលិករបស់ ម.ជ.ព.

**មាត្រា១៣.-**

១៣.១ បុគ្គលិកអចិន្ត្រៃយ៍របស់ ម.ជ.ព. មានមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬមកពីក្រសួងស្ថាប័នផ្សេងទៀត។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកក្របខណ្ឌ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ដែលកំណត់ដោយមុខងារសាធារណៈ ពីអង្គភាពដើមរបស់ខ្លួន។

១៣.២. ម.ជ.ព. អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្តែត ។ បុគ្គលិកទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ។

១៣.៣.បុគ្គលិក ម.ជ.ព. ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីការគ្រប់គ្រងបុគ្គលិកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ចំពោះមន្ត្រីនៃមុខងារសាធារណៈ បទបញ្ជានេះមិនត្រូវផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់ប្រាក់កម្រៃ លើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង។

## ផ្នែកទី ៤
## រចនាសម្ព័ន្ធរបស់ ម.ជ.ព.

**មាត្រា១៤.-**

រចនាសម្ព័ន្ធរបស់ ម.ជ.ព. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ ម.ជ.ព.។

## ផ្នែកទី ៥
## ទ្រព្យសម្បត្តិរបស់ ម.ជ.ព.

**មាត្រា១៥.-**

១៥.១.ម.ជ.ព.ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនទ្រព្យដែលមានបញ្ជាក់ក្នុងបញ្ជីសារពើភណ្ឌចុងក្រោយដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ។

១៥.២. ម.ជ.ព. អាចទិញ ប្តូរ ឬលក់ចលនទ្រព្យ អចលនទ្រព្យចាំបាច់សម្រាប់ដំណើរការមូលនិធិបានដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន។

## ជំពូកទី ៦
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ម.ជ.ព.

**មាត្រា១៦.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ម.ជ.ព. ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ។

**មាត្រា១៧.-**

១៧.១.នាយក ម.ជ.ព. ជាអាណាប័កដើមខ្សែរបស់មូលនិធិជនពិការហើយត្រូវមានភារកិច្ចៈ

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ។

១៧.២.អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិ ឬអាចបង្កើតនូវវដ្តទេយ្យចំណូល ឬបុរេប្រទានបានដោយមានការព្រមព្រៀងពីគណនេយ្យករ ម.ជ.ព.។

**មាត្រា១៨.-**

១៨.១.ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ ម.ជ.ព. ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ គណនេយ្យករនេះត្រូវទទួលខុសត្រូវចំពោះមុខនាយក ម.ជ.ព.និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកពិគ្រោះយោបល់តែឥតមានសំឡេងឆ្នោតឡើយ។

១៨.២. គណនេយ្យករមានភារកិច្ច ៖

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- ថែរក្សា និងចាត់ចែងប្រើប្រាស់មូលនិធិ និងធនធានរបស់ ម.ជ.ព.
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ។

១៨.៣. គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឲ្យអាជ្ញានុការីរបស់ខ្លួន។

**មាត្រា១៩.-**

១៩.១. ប្រភពធនធានរបស់ ម.ជ.ព. រួមមាន ៖

- ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ ម.ជ.ព. នៅពេលផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធនដែលមានចែងក្នុងថវិកាជាតិ
- អំណោយ ជំនួយ និងអច្ច័យទានដែល ម.ជ.ព. បានទទួល
- ប្រាក់ខ្ចីដោយផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុគលឲ្យ ម.ជ.ព.



- ផលការងារ និងកម្រៃនៃការផ្តល់សេវាផ្សេងៗ ដោយ ម.ជ.ព.
- កម្រៃនៃទ្រព្យរបស់ ម.ជ.ព. និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលត្រូវបានទទួលអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលត្រូវបានប្រគល់ឲ្យ ម.ជ.ព.
- ប្រាក់ចំណូលពីវិភាគទានដែលប្រមូលបានពីហិបប្រាក់វិភាគទានសប្បុរសធម៌សម្រាប់ជនពិការ
- ប្រាក់ភាគទាន ប្រាក់ពិន័យអន្តរការណ៍ និងប្រាក់ពិន័យផ្សេងៗទៀត ដូចមានចែងក្នុងមាត្រា ៣៧ និងមាត្រា ៥៥ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

១៩.២.ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ ម.ជ.ព. ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់មូលនិធិ។ ក្រុមប្រឹក្សាភិបាលរបស់ ម.ជ.ព. ត្រូវកំណត់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងនឹងទម្រង់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកាត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៩.៣.ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ ម.ជ.ព. ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឲ្យមានលំនឹងរវាងចំណូល និងចំណាយ។

១៩.៤.អនុលោមតាមមាត្រា ១៣ ខាងលើនេះ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ នៃមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈដែលមកបម្រើការងារក្នុង ម.ជ.ព. ជាបន្ទុកនៃថវិការដ្ឋ។

១៩.៥ ប្រាក់ឧបត្ថម្ភរបស់រដ្ឋដែលបានគ្រោងទុកក្នុងថវិកាជាតិ ដើម្បីផ្តល់ឲ្យ ម.ជ.ព. ត្រូវសំដៅជាពិសេសលើចំណាយថ្លៃទឹក និងថ្លៃអគ្គិសនី។

១៩.៦.សោហ៊ុយវិភាគ និងសោហ៊ុយដំណើរការសម្រាប់ស្រាវជ្រាវវិភាគចាំបាច់ផ្សេងៗ ត្រូវចែងក្នុងកិច្ចសន្យារវាងរដ្ឋ និង ម.ជ.ព. ដែលមានបញ្ជាក់ចំណែកដែលភាគីម្ខាងៗត្រូវរ៉ាប់រង។

**មាត្រា២០.-**

២០.១. ការងារគណនេយ្យរបស់ ម.ជ.ព. រួមមាន ៖

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគដែលចែងអំពីប្រតិបត្តិការថវិការតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យអសង្ហារិម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់។

គណនេយ្យរបស់ ម.ជ.ព. ត្រូវ ៖

- ស្របតាមវិធានការដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យរបស់ ម.ជ.ព. ដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះត្រូវបានយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២០.២. របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ **ម.ជ.ព.** ត្រូវរៀបចំដោយគណនេយ្យករ និងអាណាប័កដើមខ្សែដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី) ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

**មាត្រ២១.-**

មូលនិធិរបស់ **ម.ជ.ព.** គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅអគ្គនាយកដ្ឋានរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ផ្នែកទី ៧
## របបសារពើពន្ធរបស់ ម.ជ.ព.

**មាត្រា២២.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលមានចែងដោយច្បាប់ **ម.ជ.ព.** ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធ។

## ផ្នែកទី ៨
## លទ្ធកម្មរបស់ ម.ជ.ព.

**មាត្រា២៣.-**

ការសម្រេច ការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ **ម.ជ.ព.** ត្រូវគ្រប់គ្រងតាមច្បាប់ និងបទបញ្ញាទាំងឡាយជាធរមាន ដែលមានការពាក់ព័ន្ធនឹងកិច្ចការនេះ។

## ជំពូកទី ៣
## អាណាព្យាបាល
## ផ្នែកទី ១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា២៤.-**

២៤.១. ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពេលប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ នាយក **ម.ជ.ព.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃទទួលឯកសារដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរយៈពេល ២ (ពីរ) ខែ ចាប់ពីថ្ងៃទទួលឯកសារដែលបានបញ្ជូនដោយនាយក **ម.ជ.ព.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

២៤.២.លិខិតយល់ព្រមចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬតំណាងត្រូវផ្ញើជូនទៅនាយក ម.ជ.ព. ដោយមានចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នាយក ម.ជ.ព ត្រូវបញ្ជូនព័ត៌មាននេះ ទៅឲ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាទទួលបានការឯកភាព។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ដើម្បីពិភាក្សា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ។

កម្មវិធីអភិវឌ្ឍនៃ ម.ជ.ព. និងថវិកាចំណាយជាមូលធនមិនអាចឲ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

ថវិកាចំណាយជាប្រចាំអាចដាក់ឲ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះនៅពេលដែលមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា២៥.-**

២៥.១.រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចមានយោបល់ជំទាស់លើឯកសារដែលបានបញ្ជូនមកដូចមានចែងក្នុងមាត្រា ១០ ចំណុច ១០.៤ នៃអនុក្រឹត្យនេះ មានកំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរយៈពេល ១ ( មួយ ) ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ។

២៥.២.នាយក ម.ជ.ព. ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលអំពីខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាឲ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់នេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាការបាននូវការជំទាស់ទាំងនោះ សេចក្តីសម្រេច របស់ក្រុមប្រឹក្សាភិបាល ត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជាបន្ទាន់ភ្លាមនូវដំណឹងអំពីបញ្ហានេះជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា២៦.-**

២៦.១. រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចលុប ឬផ្អាកទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក ម.ជ.ព. ក្នុងករណីដែលសេចក្តីសម្រេចនោះ ៖

- ផ្ទុយនឹងគោលដៅរបស់ ម.ជ.ព.
- ផ្ទុយនឹងច្បាប់ និងបទបញ្ញា

- ធ្វើឡើងដោយអាជ្ញាធរមួយដែលពុំមានសិទ្ធិសម្រេច ឬធ្វើឡើងដោយការប្រជុំពុំស្របច្បាប់របស់ក្រុមប្រឹក្សាភិបាល។

២៦.២. ការលុបចោល ឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក **ម.ជ.ព.** ហើយនាយក **ម.ជ.ព.** ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា២៧.-**

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចចាត់ឲ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងាររបស់ **ម.ជ.ព.** ក្នុងករណីដែលយល់ថា ជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី ២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា២៨.-**

២៨.១. ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក **ម.ជ.ព.** ត្រូវផ្ញើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃទទួលឯកសារដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ២ (ពីរ) ខែ ចាប់ពីថ្ងៃទទួលឯកសារ ដែលបញ្ជូនមកដោយនាយក **ម.ជ.ព.** ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

២៨.២.លិខិតយល់ព្រមចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាងត្រូវផ្ញើទៅនាយក **ម.ជ.ព.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នាយក **ម.ជ.ព.** ត្រូវបញ្ជូនព័ត៌មាននេះទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឲ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ។ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

**មាត្រា២៩.-**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក ម.ជ.ព. ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួមមាន ៖

- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ
- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនទ្រព្យ។

សេចក្តីសម្រេចនេះ ត្រូវអនុលោមតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ១ (មួយ) រូប ប្រចាំម.ជ.ព.។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើ ម.ជ.ព. ស្របតាមអនុក្រឹត្យលេខ ៨១អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

**មាត្រា៣១.-**

៣១.១.ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែនៃ ម.ជ.ព. ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣១.២.ការគ្រប់គ្រងរបស់គណនេយ្យករត្រូវស្ថិត នៅក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាលនៃអគ្គនាយកដ្ឋានរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣១.៣.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើ ម.ជ.ព. នៅពេលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិជាធរមាន។



## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា៣២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១០
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ

## ទីតាំង និងផ្ទៃក្រឡាដីរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារាជធានី ខេត្ត

| ល.រ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា | ទីតាំង | | | | ទំហំផ្ទៃក្រឡាដី |
|---|---|---|---|---|---|---|
| | | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង/ខណ្ឌ | រាជធានី/ខេត្ត | |
| ១ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រៃវែង | ភូមិបារាយណ៍លិច | សង្កាត់បារាយណ៍ | ក្រុងព្រៃវែង | ខេត្តព្រៃវែង | ១៣ ៤៦៣ ម៉ែត្រក្រឡា |
| ២ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តតាកែវ | ភូមិ III | សង្កាត់រកាក្នុង | ក្រុងដូនកែវ | ខេត្តតាកែវ | ៤ ២៨២ ម៉ែត្រក្រឡា |
| ៣ | មជ្ឈមណ្ឌលស្តារស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តបាត់ដំបង | ចំការសំរោង | សង្កាត់ចំការសំរោង | ក្រុងបាត់ដំបង | ខេត្តបាត់ដំបង | ១៣ ៣៨៤ ម៉ែត្រក្រឡា |
| ៤ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ចាម | ភូមិទី ៧ | សង្កាត់កំពង់ចាម | ក្រុងកំពង់ចាម | ខេត្តកំពង់ចាម | ២ ៩១៨ ម៉ែត្រក្រឡា |
| ៥ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ឆ្នាំង | កណ្តាល | សង្កាត់កំពង់ឆ្នាំង | ក្រុងកំពង់ឆ្នាំង | ខេត្តកំពង់ឆ្នាំង | ១ ១២៨.៥២ ម៉ែត្រក្រឡា |
| ៦ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ធំ | ភូមិទី៧ | សង្កាត់កំពង់ធំ | ក្រុងស្ទឹងសែន | ខេត្តកំពង់ធំ | ៥៧៤ ម៉ែត្រក្រឡា |
| ៧ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រះវិហារ | គោកបេង | សង្កាត់កំពង់ប្រណាក | ក្រុងព្រះវិហារ | ខេត្តព្រះវិហារ | ១២ ៦០០ ម៉ែត្រក្រឡា |
| ៨ | មជ្ឈមណ្ឌលព្យាបាលរបួសខួរឆ្អឹងខ្នង | ចំការសំរោង | សង្កាត់ចំការសំរោង | ក្រុងបាត់ដំបង | ខេត្តបាត់ដំបង | ១០ ៣៩៤ ម៉ែត្រក្រឡា |
| ៩ | មជ្ឈមណ្ឌលជាតិស្តារលទ្ធភាពពលកម្មជនពិការគៀនឃ្លាំង | គៀនឃ្លាំង | សង្កាត់ជ្រោយចង្វារ | ខណ្ឌឫស្សីកែវ | ក្រសួងស.អ.យ | ២២ ៦[illegible] ម៉ែត្រក្រឡា |
| ១០ | សាលាបណ្តុះបណ្តាលអ្នកបច្ចេកទេសផលិតភាគៈឃរៈសិប្បនិម្មិត និងអវយវៈកម្ពុជា ភ្នំពេញ | គោកចំបក់ | សង្កាត់ចោមចៅ | ខណ្ឌដង្កោ | ក្រសួងស.អ.យ | ៤ ៦[illegible] ម៉ែត្រក្រឡា |

ឆ្នាំ ទី ១១ លេខ ៥០ សប្តាហ៍ទី ១ ថ្ងៃ ទី ០៨ ខែ កក្កដា ឆ្នាំ ២០១១ រាជកិច្ច ទំព័រ ៥១៦៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៣៧ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលដៅដូចតទៅៈ

- អនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- រួមចំណែកអនុវត្តយុទ្ធសាស្ត្រជាតិនិងគោលនយោបាយជាតិនានា ដែលទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រ
- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ជួយដល់ជនពិការក្រីក្រនៅតាមសហគមន៍
- ស្តារលទ្ធភាពពលកម្មនិងកសាងជីវភាពឡើងវិញដល់ជនពិការក្រីក្រនៅតាមសហគមន៍
- ទប់ស្កាត់ កាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថានរបស់ជនពិការក្រីក្រនៅតាមសហគមន៍ កាត់បន្ថយភាពអនាថា ការសុំទានតាមចិញ្ចើមថ្នល់នៃជនពិការក្រីក្រនៅតាមសហគមន៍
- ផ្តល់សេវាសង្គមកិច្ចដល់ជនពិការក្រីក្រនៅតាមសហគមន៍ឲ្យមានប្រសិទ្ធភាពខ្ពស់។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពចំពោះជនពិការដែលមានកម្រិតពិការភាពធ្ងន់ធ្ងរ ក្រីក្របំផុត និងគ្មានទីពឹង ជនពិការចាស់ជរា ក្រីក្របំផុត និងគ្មានទីពឹង ជនពិការមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្រីក្របំផុត និងគ្មានទីពឹង នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រ

**មាត្រា ៤.-**

ត្រូវបានបង្កើតគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ សម្រាប់ថ្នាក់រាជធានី ខេត្ត ដែលមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| - អភិបាលនៃគណៈអភិបាល រាជធានី ខេត្ត | ប្រធាន |
| - ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត | អនុប្រធាន |
| - ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត | អនុប្រធានប្រចាំការ |
| - ប្រធានមន្ទីរផែនការ រាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរកិច្ចការនារី រាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរសុខាភិបាល រាជធានី ខេត្ត | សមាជិក |
| - ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ រាជធានី ខេត្ត | សមាជិក |
| - អភិបាលក្រុង ស្រុក ខណ្ឌ | សមាជិក |
| - ប្រធានសាខាមូលនិធិជនពិការ រាជធានី ខេត្ត | សមាជិក |

សមាសភាពជាក់ស្តែង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ៥.-**

គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ សម្រាប់ថ្នាក់រាជធានី ខេត្ត មានភារកិច្ចដូចខាងក្រោម៖

- កំណត់អត្តសញ្ញាណជនពិការក្រីក្រដែលត្រូវទទួលបានរបបគោលនយោបាយនិងផ្តល់បណ្ណសង្គមកិច្ច ផ្អែកតាមមាត្រា៨នៃអនុក្រឹត្យនេះ
- កំណត់ផែនការផ្តល់របបគោលនយោបាយនិងបណ្ណសង្គមកិច្ចប្រចាំឆ្នាំជូនដល់ជនពិការក្រីក្រ ស្រប តាមលទ្ធភាពនៃថវិកាដែលមានរបស់រាជធានី ខេត្ត តាមការផ្ទេរអាណាប័កពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- អនុម័តសំណើផ្តល់របបគោលនយោបាយនិងបណ្ណសង្គមកិច្ចជូនដល់ជនពិការក្រីក្រ
- សម្របសម្រួលដោះស្រាយថវិកា អនុវត្តគម្រោងតាមការកំណត់នៃច្បាប់ថវិកាជាតិ
- រៀបចំផែនការត្រៀមបម្រុង សម្រាប់ដោះស្រាយជាយថាហេតុនៃគ្រោះមហន្តរាយធម្មជាតិផ្សេងៗ សម្រាប់ជនពិការក្រីក្រ
- លើកគម្រោងថវិកាជូនមូលនិធិជនពិការ សម្រាប់ការចំណាយឧបត្ថម្ភជនពិការក្រីក្រ
- លើកគម្រោងផែនការប្រចាំឆ្នាំបញ្ចូលក្នុងជំពូកចំណាយថវិការបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត
- ចេញសេចក្តីណែនាំដល់អាជ្ញាធរមូលដ្ឋាន ក្នុងការកំណត់អត្តសញ្ញាណជនពិការក្រីក្រនិងលើកសំណើ មកគណៈកម្មការរាជធានី ខេត្ត
- តាមដានត្រួតពិនិត្យការប្រែប្រួលជីវភាពរស់នៅរបស់ជនពិការក្រីក្រដែលទទួលបានបណ្ណសង្គមកិច្ច
- រៀបចំកញ្ចប់ថវិការបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត សម្រាប់ការ អនុវត្តការងាររបស់គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍
- រៀបចំរបាយការណ៍ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រគល់ជូន។

**មាត្រា ៦.-**

គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ សម្រាប់ថ្នាក់រាជធានី ខេត្ត មានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ជាលេខាធិការដ្ឋាន។ គណៈកម្មការនេះមានសិទ្ធិប្រើត្រារបស់សាលារាជធានី ខេត្ត។

គណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ សម្រាប់ថ្នាក់រាជធានី ខេត្ត អាចបង្កើតអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវចេញប្រកាសណែនាំអនុវត្តអនុក្រឹត្យនេះ។

## ជំពូកទី៣
## លក្ខខណ្ឌនៃការផ្តល់របបគោលនយោបាយ

**មាត្រា ៨.-**

ជនពិការក្រីក្រដែលត្រូវទទួលបានរបបគោលនយោបាយ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- មានលំនៅឋានឬកន្លែងស្នាក់នៅដែលទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋាន
- ជនពិការដែលមានកម្រិតពិការភាពធ្ងន់ធ្ងរ ក្រីក្របំផុត និងគ្មានទីពឹង ជនពិការចាស់ជរា ក្រីក្របំផុត និងគ្មានទីពឹង ជនពិការមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្រីក្របំផុត និងគ្មានទីពឹង។

## ជំពូកទី៤
## របបគោលនយោបាយចំពោះជនពិការក្រីក្រ

**មាត្រា ៩.-**

កម្រិតរបបគោលនយោបាយចំពោះជនពិការក្រីក្រ៖

| ល.រ | ប្រភេទជនពិការក្រីក្រ | រយៈពេល | | | ទឹកប្រាក់ប្រចាំខែ |
|---|---|---|---|---|---|
| | | ស្រាល | មធ្យម | ធ្ងន់ | |
| ១ | ជនពិការមានពិការភាពធ្ងន់ធ្ងរ ក្រីក្របំផុត និងគ្មានទីពឹង | ៣ខែ | ៦ខែ | ១២ខែ | ២០ ០០០ រៀល |
| ២ | ជនពិការចាស់ជរា ក្រីក្របំផុត និងគ្មានទីពឹង | ៣ខែ | ៦ខែ | ១២ខែ | ២០ ០០០ រៀល |
| ៣ | ជនពិការមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ក្រីក្របំផុត និងគ្មានទីពឹង | ៣ខែ | ៦ខែ | ១២ខែ | ២០ ០០០ រៀល |

របបគោលនយោបាយចំពោះជនពិការក្រីក្រខាងលើ ត្រូវប្រើប្រាស់កញ្ចប់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងពីប្រភពផ្សេងៗ។

**មាត្រា ១០.-**

ជនពិការមានពិការភាពធ្ងន់ធ្ងរនិងក្រីក្រ និងជនពិការដែលក្រីក្របំផុតគ្មានទីពឹង ដែលមកទទួលសេវានៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មរបស់រដ្ឋ ត្រូវបានទទួលការឧបត្ថម្ភដូចតទៅ៖

- ការផ្តល់សេវាស្តារលទ្ធភាពពលកម្ម
- ប្រាក់សម្រាប់អាហារក្នុងអំឡុងពេលទទួលសេវាស្តារលទ្ធភាពពលកម្មក្នុង១ថ្ងៃ ៣.០០០ (បីពាន់)រៀល
- ប្រាក់សោហ៊ុយធ្វើដំណើរមកទទួលសេវាស្តារលទ្ធភាពពលកម្ម ទៅមក ១០ ០០០ (មួយម៉ឺន) រៀល។

ការបង់ថ្លៃសេវាស្តារលទ្ធភាពពលកម្ម ប្រាក់សម្រាប់អាហារ និងប្រាក់សោហ៊ុយធ្វើដំណើរ ត្រូវប្រើប្រាស់ថវិការបស់មូលនិធិជនពិការ។

ជនពិការមានពិការភាពធ្ងន់ធ្ងរនិងក្រីក្រ និងជនពិការដែលក្រីក្របំផុតគ្មានទីពឹង ដែលទៅពិនិត្យព្យាបាលថែទាំសុខភាពនៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ត្រូវទទួលបានការឧបត្ថម្ភថវិកាពីមូលនិធិជនពិការក្នុងមួយនាក់ ៣០ ០០០ (បីម៉ឺន) រៀល។ ប្រាក់ឧបត្ថម្ភនេះ ត្រូវទទួលបាន១លើក ក្នុងមួយឆ្នាំ។

**មាត្រា ១១.-**

របបគោលនយោបាយដូចចែងក្នុងមាត្រា៩ មាត្រា១០នៃអនុក្រឹត្យនេះ អាចត្រូវបានផ្តល់បន្តឬផ្អាក ក្រោយពីការត្រួតពិនិត្យនិងវាយតម្លៃពីគណៈកម្មការដែលមានចែងក្នុងមាត្រា៨នៃអនុក្រឹត្យនេះ។

**មាត្រា ១២.-**

របបគោលនយោបាយចំពោះជនពិការក្រីក្រដូចមានចែងក្នុងមាត្រា៩និងមាត្រា១០នៃអនុក្រឹត្យនេះ ត្រូវកំណត់ជាបណ្ណសង្គមកិច្ចដែលចេញដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត។ ការពិនិត្យនិងផ្តល់បណ្ណសង្គមកិច្ច ត្រូវសម្រេចដោយគណៈកម្មការគ្រប់គ្រងរបបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍ សម្រាប់ថ្នាក់រាជធានី ខេត្ត។

នីតិវិធីនៃការផ្តល់បណ្ណ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មិថុនា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អន្តរក្រសួង**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ក្រសួងសុខាភិបាល**

លេខ:[illegible]សអយ/បក

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែវិច្ឆិកា ឆ្នាំ២០១១

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់កិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញការចាំបាច់របស់ក្រសួង

## ស ម្រេ ច

**ប្រការ ១**.-

ប្រកាសនេះ មានគោលបំណងកំណត់លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតនៃពិការភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅបង្កើតនិយាមថ្នាក់ជាតិសម្រាប់ប្រើប្រាស់ក្នុងការ ប្រមូលស្ថិតិ និង ទិន្នន័យ សម្រាប់ការអនុវត្តច្បាប់ គោលនយោបាយ និងកម្មវិធីផ្សេងៗ ទាក់ទងនឹងពិការភាព។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន និងនីតិបុគ្គលដែលធ្វើសកម្មភាពពាក់ព័ន្ធ នឹងការងារពិការភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ជនពិការសំដៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬសតិបញ្ញា បណ្តាលឲ្យមានការរំខានដល់ជីវភាពរស់នៅ ឬសកម្មភាពនានាប្រចាំថ្ងៃ ដូចជា ជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកល និងប្រភេទពិការផ្សេងៗទៀត ដែលនាំឲ្យមានលក្ខណៈមិនប្រក្រតី។

**ប្រការ៥ .-**

ពិការភាព ត្រូវបានកំណត់ជា ៤ ប្រភេទ ដូចខាងក្រោម ៖

១. ពិការកាយសម្បទា

២. ពិការសតិបញ្ញា

៣. ពិការផ្លូវចិត្ត

៤. ពិការផ្សេងៗ ។

**ប្រការ៦.-**

លក្ខណវិនិច្ឆ័យនៃប្រភេទពិការភាព ត្រូវកំណត់ដូចខាងក្រោម៖

| **ប្រភេទពិការ** | **និយមន័យ** | **លក្ខណវិនិច្ឆ័យ** |
|---|---|---|
| ១. ពិការកាយសម្បទា | | |
| ពិបាកក្នុងការធ្វើចលនា | ជនទាំងឡាយណាដែលមានលទ្ធភាពធ្វើចលនា (ដោយរាងកាយ) ផ្លាស់ទី ដោយលំបាក ឬលំបាកកម្រើកផ្នែកណាមួយនៃរាងកាយ ឬមិនអាចកម្រើកបាន។ | ដាច់ដៃ ដាច់ជើង ស្វិតដៃ ស្វិតជើង ស្វិត សាច់ដុំ គាំងសន្លាក់ បាក់ឆ្អឹង សាច់ដុំរួញខ្លី ខូចប្រព័ន្ធបញ្ជាចលនារបស់ខួរក្បាល ជើងខ្វេរ ជើងកែកទន់ត្រឹមកដៃ ជើងទន់ ខូចទ្រង់ទ្រាយពីកំណើត ស្លាប់មួយចំហៀងខ្លួន / កំណាត់ខ្លួន /អវយវៈ ខូចសរសៃ (nerve) កំហូចរាងឆ្អឹងខ្នង (កោងទៅមុខ កោងទៅចំហៀង និងកោងទៅក្រោយ) ពិការដោយសារផលវិបាកនៃជំងឺ ខូចស្នាម្ខាងភ្លាត់ត្រគាគធ្ងន់ធ្ងរ របួសខួរឆ្អឹងខ្នង គ្រិចធ្ងន់ធ្ងររលាកធ្ងន់ធ្ងរ (ភ្លើង ទឹកអាស៊ីដ.....) ។ |
| ពិបាកក្នុងការស្តាប់ | ជនទាំងឡាយណាដែលពិបាកក្នុងការស្តាប់ ឬលទ្ធភាពនៃការស្តាប់ចុះខ្សោយ ឬមិនអាចស្តាប់បាន | ថ្លង់ ត្រចៀកអត់រន្ធ ពុំមានក្រដាសត្រចៀក ធ្លាយក្រដាសត្រចៀក ហៀរអំបៅអំបែកធ្ងន់ធ្ងររន្ធត្រចៀកមានដុំពក។ |

| | | |
|---|---|---|
| | (ពីកំណើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ឬវ័យជរា.....។ល។) ។ | |
| ពិបាកក្នុងការនិយាយ | ជនទាំងឡាយណាដែលពិបាកក្នុងការនិយាយ និយាយមិនច្បាស់ ឬនិយាយមិនរួចទាល់តែសោះ ឬអ្នកដទៃពិបាកស្តាប់ (ពីកំណើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ឬវ័យជរា.....។ល។) | និយាយត្រឡាន់(អណ្តាតធំ)/គ្រដិតធ្ងន់ធ្ងរ ឆែបក្រអូមមាត់ ក្រឡើត ក្រងូវ និយាយមិនច្បាស់ និយាយមិនចេញ គ ជលវិបាកនៃជំងឺ។ |
| ពិបាកក្នុងការមើល | ជនទាំងឡាយណា ដែលមានគំហើញចុះខ្សោយ ឬមិនអាចមើលឃើញ (ពីកំណើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ឬវ័យជរា.....។ល។) | ងងឹតភ្នែកម្ខាង ឬទាំងសងខាង ស្វិតសរសៃបាតភ្នែក ភ្នែកស្រៀនមើលមិនឃើញ កន្ទុយថ្លែនធ្ងន់ធ្ងរ ភ្នែកឡើងបាយ ត្រាក់កូមធ្ងន់ធ្ងរបណ្តាលឲ្យមានប្រេងចាក់ ភ្នែកស្រលៀង ភ្នែកមីញ៉ូប ធ្លាក់ត្របកភ្នែក សម្ពាធកញ្ចក់ភ្នែក សម្ពាធទឹកក្នុងភ្នែកកើន ឡើងរលាកសរសៃបាតភ្នែក ងងឹតពណ៌។ |
| ពិការសរីរាង្គខាងក្នុង | ជនទាំងឡាយណាដែលបានវះកាត់សរីរាង្គខាងក្នុងសំខាន់ៗ (ដោយមានការបញ្ជាក់ពីគ្រូពេទ្យជំនាញ) ឬខ្សោយសរីរាង្គខាងក្នុង ឬចុះខ្សោយមុខងារនៃភាពស៊ាំ និងមានជំងឺរ៉ាំរ៉ៃ .....។ល។ | ខ្សោយមុខងារសរីរាង្គៈ បេះដូង ក្រលៀន ប្រព័ន្ធដង្ហើម តម្រងនោម ពោះវៀន ថ្លើម។ |
| ២. ពិការសតិបញ្ញា | | |
| | ជនទាំងឡាយណា ដែលមានផលវិបាកក្នុងការចងចាំ ភ្លេចច្រើន ឬមិនអាចធ្វើដូចមនុស្សដទៃទៀតដែល មានអាយុដំណាលគ្នា (ពីកំណើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ។ល។) | បញ្ញាលូតលាស់យឺត រៀនខ្សោយ/ ការចងចាំមានកម្រិត (Cretinism) ខូចប្រព័ន្ធបញ្ញាក្នុងខួរក្បាល (Cerebral Palsy) និងជំងឺ (ដោនសាំងដ្រូម មានចរិតទុយមុយ (Autism)។ |
| ៣. ពិការផ្លូវចិត្ត | | |
| | ជនទាំងឡាយណាដែលមានវិបត្តិផ្នែកអាកប្បកិរិយា អារម្មណ៍ និងការគិត ដែលកើតឡើងជាប្រចាំ ហើយរំខានដល់ការបំពេញមុខងារប្រចាំថ្ងៃ។ | អាក្រាត និយាយ សើច យំ ច្រៀងរាំលេងតែម្នាក់ឯងខុសពីប្រក្រតី ស្មឹងស្មាធ ជេរគេជេរឯង វាយ ឬប្រព្រឹត្តអំពើហឹង្សាដោយមិនដឹងខ្លួន មិនដឹងគ្រោះថ្នាក់ ជំងឺមន្ទិលសង្ស័យ វិកលចរិត ខូចសតិអារម្មណ៍ តានតឹងផ្លូវចិត្ត ជំងឺធ្លាក់ទឹកចិត្ត ថប់អារម្មណ៍ ជំងឺវង្វេង |

| ៤. ពិការផ្សេងៗ | | |
|---|---|---|
| | ជនទាំងឡាយណា ដែលលំបាកក្នុងការបំពេញតួនាទីផ្នែករាងកាយ ឬតួនាទីក្នុងសង្គម ឬពិការដែលមិនអាចចាត់ចូលទៅក្នុងប្រភេទពិការណាមួយខាងលើ ឬពហុពិការ។ | មុខមាត់ខូចទ្រង់ទ្រាយ ក្បាលធំ គឿ ក្រិនពកក ផលវិបាកក្នុងការបំពេញមុខងារដោយសារគ្រោះថ្នាក់ និងជំងឺពុំរ៉ៃ ... ។ល។ |

**ប្រការ ៧.-**

កម្រិតនៃប្រភេទពិការភាពនីមួយៗ ត្រូវបានកំណត់ ដូចខាងក្រោម ៖

- **ពិការកាយសម្បទា** មាន ៤កម្រិត គឺ: កម្រិតទី១/ធ្ងន់បំផុត កម្រិតទី២/ធ្ងន់ កម្រិតទី៣/មធ្យម និងកម្រិតទី៤/ស្រាល
- **ពិការសតិបញ្ញា** មាន ៤កម្រិត គឺ: កម្រិតទី១/ធ្ងន់បំផុត កម្រិតទី២/ធ្ងន់ កម្រិតទី៣/មធ្យម និងកម្រិតទី៤/ស្រាល
- **ពិការផ្លូវចិត្ត** មាន ៤កម្រិត គឺ: កម្រិតទី១/ធ្ងន់បំផុត កម្រិតទី២/ធ្ងន់ កម្រិតទី៣/មធ្យម និងកម្រិតទី៤/ស្រាល
- **ពិការផ្សេងៗ** មាន ៤កម្រិតគឺ:កម្រិតទី១/ធ្ងន់បំផុត កម្រិតទី២/ធ្ងន់ កម្រិតទី៣/មធ្យម និងកម្រិតទី៤/ស្រាល។

**ប្រការ ៨.-**

លក្ខណវិនិច្ឆ័យកម្រិត នៃប្រភេទពិការភាពនីមួយៗ កំណត់ដូចខាងក្រោម:

- លក្ខណវិនិច្ឆ័យកម្រិតនីមួយៗ នៃពិការកាយសម្បទា ផ្លូវចិត្ត និងពិការផ្សេងៗ (ដូចមានក្នុងតារាងឧបសម្ព័ន្ធ ១)
- លក្ខណវិនិច្ឆ័យកម្រិតនីមួយៗ នៃពិការសតិបញ្ញា (ដូចមានក្នុងតារាងឧបសម្ព័ន្ធ ២)

**ប្រការ ៩.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាវាយតម្លៃប្រភេទ និងកម្រិតនៃពិការភាព ថ្នាក់ជាតិ ដែលមានសមាសភាពដូចខាងក្រោម ៖

- រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប សហប្រធាន
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប សហប្រធាន
- អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល សមាជិក
- តំណាងនាយកដ្ឋានជំនាញនៃក្រសួងសុខាភិបាល ២រូប សមាជិក
- តំណាងនាយកដ្ឋានជំនាញនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២រូប សមាជិក
- តំណាងនាយកដ្ឋានជំនាញនៃក្រសួងការពារជាតិ ២រូប សមាជិក

សមាសភាពជាក់ស្តែង និងតួនាទី ភារកិច្ចនៃក្រុមប្រឹក្សាវាយតម្លៃប្រភេទ និងកម្រិតនៃពិការភាពថ្នាក់ជាតិ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ ១០.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាវាយតម្លៃប្រភេទ និងកម្រិតនៃពិការភាពសម្រាប់ថ្នាក់រាជធានី ខេត្ត ដែលមានសមាសភាព ដូចខាងក្រោម ៖

- ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត ១រូប សហប្រធាន
- ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ១រូប សហប្រធាន
- មន្ត្រីជំនាញនៃមន្ទីរសុខាភិបាលរាជធានី ខេត្ត ២រូប សមាជិក
- មន្ត្រីជំនាញនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ២រូប សមាជិក

សមាសភាពជាក់ស្តែង និងតួនាទី ភារកិច្ចនៃក្រុមប្រឹក្សាវាយតម្លៃប្រភេទ និងកម្រិត នៃពិការភាពថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ ១១.-**

គ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធត្រូវផ្សព្វផ្សាយ និងអនុវត្តប្រកាសនេះ ឲ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពខ្ពស់។

**ប្រការ ១២.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**អ៊ិត សំហេង**

**ចម្លងជូន**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងស.អ.យ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល
- ក្រុមប្រឹក្សាសកម្មភាពជនពិការ
- មូលនិធិជនពិការ
- ដូចប្រការ ១១
- ឯកសារ កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ ១ នៃប្រកាសអន្តរក្រសួងលេខ...២៤៩២...... ចុះថ្ងៃទី ...២២.... ខែ..វិច្ឆិកា.... ឆ្នាំ២០១១
# ស្តីពីការកំណត់លក្ខណាវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព

## លក្ខណាវិនិច្ឆ័យកម្រិតនីមួយៗ នៃពិការកាយសម្បទា ផ្លូវចិត្ត និងពិការផ្សេងៗ

| ពិការកាយសម្បទា | | | | | |
|---|---|---|---|---|---|
| ប្រភេទ | | កម្រិត១/ធ្ងន់បំផុត | កម្រិត២/ធ្ងន់ | កម្រិត៣/មធ្យម | កម្រិត៤/ស្រាល |
| កម្សោយ អវយវៈ និងដងខ្លួន | អវយវៈលើ | ១. បាត់បង់ ឬគ្មានអវយវៈលើទាំងពីរ ចាប់ពីត្រឹមស្មា។<br>២. បាត់បង់ទាំងស្រុងនៃមុខងារអវយវៈលើទាំងពីរ។ | ១. បាត់បង់ម្រាមដៃនៃអវយវៈលើទាំងពីរ។<br>២. បាត់បង់ត្រឹមកែងដៃដល់ចុងម្រាមឬពាក់កណ្តាលដៃណាមួយ។<br>៣. កម្សោយខ្លាំងនៃមុខងារនៃដៃទាំងពីរ។<br>៤. បាត់បង់មុខងារទាំងស្រុងនៃដៃណាមួយ។ | ១. បាត់បង់មេដៃនិងចង្អុលដៃនៃអវយវៈលើទាំងពីរ។<br>២. បាត់មេដៃនៃអវយវៈលើទាំងពីរ។<br>៣. បាត់បង់ម្រាមទាំងអស់នៃដៃណាមួយ។<br>៤. បាត់មេដៃ និងចង្អុលដៃនៃដៃណាមួយ។<br>៥. បាត់ម្រាមដៃ៣ នៃដៃណាមួយ (រួមមានមេដៃ ឬចង្អុលដៃ)។<br>៦. កម្សោយខ្លាំងនៃមុខងារនៃដៃណាមួយ។<br>៧. បាត់បង់មុខងារទាំងស្រុងនៃមេដៃនៃដៃទាំងពីរ។<br>៨. បាត់បង់មុខងារទាំងស្រុងនៃម្រាមនៃដៃទាំងសងខាង។<br>៩. បាត់បង់មុខងារទាំងស្រុងនៃសន្លាក់ស្មា សន្លាក់កែងដៃ ឬសន្លាក់កដៃ នៃដៃណាមួយ។<br>១០.បាត់បង់មុខងារទាំងស្រុងនៃម្រាមទាំងអស់នៃដៃណាមួយ។<br>១១.បាត់បង់មុខងារទាំងស្រុងនៃមេដៃ និងចង្អុលដៃនៃអវយវៈលើណាមួយ។<br>១២.បាត់បង់មុខងារទាំងស្រុងនៃម្រាមដៃ៣ នៃដៃ | ១. បាត់បង់មេដៃនៃដៃណាមួយ។<br>២. បាត់បង់ម្រាមដៃ២ នៃដៃណាមួយ រួមទាំងចង្អុលដៃ។<br>៣. ការចុះខ្សោយខ្លាំងនៃមេដៃនៃដៃទាំងពីរ។<br>៤. ការចុះខ្សោយខ្លាំងនៃសន្លាក់ស្មា សន្លាក់កែងដៃ ឬសន្លាក់កដៃនៃដៃណាមួយ។<br>៥. ការចុះខ្សោយមុខងារនៃមេដៃនិងចង្អុលដៃនៃដៃណាមួយ។<br>៦. ការចុះខ្សោយមុខងារនៃម្រាមដៃ៣ នៃដៃណាមួយ រួមទាំងមេដៃនិងចង្អុលដៃ។<br>៧. ការចុះខ្សោយមុខងារខ្លាំងនៃមេដៃនៃអវយវៈលើណាមួយ។<br>៨. បាត់បង់ទាំងស្រុងនៃមុខងារនៃមេដៃនៃដៃណាមួយ។<br>៩. បាត់បង់ទាំងស្រុង នូវមុខងារនៃម្រាមដៃ២ រួមទាំងចង្អុលដៃនៃដៃណាមួយ។ |

| | | | | | |
|---|---|---|---|---|---|
| | | | | ណាមួយ (រួមមានមេដៃ ឬចង្អុលដៃ) ។<br>១៣.បាត់បង់មុខងារស្ទើរតែទាំងស្រុងនៃម្រាមដៃ៤នៃអវយវៈលើណាមួយ(រួមមានមេដៃ និងចង្អុលដៃ) ។ | |
| | អវយវៈក្រោម | ១. អវយវៈក្រោមទាំងពីរបាត់បង់យ៉ាងយ៉ាងហោចណាស់ត្រឹមពាក់កណ្តាលភ្លៅ។<br>២. អវយវៈក្រោមទាំងពីរបាត់បង់មុខងារទាំងស្រុង។ | ១. អវយវៈក្រោមទាំងពីរបាត់បង់យ៉ាងហោចត្រឹមជង្គង់<br>២. អវយវៈក្រោមទាំងពីរចុះខ្សោយមុខងារធ្ងន់ធ្ងរ។ | ១. ជើងទាំងពីរបាត់បង់យ៉ាងហោចត្រឹមស្មងជើងចុះក្រោម។<br>២. អវយវៈក្រោមណាមួយបាត់បង់យ៉ាងហោចត្រឹមពាក់កណ្តាលភ្លៅ ។<br>៣. ជើងណាមួយបាត់បង់យ៉ាងហោចណាស់ពាក់កណ្តាល<br>៤. ជើងម្ខាងខ្លីជាងជើងម្ខាងទៀតប្រវែង១០សង់ទីម៉ែត ឬ១/១០ ។<br>៥. ជើងទាំងពីរបាត់បង់ម្រាមទាំងអស់។<br>៦. ម្រាមជើងទាំងអស់បាត់បង់មុខងារទាំងស្រុង<br>៧. ជើងណាមួយបាត់បង់មុខងារទាំងស្រុង ។<br>៨. អវយវៈក្រោមណាមួយចុះខ្សោយមុខងារស្ទើរតែទាំងស្រុង ។<br>៩. សន្លាក់ជង្គង់ឬត្រគាកណាមួយបាត់បង់មុខងារទាំងស្រុង។ | ១.អវយវៈក្រោមណាមួយចុះខ្សោយមុខងារនៃសន្លាក់ត្រគាក ឬសន្លាក់ជង្គង់ ។<br>២.ជើងម្ខាងខ្លីជាងជើងម្ខាងទៀតប្រវែង៥សង់ទីម៉ែត ឬ១/១៥។<br>៣.ប្រអប់ជើងណាមួយបាត់បង់ពាក់កណ្តាល។<br>៤.សន្លាក់កជើងណាមួយចុះខ្សោយមុខងារយ៉ាងខ្លាំង។<br>៥.សន្លាក់កជើងណាមួយបាត់បង់មុខងារទាំងស្រុង។ |
| | ដងខ្លួន | ដងខ្លួនចុះខ្សោយនូវមុខងារមិនមានលំនឹងអង្គុយបាន។ | ១. ដងខ្លួន ចុះខ្សោយមុខងារលំបាកក្នុងការរក្សាជំហរឬអង្គុយ ។<br>២. ដងខ្លួនចុះខ្សោយនូវមុខងារ ពិបាកក្នុងការក្រោកឈរ។ | ដងខ្លួនចុះខ្សោយមុខងារពិបាកក្នុងការដើរ។ | ផ្នែកខ្លះនៃដងខ្លួនចុះខ្សោយមុខងារ។ |

| | | | | | |
|---|---|---|---|---|---|
| មុខងារបញ្ហាចលនាចុះខ្សោយដោយសារការលូតលាស់ខួរក្បាល មិនប្រក្រតី ដែលកើតឡើងមុន និងក្រោយពេលទារកកើត ។ | មុខងារចលនានៃអវយវៈលើ | មុខងារដៃទាំងពីរ មិនអាចមានលទ្ធភាពស្ទើរតែទាំងស្រុងក្នុងការបំពេញសកម្មភាពការងារប្រចាំថ្ងៃ ដោយសារចលនាអធន្ទ: ឬកង្វះចលនាសម្របសម្រួល។ | មុខងារដៃទាំងពីរ បំពេញការងារប្រចាំថ្ងៃមានកម្រិតយ៉ាងខ្លាំង ដោយសារ ចលនាអធន្ទ: ឬកង្វះ ចលនាសម្របសម្រួល។ | ១. មុខងារដៃទាំងពីរ បំពេញការងារប្រចាំថ្ងៃមានកម្រិតដោយសារ ចលនាអធន្ទ:ឬកង្វះចលនាសម្របសម្រួល។<br>២. មុខងារដៃទាំងពីរបំពេញសកម្មភាពសង្គមមានកម្រិត ដោយសារ ចលនាអធន្ទ:ឬកង្វះចលនាសម្របសម្រួល។ | ១. មុខងារដៃម្ខាងចុះខ្សោយខ្លាំងដោយសារ ចលនាអធន្ទ:ឬកង្វះចលនាសម្របសម្រួល។<br>២. មុខងារដៃម្ខាងចុះខ្សោយដោយសារចលនាអធន្ទ:ឬកង្វះចលនាសម្របសម្រួល។ |
| | មុខងារចលនានៃអវយវៈក្រោម | មិនអាចដើរបានដោយសារ ចលនាអធន្ទ: ឬកង្វះចលនាសម្របសម្រួល។ | ស្ទើរតែមិនអាចដើរកើតដោយសារ ចលនាអធន្ទ: ឬកង្វះ ចលនាសម្របសម្រួល។ | ១. ការដើរនៅមានកម្រិត ក្នុងសកម្មភាពប្រចាំថ្ងៃនៅផ្ទះ ដោយចលនាអធន្ទ:ឬកង្វះចលនាសម្របសម្រួល។<br>២. សកម្មភាពសង្គមប្រចាំថ្ងៃស្ទើរតែមិនអាចធ្វើបានដោយសារចលនាអធន្ទ: ឬកង្វះ ចលនាសម្របសម្រួល។ | ១. ចលនាអធន្ទ: ឬកង្វះ ចលនាសម្របសម្រួលដែលរំខានដល់សកម្មភាពសង្គមប្រចាំថ្ងៃ។<br>២. មុខងារចលនាត្រូវបានចុះខ្សោយដោយសារចលនាអធន្ទ: ឬកង្វះ ចលនាសម្របសម្រួល។ |
| កម្សោយគំហើញ | | ការបូកបញ្ចូលគ្នានៃ គំហើញរបស់ភ្នែកទាំងពីរ តិចជាង១/២(៣ម៉ែត្រ) រហូតដល់មើលពន្លឺមិនឃើញ (ដោយផ្អែកលើការប្រើប្រាស់តារាងវាស់ភ្នែកជាសកល។ ក្នុងករណីមនុស្ស ដែលមានបញ្ហាកំហុសកំណំ (ទទួលពន្លឺ) (Ametropia) ត្រូវវាស់ដោយផ្អែកលើ វ៉ែនតា)។ | ១. ការបូកបញ្ចូលគ្នានៃ គំហើញរបស់ភ្នែកទាំងពីរ ចាប់ពី១/២០ (៣ម៉ែត្រ)។<br>២. ដែនគំហើញនៃរង្វង់គំហើញភ្នែកម្ខាងៗ មិនលើសពី១០ដឺក្រេ ហើយការបាត់បង់គំហើញជិតមិនតិចជាង៩៥%។ | ១. ការបូកបញ្ចូលគ្នានៃ គំហើញរបស់ភ្នែកទាំងពីរ គឺពី១/១០ទៅ៣/១០។<br>២. ដែនគំហើញនៃភ្នែកម្ខាងៗមិនលើសពី១០ដឺក្រេ ហើយរង្វង់កែវយឹតដែលបាត់បង់មិនតិចជាង៩០%។ | ១. ការបូកបញ្ចូលគ្នានៃ គំហើញរបស់ភ្នែកទាំងពីរ គឺពី៣/១០ទៅ៥/១០។<br>២. ដែនគំហើញនៃភ្នែកម្ខាងៗមិនលើសពី ១០ដឺក្រេ ។<br>- |

| | | | | | |
|---|---|---|---|---|---|
| មុខងារ ឬ លំនឹងនៃការស្តាប់ ចុះខ្សោយ (equilibrium) | កម្សោយមុខងារក្នុងការស្តាប់ | គ្មានចំណាត់ថ្នាក់ | កម្រិតនៃការស្តាប់របស់ត្រចៀកទាំងពីរគឺពី ៩៥ -១២០ដេស៊ីបែល (decibels) ឬលើសពីនេះ ឧ- ថ្លង់ទាំងស្រុងនៃត្រចៀកទាំងពីរ។ | កម្រិតនៃការឮនៃត្រចៀកទាំងពីរគឺពី ៨០ -៩៥ ដេស៊ីបែល(ឧ.មិនមានលទ្ធភាពក្នុងការស្តាប់សម្លេងខ្លាំងលើកលែងតែប្រភពសំឡេងនៅជិតត្រចៀក)។ | ១. កម្រិតនៃការស្តាប់ក្នុងត្រចៀកទាំងពីរគឺពី ២០ - ៨០ ដេស៊ីបែល (ឧ.មិនមានលទ្ធភាពក្នុងការស្តាប់សំឡេងនិយាយ លើកលែងតែប្រភពសំឡេងនៅជិតត្រចៀក ឬមិនមានលទ្ធភាពក្នុងការយល់ពាក្យដែលនិយាយក្នុងចម្ងាយ៤០សង់ទីម៉ែត្រឬលើស)<br>២. មិនលើសពី៥០%នៃសម្លេងនិយាយដែលអាចឮបានច្បាស់។<br>៣. កម្រិតនៃការស្តាប់ឮនៃត្រចៀកម្ខាងគឺ៩០ ដេស៊ីបែលឬច្រើន ជាមួយនឹង៥០ដេស៊ីបែលឬច្រើនជាងនៃត្រចៀកម្ខាងទៀត។ |
| | កម្សោយមុខងារលំនឹងនៃការស្តាប់ | គ្មានចំណាត់ថ្នាក់ | គ្មានចំណាត់ថ្នាក់ | ការចុះខ្សោយខ្លាំងនៃមុខងារលំនឹង (equilibrium)។ | ការចុះខ្សោយខ្លាំងនៃលំនឹង។ |
| កម្សោយមុខងារក្នុងការបញ្ចេញសំឡេងនិយាយ ឬ ទំពារ | | គ្មានចំណាត់ថ្នាក់ | គ្មានចំណាត់ថ្នាក់ | បាត់បង់មុខងារបញ្ចេញសំឡេងនិយាយ ឬការទំពារ។ | ការចុះខ្សោយខ្លាំងនៃមុខងារសំឡេងនិយាយ ឬការទំពារ។ |
| ការចុះខ្សោយមុខងារនៃបេះដូង តម្រងនោម ប្រដាប់ដង្ហើម ប្លោកនោម គល់ពោះ វៀនធំ ពោះវៀនតូច ឬថ្លើម | កម្សោយមុខងារនៃបេះដូង | គ្មានលទ្ធភាពបំពេញការងារប្រចាំថ្ងៃ ដោយសារងាប់ ឬក្រិនផ្នែកណាមួយនៃសាច់ដុំបេះដូង។ | លទ្ធភាពនៃការបំពេញការងារផ្ទាល់ខ្លួនប្រចាំថ្ងៃមានការលំបាកខ្លាំង ដោយសារការចុះខ្សោយមុខងារនៃបេះដូង។ | សកម្មភាពប្រចាំថ្ងៃនៅផ្ទះគឺនៅមានការលំបាកខ្លាំង ដោយសារការចុះខ្សោយមុខងារនៃបេះដូង។ | សកម្មភាពសង្គមប្រចាំថ្ងៃគឺនៅមានការលំបាកខ្លាំង ដោយសារការចុះខ្សោយមុខងារនៃបេះដូង។ |
| | កម្សោយមុខងារនៃតម្រងនោម | គ្មានលទ្ធភាពបំពេញការងារប្រចាំថ្ងៃ ដោយសារខូចតម្រង | លទ្ធភាពនៃការបំពេញការងារផ្ទាល់ខ្លួនប្រចាំថ្ងៃមានការលំបាកខ្លាំង | សកម្មភាពប្រចាំថ្ងៃនៅផ្ទះគឺនៅមានការលំបាកខ្លាំង ដោយសារការចុះខ្សោយមុខងារនៃតម្រងនោម។ | សកម្មភាពសង្គមប្រចាំថ្ងៃគឺនៅមានការលំបាកខ្លាំង ដោយសារការចុះខ្សោយមុខងារនៃតម្រងនោម។ |

| | | | | | |
|---|---|---|---|---|---|
| | | នោមទាំងស្រុង។ | ដោយសារការចុះខ្សោយមុខងារនៃតម្រងនោម។ | | |
| | កម្សោយមុខងារនៃប្រដាប់ដង្ហើម | លទ្ធភាពនៃការបំពេញការងារផ្ទាល់ខ្លួនប្រចាំថ្ងៃមានការលំបាកខ្លាំងដោយសារ ការចុះខ្សោយមុខងារនៃប្រដាប់ដង្ហើម។ | គ្មានចំណាត់ថ្នាក់ | សកម្មភាពប្រចាំថ្ងៃនៅផ្ទះគឺនៅមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារនៃប្រដាប់ដង្ហើម។ | សកម្មភាពសង្គមប្រចាំថ្ងៃគឺនៅមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារនៃប្រដាប់ដង្ហើម។ |
| | កម្សោយមុខងារនៃប្លោកនោមឬតល់ពោះវៀនធំ | លទ្ធភាពនៃការបំពេញការងារផ្ទាល់ខ្លួនប្រចាំថ្ងៃមានការលំបាកខ្លាំងដោយសារ ការចុះខ្សោយមុខងារនៃប្លោកនោមឬពោះវៀនធំ។ | គ្មានចំណាត់ថ្នាក់ | សកម្មភាពប្រចាំថ្ងៃនៅផ្ទះគឺនៅមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារនៃប្លោកនោម ឬពោះវៀនធំ។ | សកម្មភាពសង្គមប្រចាំថ្ងៃគឺនៅមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារនៃប្លោកនោមឬពោះវៀនធំ។ |
| | កម្សោយមុខងារនៃពោះវៀនតូច | លទ្ធភាពនៃការបំពេញការងារផ្ទាល់ខ្លួនប្រចាំថ្ងៃមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារ នៃពោះវៀនតូច។ | គ្មានចំណាត់ថ្នាក់ | សកម្មភាពប្រចាំថ្ងៃនៅផ្ទះគឺនៅមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារនៃពោះវៀនតូច។ | សកម្មភាពសង្គមប្រចាំថ្ងៃគឺនៅមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារនៃពោះវៀនតូច។ |
| | កម្សោយមុខងារនៃថ្លើម | លទ្ធភាពនៃការបំពេញការងារផ្ទាល់ខ្លួនប្រចាំថ្ងៃមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារនៃថ្លើម។ | គ្មានចំណាត់ថ្នាក់ | សកម្មភាពប្រចាំថ្ងៃនៅផ្ទះគឺនៅមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារនៃថ្លើម។ | សកម្មភាពសង្គមប្រចាំថ្ងៃគឺនៅមានការលំបាកខ្លាំងដោយសារការចុះខ្សោយមុខងារនៃថ្លើម។ |

| ពិការផ្លូវចិត្ត និងពិការផ្សេងៗ | | | | |
|---|---|---|---|---|
| ប្រភេទ | កម្រិត១/ធ្ងន់បំផុត | កម្រិត២/ធ្ងន់ | កម្រិត៣/មធ្យម | កម្រិត៤/ស្រាល |
| ការបាត់បង់លទ្ធភាពបំពេញការងារ | លើសពី៨០% | លើសពី៦០%-៨០% | លើសពី៤០%-៦០% | លើសពី២០%-៤០% |

**កំណត់សំគាល់ ៖**

១. ក្នុងករណីមានពិការភាពពីរក្នុងកម្រិតដូចគ្នា(តែមួយ) ត្រូវកំណត់ឡដល់ជនពិការនោះ ក្នុងកម្រិតខ្ពស់ជាង។

២. ជនពិការម្នាក់មានពិការភាពពីរ ឬច្រើន ដែលស្ថិតក្នុងកម្រិតផ្សេងៗ ជនពិការនោះត្រូវបានពិចារណាឲ្យស្ថិតក្នុងកម្រិតខ្ពស់ជាង ។

## តារាងឧបសម្ព័ន្ធ ២ នៃប្រកាសអន្តរក្រសួងលេខ ២៤៩២ ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកំណត់លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព

### លក្ខណវិនិច្ឆ័យកម្រិតនិមួយៗ នៃពិការសតិបញ្ញា

| ល.រ | កម្រិត | លក្ខណ:វិនិច្ឆ័យ | |
|---|---|---|---|
| | | វាស់ដោយប្រព័ន្ធ IQ Ranges | តាមរយ:ប្រតិកម្ម (Support Ranges in AAMR) |
| ១ | ធ្ងន់ធ្ងរបំផុត (Profound) | ក្រោម 20-25 | ដែលរាលដាល (Pervasive) |
| ២ | ធ្ងន់ធ្ងរ (Severe) | 20-25 to 35-40 | ដ៏ធំទូលាយ (Extensive) |
| ៣ | មធ្យម (Moderate) | 35-40 to 50-55 | ដែលមានកម្រិត (Limited) |
| ៤ | ស្រាល (Mild) | 50-55 to approx - 70 | លោះពេល (ដែលមានឈប់ៗ) (Intermitted) |

<u>កំណត់សម្គាល់:</u> Support Ranges in AAMR ការវិនិច្ឆ័យតាមរយ:ប្រតិកម្ម ដែលកំណត់ដោយសមាគម American Association Mental Retardation ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អន្តរក្រសួង**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខៈ ០០៤.......ស.អ.យ/សរណន

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២

# សារាចរណែនាំអន្តរក្រសួង
## ស្តីពី
## ការសម្របសម្រួលសមស្របសម្រាប់ការងាររបស់ជនពិការ

អនុលោមតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ និងអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ ស្តីពីការកំណត់អត្រា និងបែបបទនៃការជ្រើសរើសជនពិការចូលបម្រើការងារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំសារាចរណែនាំនេះ ក្នុងគោលបំណងសម្រួលដល់ការអនុវត្តមាត្រា ១១ នៃអនុក្រឹត្យខាងលើ និងកំណត់នីតិវិធីជាជំនួយបច្ចេកទេសដល់ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ក្នុងការសម្របសម្រួលជ្រើសរើសជនពិការ ដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងចូលបម្រើការងារ ដោយគ្មានការរើសអើង ដូចខាងក្រោម៖

### ១. និយមន័យ

ការសម្របសម្រួលសមស្រប សំដៅដល់ការកែប្រែ និងការកែតម្រូវឲ្យសមស្រប និងចាំបាច់ មិនធ្វើឲ្យការទទួលខុសត្រូវមានភាពវិសមាមាត្រ ឬមិនត្រឹមត្រូវ ដែលតម្រូវតែក្នុងករណីពិសេស ដើម្បីធានាដល់ជនពិការឲ្យទទួលយកបាន និងអនុវត្តបាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

**ការរើសអើង** សំដៅដល់ការបែងចែក ការផាត់ចេញ ឬការដាក់កំហិតណាមួយដោយសារតែពិការភាព ដែលមានបំណង ឬមានអានុភាពធ្វើឲ្យចុះទន់ខ្សោយ ឬគ្មានការទទួលស្គាល់ការអនុវត្ត ឬការទទួលបាននូវសិទ្ធិមនុស្ស និងសេរីភាពជាសារវន្តទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ពលរដ្ឋ ឬក្នុងវិស័យផ្សេងៗទៀត។ ការរើសអើងនេះ រាប់បញ្ចូលរាល់ទម្រង់នៃការរើសអើង រួមទាំងការបដិសេធនូវការសម្របសម្រួលសមស្របផង។

**ឱកាសស្មើគ្នា** សំដៅដល់ការផ្តល់លទ្ធភាព និងឱកាសស្មើគ្នា សម្រាប់មនុស្សគ្រប់រូប ក្នុងការទទួលបានការងារធ្វើ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបំពេញនូវមុខងារ និងការទទួលអត្ថប្រយោជន៍ ដោយគ្មានការរើសអើងលើពិការភាព និងផ្តល់សមភាពយេនឌ័រ។

**សុវត្ថិភាពការងារ** សំដៅដល់គ្រប់សហគ្រាស គ្រឹះស្ថាន និងកន្លែងធ្វើការត្រូវតែបានស្អាត ហើយបង្ហាញថាមានលក្ខខណ្ឌអនាម័យ និងមានសភាពសុខសប្បាយជានិច្ច ឬជាទូទៅត្រូវមានលក្ខខណ្ឌការងារចាំបាច់សម្រាប់សុខភាពរបស់មន្ត្រីរាជការ និងកម្មករនិយោជិត។

## ២. ការជ្រើសរើស

ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមានកាតព្វកិច្ចជ្រើសរើសជនពិការ ដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងចូលបម្រើការងារ ត្រូវរៀបចំនីតិវិធីនៃការជូនដំណឹងជ្រើសរើសជាលាយលក្ខណ៍អក្សរ និងការជ្រើសរើសដូចខាងក្រោម៖

- ក្រសួង ស្ថាប័នរដ្ឋ ត្រូវកសាងផែនការជ្រើសរើសជនពិការ ក្នុងអត្រា ២% នៃចំនួនមន្ត្រីរាជការសរុប និងផ្ញើជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីបានទទួលគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។ ចំពោះនីតិបុគ្គលត្រូវកសាងផែនការជ្រើសរើសជនពិការ ក្នុងអត្រា១% នៃចំនួនកម្មករ និយោជិតសរុប និងផ្ញើជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមុនដំណាច់ខែធ្នូនៃឆ្នាំ។
- ការកសាងផែនការជ្រើសរើស ត្រូវបញ្ជាក់អំពីតម្រូវការ និងមុខងារចាំបាច់នៃការងារ រួមទាំងជំនាញ និងសមត្ថភាពដែលទាមទារក្នុងការបំពេញការងារ។
- ត្រូវផ្សព្វផ្សាយដំណឹងជ្រើសរើសឲ្យចូលក្នុងក្របខណ្ឌមន្ត្រីរាជការ កម្មករ និងនិយោជិត ឱ្យបានទូលំទូលាយតាមគ្រប់រូបភាព ជាអាទិ៍ៈ បញ្ជរព័ត៌មាន គេហទំព័រ កាសែត វិទ្យុ ទូរទស្សន៍ ខិត្តប័ណ្ណ។ល។ តាមកាលបរិច្ឆេទ យ៉ាងតិចចំនួន ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃចូលប្រឡង។ ការផ្សព្វផ្សាយដំណឹងជ្រើសរើសត្រូវបង្ហាញពីតម្រូវការ និងការលើកទឹកចិត្តជនពិការ និងស្ត្រីពិការ។
- ពាក្យសុំចូលបម្រើការងារ ត្រូវរៀបចំឲ្យមានភាពសាមញ្ញ និងងាយស្រួលសម្រាប់ជនពិការ។
- ត្រូវផ្តល់ការសម្របសម្រួលក្នុងការបំពេញ និងការដាក់ពាក្យសុំចូលបម្រើការងាររបស់ជនពិការ។
- ក្រសួង ស្ថាប័នរដ្ឋត្រូវធ្វើការជ្រើសរើសបេក្ខជនប្រឡងចូលក្នុងក្របខណ្ឌមន្ត្រីរាជការ តាមនីតិវិធីជាធរមាន និងគ្មានការរើសអើងចំពោះជនពិការ។

- នីតិបុគ្គលត្រូវធ្វើការជ្រើសរើសតាមរយៈការជ្រើសរើសបឋម និងរៀបចំការប្រឡងសាកល្បងសមត្ថភាពដោយផ្តល់នូវលក្ខខណ្ឌសមស្របតាមប្រភេទពិការភាព និងគ្មានការរើសអើងចំពោះជនពិការ។
- ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវជូនដំណឹងជាមុនដល់បេក្ខជនមកសម្ភាសន៍ដោយលើកទឹកចិត្តបេក្ខជនជាជនពិការឲ្យបញ្ជាក់ពីតម្រូវការ និងការសម្របសម្រួលផ្សេងៗ ដែលត្រូវការក្នុងពេលសម្ភាសន៍។
- ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវសម្របសម្រួលរៀបចំកន្លែងសម្ភាសន៍ដែលមានលក្ខណៈងាយស្រួលក្នុងការចល័តចេញចូល និងប្រើប្រាស់ ដោយគ្មានឧបសគ្គដល់បេក្ខជនពិការ។ ឧបករណ៍ជំនួយ ឬមធ្យោបាយផ្សេងៗ ដែលជួយសម្រួលក្នុងដំណើរការសម្ភាសន៍ត្រូវរៀបចំឱ្យមានភាពងាយស្រួល តាមប្រភេទពិការភាពរបស់បេក្ខជន លើកលែងតែការសម្របសម្រួលនោះមានបន្ទុកធ្ងន់ធ្ងរហួសហេតុ។

## ៣. ការណែនាំការងារ និងការអភិវឌ្ឍ

ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវ៖

- ចង្អុលបង្ហាញ និងពិគ្រោះយោបល់ជាមួយជនពិការក្នុងការផ្តល់ការងារជូន ដោយផ្តោតលើបរិស្ថានការងារ កន្លែងធ្វើការ កម្មវិធីការងារ ការបណ្តុះបណ្តាល និងការគាំទ្រផ្ទាល់ខ្លួន។
- ផ្តល់ឱកាសស្មើគ្នាជូនបុគ្គលិកពិការ និងមិនពិការ ក្នុងការទទួលបានការបណ្តុះបណ្តាលបំពេញសមត្ថភាពបន្ថែម។
- រៀបចំការបណ្តុះបណ្តាលបុគ្គលិកទូទៅ ឲ្យយល់ដឹងអំពីពិការភាព ជំរុញការលុបបំបាត់ការរើសអើង និងការទទួលស្គាល់សមត្ថភាពរបស់បុគ្គលិកពិការ។

## ៤. បរិស្ថានការងារ និង កន្លែងធ្វើការ

ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវ៖

- កែប្រែ និងសម្របសម្រួលលើផ្នែកបរិក្ខារ និងបរិស្ថានកន្លែងធ្វើការ ឲ្យមានការចល័ត និងងាយស្រួលចេញចូលបាន ដូចជា អគារមានជំរាល ច្រកចេញចូលធំទូលាយ បន្ទប់អនាម័យសមស្រប និងមានបំពាក់ឧបករណ៍ផ្ទាក់ដៃ ជណ្តើរយន្តបំពាក់អក្សរស្ទាប និងឧបករណ៍ជំនួយផ្សេងៗ សមស្របសម្រាប់ជនពិការ។
- ផ្តល់សេវាទៅតាមតម្រូវការប្រភេទពិការ និងសម្រួលលើឧបករណ៍ សម្ភារប្រើប្រាស់ក្នុងការិយាល័យ ដូចជា កុំព្យូទ័របំពាក់បន្ថែមនូវឧបករណ៍ជំនួយ និងកម្មវិធីផ្សេងៗ ដែលនិយោជិតជាជនពិការអាចប្រើប្រាស់ ដើម្បីបំពេញការងារបាន។
- រៀបចំចំណតយានយន្ត និងបំពាក់ស្លាកសញ្ញាសម្គាល់សម្រាប់ជនពិការ ដូចជា កម្ពស់ចិញ្ចើមផ្លូវ ឬជណ្តើរឲ្យស្មើនឹងច្រកទ្វារយានយន្ត ស្លាកសម្គាល់បន្ទប់អនាម័យ ។ល។

## ៥. សុខភាព និង សុវត្ថិភាពការងារ

- ក្នុងករណី មានតម្រូវការពិនិត្យសុខភាព វាយតម្លៃលើជំនាញ និងសមត្ថភាពរបស់មន្ត្រីរាជការ និងកម្មករនិយោជិត ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវធានាថា គ្មានការលំអៀង និងគ្មានការរើសអើងដោយសារពិការភាព។
- ការពិនិត្យ និងវាយតម្លៃសុខភាពផ្លូវចិត្ត មន្ត្រីរាជការ និងកម្មករនិយោជិត ត្រូវបានហាមឃាត់ លើកលែងតែការពិនិត្យ និងវាយតម្លៃ ធ្វើឡើងដោយអ្នកឯកទេសជំនាញ តាមលក្ខណៈវិទ្យាសាស្ត្រ ដែលអាចទទួលយកបាន។ ការពិនិត្យ និងវាយតម្លៃនោះធ្វើឡើងដោយមានភាពត្រឹមត្រូវចំពោះមន្ត្រីរាជការ និងកម្មករនិយោជិតទាំងអស់ និងដោយគ្មានការរំលោភបំពាន។
- ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវមានកាតព្វកិច្ចផ្តល់ និងថែរក្សាសុវត្ថិភាពការងារ ចំពោះមន្ត្រីរាជការ និងកម្មករនិយោជិត ដែលជាជនពិការ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- នីតិបុគ្គលត្រូវជន្លៀសនិយោជិតជាជនពិការជាអាទិភាព ចេញពីអគារ ឬទីកន្លែងធ្វើការ ដោយសុវត្ថិភាពនៅពេលមានគ្រោះអាសន្ន។

## ៦. ការលើកទឹកចិត្ត និងការផ្លាស់ប្តូរការងារ

- ប្រធាន ក្រសួង ស្ថាប័នរដ្ឋ ត្រូវអនុវត្តនីតិវិធីក្នុងការវាយតម្លៃការងារសម្រាប់លើកទឹកចិត្តមន្ត្រីរាជការ រួមមាន ការដំឡើងថ្នាក់ ឋានន្តរសក្តិ មុខតំណែង ការផ្តល់គ្រឿងឥស្សរិយយស ការផ្តល់រង្វាន់លើកទឹកចិត្ត ត្រូវផ្អែកលើគុណវុឌ្ឍិ ដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌរបស់ខ្លួន ដោយធានានូវតម្លាភាព និងគ្មានការលំអៀងដោយសារពិការភាព។
- នីតិបុគ្គល ត្រូវផ្តល់ការលើកទឹកចិត្តដល់កម្មករនិយោជិត ដោយផ្អែកលើប្រសិទ្ធភាពការងារ ដោយធានានូវតម្លាភាព និងគ្មានការលំអៀងដោយសារពិការភាព។
- ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវផ្តល់ការសម្របសម្រួលដល់មន្ត្រីរាជការ និងកម្មករនិយោជិតជាជនពិការក្នុងការស្នើសុំផ្លាស់ប្តូរកន្លែងការងារ ឬផ្ទេរការងារដោយផ្អែកលើហេតុផលសមស្រប និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៧. ការរក្សាស្ថិរភាពការងារ និងការចូលបម្រើការងារឡើងវិញ

ប្រធានក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ត្រូវ៖

- ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីរាជការ និងកម្មករនិយោជិតជាជនពិការ ក្នុងការពិគ្រោះយោបល់ដើម្បីឆ្លើយតបនឹងតម្រូវការ និងរក្សាបានស្ថិរភាពការងារ ដូចជា ការផ្តល់សេវាស្តារលទ្ធភាពពលកម្ម ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការទទួលបាននូវផលប្រយោជន៍ដោយគ្មានការរើសអើង។
- មានវិធានការជួយគាំទ្រដល់មន្ត្រីរាជការ និងកម្មករនិយោជិតនៅពេលធ្លាក់ខ្លួនពិការដោយសារគ្រោះថ្នាក់ការងារ ឬជំងឺ ជាអាទិ៍ ការគាំទ្រផ្លូវចិត្ត ការផ្តល់សេវាសុខភាព ការស្តារលទ្ធភាពពលកម្ម ការរក្សាការងារ ការផ្តល់ឱកាសចូលបម្រើការងារឡើងវិញ សមស្របនឹងប្រភេទនិងកម្រិតពិការ និងការជួយគាំទ្រ ពិសេសផ្សេងៗតាមលទ្ធភាពរបស់អង្គភាព។

គ្រប់ក្រសួង ស្ថាប័នរដ្ឋ នីតិបុគ្គល អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងវិស័យឯកជន ត្រូវផ្សព្វផ្សាយ និងអនុវត្តសារាចរនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ចាន់ សុខ**

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**វ៉ិត សំហេង**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- ក្រុមប្រឹក្សាសកម្មភាពជនពិការ
- មូលនិធិជនពិការ
- នីតិបុគ្គល អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ..០៦...[illegible]

# សារាចរណែនាំ
# ស្តីពី
# ការចាត់តាំងខួបលើកទី៣៤ ទិវាជនពិការអន្តរជាតិ និងខួបលើកទី១៨ ទិវាជនពិការកម្ពុជា ក្រោមប្រធានបទ "ផ្តល់អាទិភាព និងសិទ្ធិអំណាចដល់ជនពិការ ក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព"
## ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៦

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាតែងប្រារព្ធទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ នៅថ្ងៃទី០៣ ខែធ្នូ ដើម្បីរំលឹកដល់ការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលលើវិស័យពិការភាព ជាពិសេសសុខុមាលភាពបងប្អូនជនពិការកម្ពុជា ស្របតាមអនុសញ្ញាស្តីពីសិទ្ធិជនពិការ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" ក៏ដូចជាផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨។

ទិវាជនពិការអន្តរជាតិត្រូវបានប្រារព្ធឡើង ដើម្បីរំលឹកអំពីការតស៊ូទាមទារសិទ្ធិចូលរួមក្នុងសង្គមរបស់ជនពិការប្រមាណ ១ប៊ីលាននាក់ ស្មើនឹងចំនួន ១៥% នៃប្រជាជនសរុបនៅក្នុងពិភពលោក ដែលជាជនបាត់បង់កាយសម្បទា កាយវិញ្ញាណ និងសតិបញ្ញា ដែលតែងតែជួបប្រទះឧបសគ្គរាំងក្នុងជីវិត តាំងពីឆ្នាំ១៩៥០ នៅសហរដ្ឋអាមេរិក និងអឺរុប សំដៅធ្វើការផ្លាស់ប្តូរនូវស្ថានភាពរស់នៅរបស់ពួកគេ និងបង្កើនការយល់ដឹងអំពីបញ្ហាពិការភាព ដោយផ្តោតសំខាន់លើសិទ្ធិជនពិការ ព្រមទាំងការធ្វើសមាហរណកម្មជនពិការទៅក្នុងគ្រប់សកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ និង កីឡា។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាប្រារព្ធទិវាជនពិការនេះឡើង ដើម្បីរំលឹកអំពីមហាវិនាសកម្មនៃរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានបន្សល់ទុកនូវផលវិបាកជាច្រើន ក្នុងនោះរួមមានជនពិការ ស្ត្រីមេម៉ាយ កុមារកំព្រា ព្រមទាំងគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។ ក្រៅពីនោះ ប្រជាជនកម្ពុជាក៏ប្រឈមនឹងភាពងគ្រោះមួយចំនួនទៀតដែលនាំឲ្យមានពិការភាពដូចជា គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់ការងារ ពិការពីកំណើត ចាស់ជរា ជំងឺ និងមូលហេតុផ្សេងៗទៀត។

ដើម្បីអបអរសាទរទិវាជនពិការកម្ពុជាលើកទី១៨ និងទិវាជនពិការអន្តរជាតិលើកទី៣៤ ឆ្នាំ២០១៦នេះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំចាត់តាំងដូចតទៅ៖

១.ទិវាជនពិការកម្ពុជាលើកទី១៨ និងទិវាជនពិការអន្តរជាតិលើកទី៣៤ ត្រូវប្រារព្ធក្រោមប្រធានបទ "**ផ្តល់អាទិភាព និងសិទ្ធិអំណាចដល់ជនពិការក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព**"។

២.ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជន ឱ្យធ្វើការផ្សព្វផ្សាយដល់សង្គមជាតិទាំងមូលឱ្យបានយល់ជ្រួតជ្រាបអំពីប្រវត្តិនៃទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ៣ធ្នូ។

៣.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំពិធីមីទ្ទិញ ពិធីជួបសំណេះសំណាលជាមួយជនពិការ កម្មវិធីកម្សាន្តសប្បាយរបស់ជនពិការ នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលនៅក្នុងមូលដ្ឋានរៀងៗខ្លួន។

៤.ក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា មូលនិធិជនពិការ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធត្រូវសហការរៀបចំពិធីមីទ្ទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកម្សាន្តផ្សេងៗសម្រាប់ជនពិការនៅរាជធានីភ្នំពេញ។

៥.គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ ឯកជន ត្រូវរៀបចំចងបដា ពាក្យស្លោកដើម្បីអបអរសាទរទិវាជនពិការកម្ពុជាលើកទី១៨ និងទិវាជនពិការអន្តរជាតិលើកទី៣៤ ដែលមានខ្លឹមសារដូចខាងក្រោម៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- ផ្តល់អាទិភាព និងសិទ្ធិអំណាចដល់ជនពិការក្នុងគ្រប់វិស័យដើម្បីសង្គមមួយគ្មានពិការភាព
- ផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកដើម្បីឃើញពីធាតុពិតរបស់ជនពិការ
- កាត់បន្ថយភាពក្រីក្ររបស់ជនពិការ តាមរយៈការផ្តល់ឱកាសការងារស្មើគ្នា
- រួមគ្នាអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សម្រាប់អនាគតយើង
- កែសម្រួលនិងរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបរិស្ថានគ្មានពិការភាព
- ជនពិការត្រូវការផ្តល់តម្លៃជាជាងការអាណិត

ទទួលបានសារាចរណែនាំ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានី ខេត្តត្រូវរៀបចំចាត់តាំងអនុវត្តក្នុងស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## Annex 5: MAPPING BY PROVINCE OF ORGANIZATIONS/SERVICES PROVIDERS WORKING WITH AND FOR ADULTS AND CHILDREN WITH DISABILITIES IN CAMBODIA[118]

**Phnom Penh**
- ADD
- Aide et Action (AeA)
- All Ears Cambodia (AEC)
- Artisans Association of Cambodia
- Association for Aid and Relief, Wheelchairs for Development (AAR-WCD)
- ABC
- Association for Music and Disabled People
- Australian Centre for Education
- CDPO
- CDMD
- Cambodia Trust
- Cambodian National Volleyball League (Disabled)
- Cambodian Volunteers for Community Development (CVCD)
- Cambodian Youth with Disabilities and Development
- CABDICO
- Caritas-Centre for Child and Adolescent Mental Health (CCAMH)
- Children’s Surgical Centre
- CBM
- Deaf Development Program (DDP)
- Development Technology Workshop
- Digital Divided Data
- Hagar House of Smiles
- HIF
- ICRC
- IDP Education (Cambodia)
- International Resource for Improvement of Sight (IRIS)
- Japan-Cambodia Interactive Association
- Jesuit Service Cambodia (JSC)
- Khmer Association for Vocational Training and Vocation
- KPF
- KT
- Light of Mercy Home Children’s Centre
- NCDP
- National Paralympic Committee of Cambodia
- New Humanity
- PACHID
- Phnom Penh Centre for Independent Living
- Pour des Sourir des Enfants
- Rabbit School
- Rehab Craft Cambodia
- Reverse the Curse Cambodia
- Rose Charity
- Social Services Cambodia (SSC)
- Transcultural Psychosocial Organisation (TPO)
- VI-C
- Watthan Artisans Cambodia
- YODIFEE

**Banteay Meanchey**
- ABC
- CABDICO
- CDPO
- Cambodian Human Resource Development
- Help Age International
- ICRC
- JSC
- KT
- OEC
- Solidarity Disabled Organization
- TPO

**Battambang**
- ABC
- AEC
- Arrupe Centre
- Battambang Disabled People’s Organisation
- CDPO
- Cambodian Spinal Cord Injury Association
- CVCD
- CCAMH
- Digital Divided Data
- Handa Emergency Hospital
- Help Age International
- HIF
- ICRC
- ILDO
- IRIS
- JSC
- KNKS
- KPF
- KT
- OEC
- Spirit of Soccer
- TPO
- Trauma Care Foundation (TCF)
- YODIFEE

**Kampong Cham**
- ABC
- CDPO
- DDP
- HIF
- KT
- OEC
- Plan Cambodia
- Representative Self-Help Disabilities Organization Batheay District
- Women & Children with Disability Forum

<table>
<tr><td>Kampong Chhnang<br>• ADD<br>• AEC<br>• Cambodia Trust<br>• CDPO<br>• Chulkiri District Disabled People’s Development Organization<br>• Kampong Trolach Disability Development Federation<br>• Landmine Disability Support<br>• New Humanity<br>• OEC</td><td rowspan="2">Kampong Speu<br>• ABC<br>• ADD<br>• Borsat Disabled People’s Development Organization<br>• CDMD<br>• CDPO<br>• Cambodian Disabled People’s Development Federation<br>• Cambodian Saving Disabled People’s Association<br>• Disabled People’s Organization Representative Kampong Speu<br>• Disabled Women Forum<br>• ICRC<br>• Kong Pisey Disability Development Federation<br>• NCDP<br>• Oddong Disability Development Federation<br>• Social Services of Cambodia<br>• Somrong Tong Disability Development Federation<br>• Svay Krovann Disabled People’s Development Federation<br>• Vor Sor Disability Development Federation</td></tr>
<tr><td>Kampong Thom<br>• ABC<br>• ADD<br>• CDPO<br>• CCAMH<br>• HIF<br>• JSC<br>• Organization for Disability Development Kampong Thom Province<br>• TPO</td></tr>
<tr><td>Kampot<br>• AAR-WCD<br>• ABC<br>• ADD<br>• AEC<br>• Angkor Chey Disabled People’s Federation Organization<br>• CDMD<br>• CDPO<br>• Chum Kiri Disabled People’s Development Federation<br>• DDP<br>• Dong Tong Disability Development Federation<br>• Epic Arts<br>• KPF<br>• NCDP<br>• Women & Children with Disability Forum in Kampot<br>• YODIFEE</td><td>Kandal<br>• AAR-WCD<br>• AEC<br>• Banteay Prieb Vocational Training School<br>• CDMD<br>• CDPO<br>• CCAMH<br>• Hagar House of Smiles<br>• JSC<br>• Kandal Steung Disabled People’s Development Organization<br>• Lavalla School for the Physically Disabled<br>• Marist Solidarity Cambodia<br>• NCDP<br>• Representative for Disability Development Organization in Kandal<br>• Rose Cambodia Rehabilitation Centre<br>• SSC<br>• VI-C<br>• Women & Children with Disability Forum<br>• YODIFEE</td></tr>
<tr><td>Kep<br>• AeA<br>• AEC<br>• CABDICO<br>• CDPO<br>• Persons with Disability Organization in Kep</td><td>Kratie<br>• ABC<br>• CDPO<br>• Kratie Disabled People’s Organization<br>• Kratie Disabled Women Forum<br>• VI-C</td></tr>
</table>

| | |
|---|---|
| **Koh Kong**<br>• CDPO<br>• Koh Kong Disabled People's Organization<br>• OEC | **Mondulkiri**<br>• CANDO<br>• CDPO<br>• Italian Association for Aid to Children (CIAI)<br>• Mondulkiri Disabled People's Organization<br>• Senmonorom Disabled People's Federation Organization |
| **Oddar Meanchey**<br>• CDPO<br>• ICRC<br>• Jesuit Refugee Service (JRS)<br>• People with Disability Organization in Oddar Meanchey | **Pailin**<br>• Arrupe Centre<br>• CDPO<br>• DDSP<br>• Disabled People's Organization in Pailin<br>• ICRC<br>• TCF |
| **Prey Veng**<br>• ABC<br>• ADD<br>• CDPO<br>• Porieng Disability Federation Organization<br>• Svay Antor Disabled People's Development Organization<br>• Women & Children with Disability Forum Prey Veng<br>• VI-C | **Preah Sihanouk**<br>• ABC<br>• AEC<br>• Cambodia Trust<br>• CDPO<br>• KT<br>• NCDP<br>• Preah Sihanouk Disabled People's Organization<br>• Prey Nob Disabled People's Federation Organization<br>• Starfish Foundation |
| **Preah Vihear**<br>• CDPO<br>• JRS<br>• Minority Organization for Development of Economy (MODE)<br>• Representative Disability Organization in Preah Vihear Province<br><br>**Pursat**<br>• ABC<br>• AeA<br>• AEC<br>• Bakan Disabled People's Organization<br>• CDPO<br>• DDSP<br>• ICRC<br>• KNKS<br>• OEC<br>• Organization for Disability Development in Pursat Province<br><br>**Ratanakiri**<br>• CANDO<br>• CDPO<br>• CIAI<br>• NCDP<br>• New Humanity<br>• Plan Cambodia<br>• Ratanakiri Disabled People's Organization | **Siem Reap**<br>• ABC<br>• ADD<br>• AEC<br>• Angkor Association for Disabled<br>• Angkor Hospital for Children<br>• CABDICO<br>• CDPO<br>• Ensure Khmer Disabled Assistance Organization<br>• Friends Cambodia<br>• Grace House Community Care<br>• Krolanh Disabled People's Development Federation<br>• JRS<br>• JSC<br>• KPF<br>• KT<br>• OEC<br>• Plan Cambodia<br>• People with Disability Organization in Siem Reap<br>• Safe Haven Cambodia<br>• SIFA Organization<br>• Srey Snom Disability Development Federation<br>• TPO |

| | |
|---|---|
| **Stung Treng**<br>• CDPO<br>• Disabled People's Voice Organization in Stung Treng<br>• Strung Treng Disabled People's Organization | **Takao**<br>• AAR-WCD<br>• ADD<br>• Bati Disability Development Federation<br>• CDMD<br>• CDPO<br>• Community Council for Development Organization<br>• Disabled Youths, Children Foundation for Education<br>• Federation for Disability Development Kirivong<br>• NCDP<br>• Somrong Development Organization for Disabled Orphan and the Poor<br>• Takeo Disabled Women Forum<br>• Tramkok Disabled People's Development Organization<br>• Union of Disabled Development Prey Kabas District Organization |
| **Svay Rieng**<br>• AAR-WCD<br>• ADD<br>• CDPO<br>• Federation for Disability Development Romeas Hek District<br>• Svay Chrum Disabled People's Federation Organization<br>• Svay Teab Disabled Development Federation<br>• Union of Disabled Rehabilitation Kompong Ro<br>• Women & Children with Disability Forum<br>• VI-C | |

* In addition to the above, the Cambodian Red Cross provides health care and other services and assistance in all provinces and districts with the aim of contributing to poverty reduction among the most vulnerable. It is not clear to what extent persons with disabilities and their families are accessing these services.

# អង្គការដែលធ្វើការងារជាមួយ ឬផ្តល់សេវាដល់ជនពិការ

**អង្គការ អេឌីឌីអន្តរជាតិកម្ពុជា** ( ADD International Cambodia )

ក្រុមគោលដៅ ៖ អង្គការជនពិការ
តំបន់គោលដៅ ៖ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ ព្រៃវែង សៀមរាប កំពង់ធំ ស្វាយរៀង តាកែវ កណ្តាល កំពង់ចាម កំពត
អាសយដ្ឋាន ៖ ផ្ទះលេខ៧៤ ផ្លូវលេខ៥៨៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៨៨៥ ០០៦

**អង្គការ ត្រចៀកកម្ពុជា** ( All Ears Cambodia )

ក្រុមគោលដៅ ៖ ជនពិការថ្លង់ និងអ្នកដែលពិបាកស្តាប់
តំបន់គោលដៅ ៖ ភ្នំពេញ និង ទទួលពីខេត្ត ក្រុង ក្នុងប្រទេសកម្ពុជា
អាសយដ្ឋាន ៖ ផ្ទះលេខ ១០៩ z ផ្លូវលេខ ២២៨ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១១ ៧៧៥ ០៦៣

**សមាគមនៃជនពិការភ្នែកកម្ពុជា** ( Association of the Blind in Cambodia - ABC )

ក្រុមគោលដៅ ៖ ជនពិការភ្នែក និងអ្នកខ្សោយគំហើញ
តំបន់គោលដៅ ៖ ភ្នំពេញ កំពង់ស្ពឺ កំពង់ចាម ក្រុងព្រះសីហនុ
អាសយដ្ឋាន ៖ ផ្ទះលេខ១១F ផ្លូវលេខ៦០C សង្កាត់ស្ទឹងមានជយ័ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៦១៨ ៨៨២

**អង្គការជនពិការកម្ពុជា** ( CDPO )

ក្រុមគោលដៅ ៖ ជនពិការគ្រប់ប្រភេទ
តំបន់គោលដៅ ៖ ទូទាំងប្រទេសកម្ពុជា
អាសយដ្ឋាន ៖ វត្តថាន់ មហាវិថីព្រះនរោត្តម ទន្លេបាសាក់ ចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ២២១ ៨២៣/០១២ ៨៥១ ៨៤១

**អង្គការ កម្ពុជាត្រាស់/អិចសីដ** ( Cambodia Trust/Exceed )

ក្រុមគោលដៅ ៖ ឧបករណ៍រណប និងអវៈយវៈសប្បនិម្មិត
តំបន់គោលដៅ ៖ ភ្នំពេញ ព្រះសីហនុ ( កំពង់សោម ) និងកំពង់ឆ្នាំង
អាសយដ្ឋាន ៖ ផ្ទះលេខ ២០សេ ក្រុមទី៣ ផ្លូវដួងងៀប សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៨៨១ ៤៩៤/០២៣ ៨៦៤ ០៤៦

**អង្គការ អភិវឌ្ឍន៍សមត្ថភាពដើម្បីសហប្រតិបត្តិការជនពិការ** ( CABDICO )

ក្រុមគោលដៅ ៖ ជនពិការ ការព្យាបាលអ្នកដែលមានបញ្ហាខាងនិយាយ
តំបន់គោលដៅ ៖ សៀមរាប កែប
អាសយដ្ឋាន ៖ កុដលេខ ៤៣ ( ក្នុងវត្តសារាវ័ន្ត ) ផ្លូវលេខ ១៧៨ ( ជិតកែងផ្លូវនរោត្តម ) ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១៧ ៤៥៤ និង ០១២ ៨៨៣ ៦៤៧

**កម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់ (DDP)**

ក្រុមគោលដៅ ៖ ជនពិការថ្លង់ អ្នកពិបាកស្តាប់

តំបន់គោលដៅ ៖ កំពង់ចាម ភ្នំពេញ កំពត

អាសយដ្ឋាន ៖ ផ្ទះលេខ៧ អា ផ្លូវលេខ ១០១ បឹងត្របែក រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៩៨៧ ៩៣១ និង ០១៧ ៩៩៣ ៣២១ និង ០១២ ៧៦៣ ៧៧៦

**អង្គការ សេវាអភិវឌ្ឍន៍ជនពិការ ខេត្តពោធិ៍សាត់**

ក្រុមគោលដៅ ៖ កុមារ និង មនុស្សចាស់ពិការ

តំបន់គោលដៅ ៖ ពោធិ៍សាត់ និង ខេត្តប៉ៃលិន

អាសយដ្ឋាន ៖ ភូមិពាលញែក ២ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

ទូរស័ព្ទ ៖ ០៩២ ២៦៦ ៤៩៣ និង ០៥២ ៩៥១៤៩៥

**មូលនិធិ ហ្វ្រេតហូលូកម្ពុជា Fred Hollows Foundation**

ក្រុមគោលដៅ ៖ សុខភាពភ្នែកទូទៅ លើកកម្ពស់យេនឌ័ និងជនពិការឲ្យបានទទួលសេវាភ្នែក

តំបន់គោលដៅ ៖ រាជធានីភ្នំពេញ មន្ទីរពេទ្យខ្មែរ សូវៀត មន្ទីរពេទ្យអង្គឌួង មន្ទីរពេទ្យក្រុងភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ធំ សៀមរាប ឧត្តរមានជ័យ ប៉ៃលិន ព្រះវិហារ ព្រះសីហនុ ព្រៃវែង

អាសយដ្ឋាន ៖ ប្រអប់សំបុត្រ ៥១៨ បន្ទប់២០១ ការិយាល័យ ១៦០ ផ្លូវលេខ៧១ ទន្លេបាសាក់ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ (៨៥៥)២៣ ៩៨៧ ៨៣១

**អង្គការ មូលនិធិកុមារពិការ**

ក្រុមគោលដៅ ៖ កុមារ និងយុវជនពិការ កម្រិតមធ្យមនិងធ្ងន់ធ្ងរ (រាងកាយ និងសតិបញ្ញា)

តំបន់គោលដៅ ៖ ភ្នំពេញ កំពត ក្រចេះ

អាសយដ្ឋាន ៖ កុដលេខ ៤៣ (ក្នុងវត្តសារាវន្ត) ផ្លូវលេខ ១៧៨ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១០ ៤៤៧ និង ០១២ ៨៤៣ ៤៦៦

**អង្គការ គ្រួសារថ្មី**

ក្រុមគោលដៅ ៖ ជនពិការភ្នែក និងខ្សោយគំហើញ, ជនពិការថ្លង់ និងខ្សោយខាងការស្តាប់

តំបន់គោលដៅ ៖ ១៤ រាជធានី ខេត្តក្នុងប្រទេសកម្ពុជា និងជាពិសេស រាជធានីភ្នំពេញ ខេត្តកំពង់ចាម សៀមរាប បាត់ដំបង សិរីសោភ័ណ កំពង់សោម

អាសយដ្ឋាន ៖ ផ្ទះលេខ ៤ ផ្លូវលេខ ២៥៧ ទឹកល្អក់ ១ ទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៨៨០ ៥០៣

**អង្គការ មនុស្សលោកថ្មី**

ក្រុមគោលដៅ ៖ ជនពិការ

តំបន់គោលដៅ ៖ ខេត្តកំពង់ឆ្នាំង
អាសយដ្ឋាន ៖ ប្រអប់សំបុត្រលេខ ៤៨ ផ្ទះលេខ ១៩ ផ្លូវលេខ ៣១៧ បឹងកក់ ១ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ២២០ ២៦៣

**អង្គការ សប្បុរសធម៌ Rose Charity**
ក្រុមគោលដៅ ៖ ព្យាបាលភ្នែក
តំបន់គោលដៅ ៖ រាជធានីភ្នំពេញ
អាសយដ្ឋាន ៖ កន្លែងវះកាត់ មន្ទីរពេទ្យបង្អែកជ័យជំនះ ផ្លូវជាតិលេខ ២ ក្រុងតាខ្មៅ ខេត្តកណ្ដាល
ទូរស័ព្ទ ៖ ០១២ ៩៤០ ៣១២/០២៤ ៩៨៥ ៧៦៧

**អង្គការ ចិត្តសង្គមអន្តរវប្បធម៌ (TPO) កម្ពុជា**
ក្រុមគោលដៅ ៖ សុខភាពផ្លូវចិត្ត និងស្តារលទ្ធភាពចិត្តសង្គម
តំបន់គោលដៅ ៖ រាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប កំពង់ធំ ត្បូងឃ្មុំ កំពង់ចាម កណ្ដាល កំពង់ឆ្នាំង
អាសយដ្ឋាន ៖ ផ្ទះលេខ២-៤ ផ្លូវលេខ១៩៥២ សង្កាត់ភ្នំពេញថ្មី រាជខណ្ឌសែនសុខ ជានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៦៣៦ ៦៩៩២

**អង្គការ អតីតយុទ្ធជនអន្តរជាតិកម្ពុជា**
ក្រុមគោលដៅ ៖ ស្តារលទ្ធភាពកាយសម្បទា
តំបន់គោលដៅ ៖ រាជធានីភ្នំពេញ ខេត្តកណ្ដាល ក្រចេះ ព្រៃវែង និងស្វាយរៀង
អាសយដ្ឋាន ៖ ផ្លូវជាតិ ៦អា ភូមិកៀនឃ្លាំង សង្កាត់ជ្រោយចង្វារ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ៤៣០ ៩៤២/ ០១១ ៧២៨ ៧០២

**អង្គការ ជនពិការអន្តរជាតិ**
ក្រុមគោលដៅ ៖ ជនពិការកាយសម្បទា (ផ្តល់អវៈយវៈសិប្បនិម្មិត រណបនិងឧបករណ៍ជំនួយចលត័ភាព
តំបន់គោលដៅ ៖ រាជធានីភ្នំពេញ សៀមរាប កំពង់ចាម
អាសយដ្ឋាន ៖ ផ្ទះលេខ ៩AB ផ្លូវលេខ៤៤៦ សង្កាត់ទួលទំពូងI ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១២ ៨៩៧/(៨៥៥) ២៣ ២១៧ ៣០០

*បញ្ជីឈ្មោះអង្គការខាងលើមិនមែនជាបញ្ជីរាយឈ្មោះគ្រប់អង្គការនោះទេ។ សម្រាប់ព័ត៌មានបន្ថែម អាចទំនាក់ទំនងទៅកាន់អង្គការទាំងនេះ ហើយអង្គការទាំងនេះប្រហែលជាអាចជួយអ្នកក្នុងការទំនាក់ទំនងជាមួយអង្គការដែលអ្នកត្រូវការ។

## ៤.២. របៀបធ្វើការប្រាស្រ័យទាក់ទងជាមួយជនពិការគ ថ្លង់ ឬអ្នកដែលខ្សោយខាងការស្តាប់

ដំបូន្មានមួយចំនួនសម្រាប់ប្រាស្រ័យទាក់ទងជាមួយនឹងជនពិការគ-ថ្លង់ ឬអ្នកដែលពិបាកស្តាប់ ៖



- ទាក់ទាញការយកចិត្តទុកដាក់របស់ជនពិការគ-ថ្លង់ ប្រសិនបើគាត់មិនប្រតិកម្មតបទេនោះ សូមប៉ះដៃ ឬស្មារបស់គាត់ថ្នមៗ ឬបក់ដៃហៅគាត់
- សួរថាតើគាត់ចង់បានការប្រាស្រ័យទាក់ទងដោយរបៀបណា
- ឈរបែរមុខទៅរកគាត់។ អ្នកដែលមានពិការភាពខាងការស្តាប់ចង់ឃើញមុខរបស់អ្នក ដើម្បីពួកគាត់អាចអាន(មើល)បបូរមាត់របស់អ្នក និងមើលទឹកមុខរបស់អ្នក។ ឈរត្រឹមកម្ពស់ស្មើគ្នានឹងគាត់ ឧទាហរណ៍ ៖ សូមអង្គុយចុះ ប្រសិនបើគាត់អង្គុយ។ កុំដាក់ដៃរបស់អ្នកបាំងមុខរបស់អ្នក
- ផ្លាស់ទៅកន្លែងស្ងាត់ ដើម្បីកុំឱ្យមានសំឡេងរំខាន ឬមានសំឡេងរំខានតិចតួច
- ឈរក្បែរគាត់ ដើម្បីឱ្យអ្នកដែលពិបាកស្តាប់ អាចស្តាប់ឮអ្នកនិយាយឱ្យបានប្រសើរបំផុត
- មានភ្លើងបំភ្លឺគ្រប់គ្រាន់ ដើម្បីឱ្យគាត់អាចមើលឃើញអ្នកបានច្បាស់
- និយាយច្បាស់ៗ និងក្នុងកម្រិតសំឡេងធម្មតា(សូមកុំស្រែក)
- សួរថា តើគាត់យល់ពីអ្វីដែលអ្នកបាននិយាយដែរឬទេ ដូចជាឱ្យគាត់ផ្តល់ព័ត៌មានត្រឡប់
- និយាយសារសំខាន់ៗឡើងវិញ ដូចជា សរសេរសារទាំងនេះ ជាដើម
- ប្រើប្រាស់ទឹកមុខ និងកាយវិការ ដើម្បីគាំទ្រដល់អ្វីដែលអ្នកនិយាយ
- និយាយទៅគាត់ដោយផ្ទាល់។ សូមកុំនិយាយទៅកាន់សមាជិកគ្រួសារ ឬអ្នកបកប្រែ
- នៅក្នុងអគាររបស់អ្នក សូមដាក់សញ្ញាឱ្យបានច្បាស់ ដើម្បីជួយឱ្យជនពិការគ-ថ្លង់ និងអ្នកពិបាកស្តាប់ដឹងពីកន្លែងដែលត្រូវទៅ
- ផ្តល់ព័ត៌មានជាលាយល័ក្ខណ៍អក្សរ ប្រសិនបើគាត់អាចអាន និងសរសេរបាន។ ត្រៀមប៊ិច និងក្រដាស ក្នុងករណីដែលអ្នកចាំបាច់ត្រូវប្រាស្រ័យទាក់ទងដោយសរសេរ

## ៤.៧. របៀបធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលមានពិការភាពខាងសតិបញ្ញា

ដំបូន្មានមួយចំនួនសម្រាប់ប្រាស្រ័យទាក់ទងជាមួយនឹងអ្នកដែលមានពិការភាពខាងសតិបញ្ញា ៖

- ត្រូវបង្ហាញនូវភាពជាក់ស្តែង
- ចំណាយពេលតាមសម្រួល ហើយបង្កើតនូវការជឿទុកចិត្តគ្នាសិន ដើម្បីឱ្យគាត់មានអារម្មណ៍កក់ក្តៅជាមួយអ្នក
- និយាយឱ្យបានច្បាស់ៗ និងប្រើប្រាស់ប្រយោគខ្លី និងពាក្យពេចន៍ងាយៗ
- និយាយឡើងវិញពីអ្វីដែលអ្នកបាននិយាយ ឬប្រើពាក្យពេចន៍ផ្សេង ដើម្បីបញ្ជាក់ពីអ្វីដែលអ្នកបាននិយាយ
- ប្រើប្រាស់រូបភាព
- កុំប្រើសំឡេងដូចក្មេង ឬនិយាយបំផ្លើស
- ប្រើឯកសារដែលងាយស្រួលអាន អមដោយសារងាយៗ និងប្រយោគខ្លីៗ
- រកកន្លែងស្ងាត់សម្រាប់និយាយ
- ប្រើកាយវិការ និងទឹកមុខ ឧទាហរណ៍ ធ្វើទឹកមុខសោកសៅ នៅពេលដែលអ្នកកំពុងនិយាយ អ្វីមួយ ដែលមិនសប្បាយចិត្ត
- បញ្ជាក់ជាមួយគាត់ថាតើគាត់យល់ពីអ្វីដែលអ្នកកំពុងនិយាយដែរឬទេ។

## ៤.៤. របៀបធ្វើការប្រាស្រ័យទាក់ទងជាមួយនិងអ្នកដែលខ្សោយគំហើញ

ដំបូន្មានមួយចំនួនសម្រាប់ប្រាស្រ័យទាក់ទងទៅកាន់អ្នកដែលខ្សោយខាងគំហើញ ៖



- ណែនាំខ្លួនអ្នក ដើម្បីឱ្យអ្នកដែលខ្សោយខាងគំហើញស្គាល់ថាអ្នកជាអ្នកណា
- ប្រាប់គាត់ ប្រសិនបើអ្នកទៅឆ្ងាយពីគាត់។ សូមកុំចាកចេញពីគាត់ដោយមិនបានប្រាប់គាត់ថាអ្នកនឹងចាកចេញពីគាត់។
- រៀបរាប់ពីទីកន្លែងដែលអ្នកកំពុងនៅ និងអ្វីដែលអ្នកឃើញឱ្យគាត់ដឹង
- ត្រូវរៀបរាប់ឱ្យបានជាក់លាក់។ និយាយថា "តុនៅចំពីមុខអ្នក" មិនមែន "តុនៅទីនេះ" នោះទេ។
- នៅពេលដែលអ្នកស្ថិតនៅក្នុងក្រុម សូមប្រាប់ពួកគាត់ពីអ្នកដែលកំពុងមានវត្តមាននៅក្នុងក្រុម
- សូមកុំផ្លាស់ប្តូរទីតាំងរបស់វត្ថុនានា ឬទុកអ្វីមួយនៅលើឥដ្ឋដែលអាចធ្វើឱ្យគេដើរជាន់
- នៅពេលដែលអ្នកនិយាយក្នុងក្រុម សូមប្រើប្រាស់ឈ្មោះរបស់គាត់នៅពេលដែលអ្នកចង់និយាយទៅគាត់
- ជានិច្ចកាល សូមនិយាយដោយផ្ទាល់ទៅគាត់។ សូមកុំប្រើមនុស្សទី៣ឱ្យឆ្លើយសំណួររបស់អ្នក
- និយាយបែបធម្មតា និងច្បាស់ៗ។ អ្នកមិនចាំបាច់ស្រែកនោះទេ
- ចៀសវាងកន្លែងដែលមានសំឡេងរំខាន ដើម្បីឱ្យគាត់អាចស្តាប់អ្នកបានច្បាស់
- ជានិច្ចកាល ត្រូវសួរសិនថាតើគាត់ចង់ឱ្យគេជួយដែរឬទេ។ សូមកុំជួយអ្នកណាម្នាក់ដោយមិនបានសួរគាត់ជាមុន
- សម្រាប់អ្នកដែលខ្សោយខាងគំហើញ សូមប្រើប្រាស់សញ្ញា និងឯកសារដែលច្បាស់ៗ អាចជាអក្សរធំៗ ឬ អក្សរដែលអ្នកអាចស្ទាបដឹងបាន
- សម្រាប់អ្នកដែលពិការភ្នែក ហើយអាចអានអក្សរស្ទាបបាន អ្នកអាចផ្តល់ព័ត៌មានលាយល័ក្ខណ៍អក្សរដោយប្រើអក្សរស្ទាប
- បច្ចេកទេសក្នុងការនាំផ្លូវអ្នកពិការគំហើញ ដូចជាការដើរទន្ទឹមគាត់ក្នុងទីធ្លាទូលាយ និងដើរពីមុខគាត់ក្នុងទីធ្លាចង្អៀតក្នុងករណីឡើងជណ្តើរ ឬចូលជណ្តើរយន្តត្រូវពន្យល់គាត់ឱ្យបានច្បាស់ និង និយាយមួយៗរៀបរាប់ប្រាប់គាត់។

# បញ្ជីត្រួតពិនិត្យអគារសាធារណៈសម្រាប់ជនពិការ អាចប្រើប្រាស់បាន

| ការបរិយាយ | ចម្លើយ |
|---|---|
| **១. ទីធ្លាខាងក្រៅ** | |
| តើផ្លូវដើររាបស្មើ មិនមានការរំខានមែនដែរឬទេ? | |
| តើផ្លូវដើរមានទទឹងទំហំ១.៥០ម៉ែត្រ ធំទូលាយគ្រប់គ្រាន់ដែរឬទេ? | |
| តើផ្លូវដើរមានលក្ខណៈមិនរអិលនិងសុវត្ថិភាពដែរឬទេ? | |
| តើច្រកចូលអគារងាយស្រួលសម្រាប់ជនពិការជិះរទេះចេញចូលដែរឬទេ? | |
| **២. ច្រករបៀង** | |
| តើច្រករបៀងមានភាពស្រលះ និងមិនមានអ្វីជារបាំងដែរឬទេ? | |
| តើច្រករបៀងសម្រាប់សាធារណៈដែលមិនសូវមានគេធ្វើដំណើរ មានទទឹងទំហំយ៉ាងតូច ១.៥ម៉ែត្រ ដែរឬទេ? | |
| តើច្រករបៀងមានផ្ទៃរាបស្មើ និងមិនរអិលដែរឬទេ? | |
| តើច្រករបៀងសម្រាប់ធ្វើដំណើរងាយស្រួលរកដែរឬទេ? | |
| **៣. ទ្វារ** | |
| តើទ្វារបើកមានទទឹងប្រហែល០.៨ម៉ែត្រ ដែរឬទេ? | |
| តើអ្នកប្រើប្រាស់ច្រកទ្វារត្រូវឆ្លងកាត់ចំណោតដែលមានកម្ពស់ខ្ពស់ជាង០.០២ម៉ែត្រ ដែរឬទេ? | |
| តើទ្វារងាយស្រួលបើកដោយប្រើដៃតែម្ខាងបានដែរឬទេ? | |
| តើទំហំច្រកទ្វារប្រហែល ១.៥ ម៉ែត្រ គុណនឹង ១.៨ ម៉ែត្រអាចឱ្យជនពិការជិះរទេះបើកទ្វារបានដែរឬទេ? | |
| តើទ្វារងាយស្រួលក្នុងការរកដែរឬទេ? | |

| ការបរិយាយ | ចម្លើយ |
|---|---|
| **៤. ជម្រាល ជណ្ដើរ និងបង្កាន់ដៃ** | |
| តើក្នុងមួយជាន់ៗ មានជណ្ដើរ ឬ ជម្រាលដើម្បីសម្រួលដល់ជនពិការធ្វើដំណើរដែរឬទេ ? | |
| តើចំណោតរបស់ជម្រាលមានកម្ពស់អតិបរមាត្រឹម១/១២ ដែរឬទេ ? | |
| តើជម្រាលមានទទឹងយ៉ាងហោច១ ម៉ែត្រដែរឬទេ ? | |
| តើបង្កាន់ដៃមានកម្ពស់ចន្លោះពី ០.៨ទៅ ០.៩ ម៉ែត្រដើម្បីធ្វើដំណើរដោយសុវត្ថិភាពនៅពេលប្រើជណ្ដើរ ឬជម្រាលដែរឬទេ ? | |
| តើជណ្ដើរ និងជម្រាលងាយរកឃើញដែរឬទេ ? | |
| **៥. បង្គន់ ឬ បន្ទប់ទឹក** | |
| តើមានបង្គន់សម្រាប់ជនពិការប្រើប្រាស់ដែរឬទេ ? | |
| តើបង្គន់សម្រាប់ជនពិការមានដាក់ស្លាកសញ្ញាសម្គាល់ដែរឬទេ ? | |
| **៦. ស្លាកសញ្ញា** | |
| តើមានស្លាកសញ្ញាប្រាប់ពីទីតាំង ឧបករណ៍ និងសម្ភារៈប្រើប្រាស់ផ្សេងៗសម្រាប់ជនពិការបានដឹងដែរឬទេ ? | |
| តើមានផែនទី ផ្ទាំងព័ត៌មាន និងស្លាកសញ្ញាផ្សេងៗនៅលើជញ្ជាំងក្នុងកម្ពស់ដែលសមស្របចន្លោះពី ០.៨ ទៅ ០.៩ ម៉ែត្រ ដែរឬទេ ? | |
| តើព័ត៌មានសំខាន់ៗលើស្លាកសញ្ញាអាចងាយស្រួលសម្រាប់ជនពិការបានដឹង ឬ អានបានដែរឬទេ ? (អក្សរផុស ឬ អក្សរស្ទាបដែលជនពិការអាចអាន) | |
| តើស្លាកសញ្ញាងាយស្រួលរក និងអានដែរឬទេ ? | |

| ការបរិយាយ | ចម្លើយ |
|---|---|
| ៧. ប្រព័ន្ធប្រកាសអាសន្ន | |
| តើទីតាំងដាក់សញ្ញាប្រកាសអាសន្នអាចងាយស្រួលរក ឬ ដឹង ដោយជនពិការដែរឬទេ? | |
| តើមនុស្សគថ្លង់អាចស្គាល់ ឬ ដឹងថាមានការប្រកាស អាសន្ន ដែរឬទេ? | |

## ៤.៧. បញ្ជីផ្ទៀងផ្ទាត់ក្នុងពេលកិច្ចប្រជុំ ឬព្រឹត្តិការណ៍នានា

| ការបរិយាយ/សំណួរគន្លឹះ | បាទ/ចាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|
| ១. ការអញ្ជើញ | | | |
| តើជនពិការ អង្គការជនពិការត្រូវបាន អញ្ជើញដូចអ្នកដទៃដែរឬទេ? | | | |
| តើការអញ្ជើញប្រើប្រាស់ទម្រង់ផ្សេងៗគ្នា (ឧ. លិខិត ឬផ្ទាល់មាត់) ដែរឬទេ? | | | |
| តើមានប្រើប្រាស់ភាសាសាមញ្ញដើម្បីផ្តល់ ព័ត៌មានដល់ជនពិការដែរឬទេ? | | | |
| តើការអញ្ជើញបានផ្តល់ព័ត៌មានអំពីភាព ងាយស្រួលចេញចូលកន្លែងប្រជុំដែរឬទេ? | | | |
| តើអ្នករៀបចំបានសួរទៅជនពិការដែលអញ្ជើញឱ្យចូលរួម ថាតើពួកគេមានតម្រូវការអ្វីបន្ថែមទៀតដែលផ្តល់ភាពងាយស្រួល ដល់ពួកគេដែរឬទេ? | | | |
| ២. ការបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ | | | |
| សូមចាំថាការបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ សំដៅលើរចនាសម្ព័ន្ធរូបវន្ត ផង និងលើវិធីសាស្ត្រប្រាស្រ័យទាក់ទងផង។ | | | |

| ការបរិយាយ/សំណួរគន្លឹះ | បាទ/ចាស | ទេ | កំណត់សម្គាល់ |
|---|---|---|---|
| តើការបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ គឺសម្រាប់គ្រប់ៗគ្នាឬ? សម្រាប់ក្រុមផ្សេងៗឬ (ដូចជា ចាស់ជរា ស្ត្រីមានផ្ទៃពោះ កុមារ ។ល។) | | | |
| នៅលើឯកសារលាយលក្ខណ៍អក្សរ មានប្រើប្រាស់ពណ៌ដិត សម្រាប់អត្ថបទ និងផ្ទៃខាងក្រោយឬទេ? | | | |
| **៣. រៀបចំកន្លែង សម្រាប់កិច្ចប្រជុំ ឬ ព្រឹត្តិការណ៍** | | | |
| តើកន្លែងរៀបចំកិច្ចប្រជុំផ្តល់ភាពងាយស្រួលសម្រាប់ជនពិការដែរឬទេ? | | | |
| តើអគារប្រជុំផ្តល់ភាពងាយស្រួលសម្រាប់ជនពិការដែរឬទេ? | | | |
| តើបង្គន់ ច្រកផ្លូវដើរ និងកន្លែងញ៉ាំ អាហារផ្តល់ភាពងាយស្រួលដល់ជនពិការដែរឬទេ? | | | |
| **៤. មធ្យោបាយដែលជនពិការអាចទៅចូលរួម** | | | |
| តើពួកគេអាចទៅដល់កន្លែងរៀបចំព្រឹត្តិការណ៍ដោយមធ្យោបាយធ្វើដំណើរសាធារណៈបានដែរឬទេ? ប្រសិនបើមិនបាន តើមានជម្រើសផ្សេងទៀតដែរឬទេ (ឧ.រៀបចំការធ្វើដំណើរ ដោយមានការគាំទ្រពីអង្គការជនពិការនៅមូលដ្ឋាន)? | | | |
| តើមានព័ត៌មានអំពីកន្លែងប្រជុំដែរឬទេ? អំពីរបៀបទៅដល់ទីនោះ តើនឹងមានការគាំទ្រអ្វីខ្លះនៅក្នុងកិច្ចប្រជុំនោះ និងតើមានការទូទាត់ចំណាយសម្រាប់ពួកគេវិញដែរទេ? | | | |

| **ការបរិយាយ/សំណួរគន្លឹះ** | **បាទ/ចាស** | **ទេ** | **កំណត់សម្គាល់** |
|---|---|---|---|
| តើមានអ្នកណាម្នាក់នៅច្រកចូលកន្លែងរៀបចំព្រឹត្តិការណ៍នេះ ដើម្បីនាំផ្លូវពួកគេ និងផ្តល់ជំនួយក្នុងករណីដែលចាំបាច់ដែរឬទេ ? | | | |
| តើអ្នកមានព័ត៌មានពីអ្នកដែលត្រូវបានអញ្ជើញ ថាតើពួកគេមានតម្រូវការ ពិសេសអ្វីដែលផ្តល់ភាពងាយស្រួលសម្រាប់ជនពិការ ឬថាតើពួកគេនឹងនាំជំនួយការផ្ទាល់ខ្លួនទៅដែរឬទេ ? | | | |
| តើការបកប្រែសញ្ញាត្រូវបានរៀបចំឡើង និងគ្រោងថវិកាសម្រាប់ក្នុងករណី ដែលមានអ្នកដែលខ្សោយក្នុងការស្តាប់មកចូលរួមដែរទេ ? | | | |
| តើព័ត៌មានជាអក្សរស្ទាប អក្សរបោះពុម្ពធំៗ ឬសំឡេង ត្រូវបានរៀបចំឡើង និងគ្រោងថវិកាក្នុងករណីដែលមានអ្នក ដែលខ្សោយខាងគំហើញ មកចូលរួមដែរឬទេ ? | | | |
| តើវាគ្មិននៅក្នុងកិច្ចប្រជុំនេះបានទទួលព័ត៌មានអំពីការប្រាស្រ័យទាក់ទងដែរឬទេ ? តើវាគ្មិននិយាយយឺតៗ និងច្បាស់ៗដែរទេ ? និងតើមានអ្នកបកប្រែភាសា ឬភាសាកាយវិការដែរឬទេ ? | | | |
| តើបន្ទប់ត្រូវបានរៀបចំឡើងដើម្បីឱ្យរទេះរុញអាចឆ្លងកាត់បានដែរឬទេ ? តើពុំមានវត្ថុអ្វីដែលគេអាចជំពប់ដួលដែរឬទេ ? | | | |
| តើកាលវិភាគសមស្របសម្រាប់អ្នកចូលរួមទាំងអស់ដែរឬទេ ? | | | |